ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Feb-2012, 15:07
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី៣៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក សេង ប៊ុនឃាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោកស្រី ហ្វាល់ហ្គុនី ដេបណាត
*(Falguni DEBNATH)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Michiel Pestman)*

លោក អេនឌ្រូ អ៊ីនូហ្វ៊ី

*(Mr.Victor KOPPE)*

លោក ហ្សាស្ពើ ប៉ៅ

*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីស

*(Ms. Anta GUISSE)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គីមសួន

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោក ឡៅ ជុនធី

លោក អូលីវីយេ បាហ៊ូញ

*(Mr. Olivior BAHOUGNE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោកស្រី ហ្វាល់ហ្គុនី ដេបណាត | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្សុី | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក នួន ជា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ តាមកាលវិភាគដែលបានគ្រោងទុក កិច្ចដំណើរការសវនាការថ្ងៃនេះគឺ អង្គជំនុំជម្រះផ្តល់នូវឱកាសដល់គ្រប់ភាគី ក្នុងការលើកឡើងនូវទឡ្ហីករណ៍តទល់ពាក់ព័ន្ធនឹងឯកសារទាំងឡាយ ដែលមានយោងនៅត្រង់ជើងទំព័រ នៃកថាខណ្ឌនានាក្នុងដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានកំណត់ថា ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ ដែលអង្គជំនុំជម្រះបានជម្រាបជូនភាគីរួចហើយ នៅក្នុងឯកសារ E170 ចាប់ពីកថាខណ្ឌ៥ទៅ។ ប៉ុន្តែដោយកាលពីម្សិលមិញ យើងកិច្ចដំណើរការសវនាការនៅមានបញ្ហាមួយទៀត ដែលអង្គជំនុំជម្រះដំណើរការទៅមិនបានតាមផែនការ ដែលបានគ្រោងទុក គឺសេចក្តីអត្ថាធិប្បាយរបស់ជនជាប់ចោទដែលគាត់មានបំណងឆ្លើយតបទៅនឹងឯកសារ ដែលបានដាក់ដោយភាគី សហព្រះរាជអាជ្ញា ឬក៏ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:០៥:១០]

ហើយនៅព្រឹកនេះ អង្គជំនុំជម្រះនឹងផ្តល់ឱកាសឱ្យដល់ជនជាប់ចោទណា ដែលមានបំណងក្នុងការធ្វើអត្ថាធិប្បាយតបទៅនឹងឯកសារទាំងឡាយ ដែលបានដាក់ដោយភាគី សហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកន្លងមកនេះ។ ហើយដើម្បីសម្រួលបញ្ហានេះ អង្គជំនុំជម្រះសូមសួរទៅលោក នួន ជា ថាតើលោក នួន ជា ត្រូវចំណាយពេលវេលាប្រហែលប៉ុន្មាននៅក្នុងការដែលលោកនឹងធ្វើអត្ថាធិប្បាយតបទៅនឹងឯកសារ ដែលបានដាក់ដោយសហព្រះរាជអាជ្ញា ហើយនិងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកន្លងមកនេះ?

សូមអញ្ជើញលោក នួន ជា! សូមបង្ហាញអំពីពេលវេលាដែលអាចប្រើប្រាស់ នៅក្នុងការធ្វើអត្ថាធិប្បាយជាមុនសិន។

សូមអញ្ជើញមេធាវី!

[០៩:០៦:១៤]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់។

ព្រឹកនេះយើង គឺក្រុមយើងខ្ញុំគឺ សង្ខេបទេប្រសិនណាជាមានការអនុញ្ញាត។ ខ្ញុំសុំឲ្យលោក នួន ជា គាត់ឡើងមុន។ គាត់ប្រហែលជាត្រូវការពេលវេលា១៥ ទៅ ២០នាទី ពាក់ព័ន្ធទៅនឹងឯកសារដែលបានលើកឡើង ហើយបន្ទាប់សហសេវិករបស់ខ្ញុំ អេនឌ្រូ ប្រហែលគាត់ត្រូវការ១៥ ទៅ២០នាទី ទៀត។

ដូច្នេះសរុបមក ក្រុមយើងខ្ញុំប្រហែលជាត្រូវការពេលវេលា៤៥នាទី។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៧:២០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា តាមកាលវិភាគកិច្ចដំណើរការសវនាការ អង្គជំនុំជម្រះបានជម្រាបជូនហើយ ឱកាសដែលនឹងផ្ដល់ឲ្យនៅពេលនេះគឺ ដល់ជនជាប់ចោទ ក្នុងការធ្វើអត្ថាធិប្បាយតបទៅនឹងឯកសារទាំងឡាយដែលត្រូវបានដាក់រួចហើយដោយសហព្រះរាជអាជ្ញា និងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ លោកបានបង្ហាញរួចហើយ អំពីចេតនា និងការចំណាយពេលវេលារបស់ជនជាប់ចោទ នួន ជា ទំនងជា១៥ ទៅ២០នាទី ប៉ុន្តែបញ្ហាទីពីរ លោកស្នើសុំធ្វើអត្ថាធិប្បាយ ដោយខ្លីក្រោយពីការអត្ថាធិប្បាយរបស់លោក នួន ជា។

អង្គជំនុំជម្រះចង់ដឹងថា តើលោកមានបំណងចង់ធ្វើអត្ថាធិប្បាយអំពីបញ្ហាអ្វីជាក់លាក់ទៅ? ពីព្រោះកាលវិភាគក្នុងកិច្ចដំណើរការសវនាការនេះ អង្គជំនុំជម្រះបានជម្រាបជូនអម្បាញ់មិញរួចហើយ ដោយការរំឭកបញ្ជាក់បន្ថែមលើឯកសារ E170 ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ ដែលអង្គជំនុំជម្រះបានជម្រាបអំពីគោលបំណង នៃដំណើរការសវនាការសម្រាប់ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ នេះ។ លោកអាចបញ្ជាក់បានទេ ឲ្យច្បាស់បានទេបញ្ហាអ្វីទៅដែលលោកចង់ធ្វើអត្ថាធិប្បាយបន្ទាប់ពី ការអត្ថាធិប្បាយរបស់កូនក្ដីរបស់លោក?

[០៩:០៩:១៤]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ តាមការយល់ព្រមរបស់ក្រុមខ្ញុំ ក៏ដូចជា លោកប្រធានបានលើក

ឡើងដែរ យើងខ្ញុំត្រូវការប្រហែលជា២០នាទីទេ នេះសម្រាប់កូនក្ដីខ្ញុំ ហើយក្រៅពីនេះគឺសំណើរបស់យើងខ្ញុំវាពាក់ព័ន្ធទៅនឹង E170 នេះគឺ យើងខ្ញុំត្រូវការពេលវេលា២០នាទីបន្ថែមទៀត។ ដូច្នេះ បន្ទាប់ពីលោក នួន ជា ធ្វើបទអត្ថាធិប្បាយ យើងខ្ញុំសុំរយៈពេលពីរបីនាទីបន្ថែមទៀត លើកឡើងអំពីបញ្ហានីតិវិធីគឺខ្លីទេ។ ដូច្នេះ សរុបទាំងអស់តែម្ដង គឺយើងក្រុមយើងខ្ញុំត្រូវការប្រហែលជា៤០ ទៅ៤៥នាទី រួមទាំងពាក់ព័ន្ធទៅនឹងឯកសារ E170 នេះផង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ដោយសារជនជាប់ចោទ នួន ជា គឺត្រូវចំណាយពេលវេលាខ្លីទេ ប្រហែលជា១៥ទៅ២០នាទី ប៉ុណ្ណោះក្នុងការធ្វើអត្ថាធិប្បាយ។ ដូច្នេះអង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យគាត់អាចធ្វើអត្ថាធិប្បាយពីកន្លែងដែលគាត់អង្គុយនៅពីខាងក្រោយមេធាវីរបស់គាត់។

សូមអញ្ជើញលោក នួន ជា! អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅលោក ដើម្បីធ្វើអត្ថាធិប្បាយតបទៅនឹងឯកសារទាំងឡាយ ដែលបានដាក់ដោយក្រុមសហព្រះរាជអាជ្ញា ហើយនិង ឬក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

[០៩:១០:៥៦]

**លោក នួន ជា៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។ ជាដំបូង ខ្ញុំសូមជម្រាបលោកប្រធានថា ខ្ញុំពិតជាមានការលំបាកក្នុងការអានឯកសារទាំងអស់ ឲ្យមានប្រសិទ្ធភាពណាស់ ដោយសារតែវ័យចាស់ជរារបស់ខ្ញុំ។ ជាពិសេស គឺការផ្ចង់អារម្មណ៍ក្នុងការអានឲ្យបានយល់ដឹងពេញលេញ ហើយការចងចាំរបស់ខ្ញុំក៏កាន់តែថមថយទៀត។ ពិតមែនតែខ្ញុំមានក្រុមមេធាវីតំណាងក្នុងការជួយខ្ញុំក៏ដោយ ក៏ខ្ញុំគិតថា ខ្ញុំចាំបាច់ក្នុងការយល់ដឹងនូវរាល់ឯកសារភស្តុតាង ដែលដាក់ដោយភាគីក្នុងការចោទប្រកាន់របស់លើរូបខ្ញុំដែរ។

[០៩:១១:៥១]

ដូចដែលមេធាវីរបស់ខ្ញុំបានលើកឡើងរួចមកហើយថា ដើម្បីឲ្យខ្ញុំឆ្លើយតបដោយមានប្រសិទ្ធភាពនោះ ខ្ញុំសូមស្នើឲ្យភាគីមេត្តាដាក់ជូននូវបញ្ជីឯកសារមកក្រុមយើងខ្ញុំ ឲ្យបានរយៈពេលវែងមុននឹងធ្វើការដេញដោលមកលើរូបខ្ញុំ។ ខាងក្រោមនេះ គឺជាការឆ្លើយតបរបស់ខ្ញុំ ចំពោះឯកសារដែលលើកឡើងដោយសហព្រះរាជអាជ្ញា។

ដំបូង ខ្ញុំសូមលើកឡើងយ៉ាងខ្លីទាក់ទងនឹងឯកសារ IS9.1 ជាលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំសូមលើកឡើងជាការកត់សម្គាល់ជូនអង្គជំនុំជម្រះថា មាត្រាទី៧(១) បាននិយាយយ៉ាងច្បាស់នូវអង្គការដែលមានអំណាចខ្ពស់បំផុតដូចខាងក្រោម៖

"អង្គការរបស់បក្សមានសិទ្ធិអំណាចធំជាងគេបំផុត សម្រាប់ទូទាំងប្រទេស គឺមហាសន្និបាតតំណាងទូទាំងប្រទេស"។ ចប់ការដកស្រង់។

នេះជាឯកសារផ្លូវការរបស់បក្សតែមួយគត់ ក្នុងការបញ្ជាក់ពីអង្គការលេខរបស់បក្ស។ ដូចនេះការដែលរៀបរាប់ពីគណៈឃោធាក្តី គណៈអចិន្ត្រៃយ៍ក្តី ដែលយកចេញពីបុគ្គលមួយចំនួននោះ គឺមិនត្រឹមត្រូវទេ។ ចំណែកបទសម្ភាសន៍ផ្សេងៗជាមួយរូបខ្ញុំ គឺជាការចាំបាច់ត្រូវតែស្តាប់ខ្សែអាត់ដែលបានថតនោះដើម្បីឲ្យដឹងថា ជាសម្តីរបស់ខ្ញុំមែនដែរឬទេ? ដោយឡែកចំពោះឯកសារ IS20.34 ព្រះរាជអាជ្ញាបានលើកឡើងថា ឯកសារដើមជាភាសាអង់គ្លេស។ នេះបញ្ជាក់ឲ្យឃើញថា បទសម្ភាសន៍នោះធ្វើឡើងជាភាសាអង់គ្លេស។

[០៩:១៤:២២]

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំជាជាតិខ្មែរខំតស៊ូលះបង់ជីវិតសុខស្រួលគ្រប់បែបយ៉ាង គឺដើម្បីថែរក្សាជាតិឲ្យគង់វង្សនោះ តើមានបំណងអ្វីក្នុងការនិយាយភាសាបរទេស ដែលមិនមែនជាភាសាកំណើតរបស់ខ្ញុំនោះ។ និយាយឲ្យខ្លីទៅ ខ្ញុំមិនដែលផ្តល់បទសម្ភាសន៍ជាភាសាអង់គ្លេសទេ។ ខ្ញុំគិតថា ខ្ញុំមិនបានផ្តល់ការសម្ភាសបែបនេះទេ ហើយប្រសិនបើមានមែន តាមការពិនិត្យឈ្មោះដែលសម្ភាសខ្ញុំគឺជាជនជាតិខ្មែរ។ ដូចនេះច្បាប់ដើមត្រូវជាភាសាខ្មែរ។ ក្នុងចំណោមអ្នកសម្ភាសនោះ មានលោក អៀ ម៉េងទ្រី ដែលបានសរសេរសៀវភៅពីរក្បាល ដែលមានចេតនាអាក្រក់មកលើរូប-- មកលើរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយកាន់តែអាក្រក់ទៅទៀតនោះ គឺគាត់មានគ្រាមួយនោះ បានបម្រើការងារសម្រាប់ការិយាល័យព្រះរាជអាជ្ញា ដែលជាការិយាល័យធ្វើការសម្រាប់តែការដាក់បន្ទុកមកលើរូបខ្ញុំតែប៉ុណ្ណោះ។

ចំពោះឯកសារដែលនៅសល់ ប្ញូករួមទាំងទស្សនាវដ្តីទង់បដិវត្តផងដែរនោះ ខ្ញុំសូមជម្រាបលោកប្រធានថា ខ្ញុំពិតជាមិនអាចធ្វើអត្ថាធិប្បាយ និងឆ្លើយតបដោយមានប្រសិទ្ធភាពនោះបានទេ ដរាបណាយថាភាពរបស់វាមិនទាន់ត្រូវបានសម្រេចគិតគូរនៅឡើយនោះ។ សំណើរបស់ខ្ញុំលើបញ្ហានេះ គឺងាយស្រួលទេ ដោយសារក្រោយពីស្តាប់សក្ខីកម្មសាក្សីពីររូបមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយជាពិសេសលោក ឆាំង យុ ដែលមានបំណងល្អ ក្នុងការសហការជាមួយតុលាការ ក្នុងការផ្ទៀងផ្ទាត់ពិនិត្យ

ពិច័យជាមួយឯកសារដើម ដែលគាត់អះអាងថា កំពុងតែរក្សាទុកនៅមជ្ឈមណ្ឌលរបស់លោកនោះ។

[០៩:១៧:១៤]

ខ្ញុំសូមទទូចស្នើដល់តុលាការថា គ្រប់ឯកសារដែលផ្ដល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានដាក់ ហើយនឹងត្រូវបានដាក់នៅពេលខាងមុខ ក្នុងការចោទប្រកាន់មកលើរូបខ្ញុំដោយភាគីនានា គឺចាំបាច់ត្រូវតែយកឯកសារដើមមកផ្ទៀងផ្ទាត់ ពិនិត្យពិច័យ ពីយថាភាពរបស់វាក្នុងតុលាការនេះជាមុនសិន។ ហើយប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា វាជាសំណើធំពេកនោះ ខ្ញុំសូមឲ្យមានការផ្ទៀងផ្ទាត់ពិនិត្យពិច័យជាមួយឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងដំណាក់កាលដំបូងនេះសិនចុះ។

ជាការពិត សហព្រះរាជអាជ្ញា គាត់មានអំណាចក្នុងការស៊ើបអង្កេតបឋមក្នុងការដាក់បន្ទុកមកលើរូបខ្ញុំ។ ផ្ទុយពីភាគីខ្ញុំ ដែលពឹងផ្អែកទៅលើការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមានភាពលម្អៀង និងមិនគួរឲ្យទុកចិត្តបាន។ បើគិតៗទៅ ការិយាល័យមួយនេះ ដើរតួសឹងតែដូចគ្នានឹងការិយាល័យសហព្រះរាជអាជ្ញាដែរ។

លោកស្រីចៅក្រម និងអង្គសវនាការ ប្រហែលជាបានដឹងហើយអំពីសេចក្ដីថ្លែងការណ៍របស់អតីតមន្ត្រីជាន់ខ្ពស់ របស់ការិយាល័យនេះ អំពីការលម្អៀងក្នុងការស៊ើបអង្កេត។ ដូចនេះ ខ្ញុំមិនចាំបាច់លើកឡើងទៀតទេ។

អាស្រ័យហេតុនេះ វាគ្មានមន្ទិលសង្ស័យទេដែលថា ឯកសារដែលព្រះរាជអាជ្ញាទទួលមក គឺគាត់ប្រកាសថាជាឯកសារត្រឹមត្រូវពិតប្រាកដតាមច្បាប់ដើម សម្រាប់តែខ្លួនឯង។ ហើយខ្ញុំគិតថា ភាគីផ្សេងទៀត រួមទាំងអង្គជំនុំជម្រះផង ប្រហែលជាមិនដែលបានឃើញឯកសារដើមដែរ។

ខ្ញុំយល់ឃើញថា មានតែអង្គជំនុំជម្រះទេ ដែលមានអំណាចសមស្របបំផុតក្នុងការផ្ដល់ជូនខ្ញុំនូវសំណើនេះ ដើម្បីបម្រើដល់ដំណើរការនីតិវិធីមួយ ដែលបម្រើដល់ការពិត មានប្រយោជន៍ និងយុត្តិធម៌សម្រាប់គ្រប់ភាគីទាំងអស់។

[០៩:២០:៤៥]

ខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះនឹងពិចារណាលើសំណើដែលសមស្របរបស់ខ្ញុំនេះ គឺដើម្បីផ្ដល់លទ្ធភាពឲ្យខ្ញុំបានចូលរួមយ៉ាងសកម្មក្នុងការស្វែងរកការពិតជូនប្រជាជាតិទាំងមូល។ ខ្ញុំគិតថានេះជាសំណើស្របច្បាប់ និងសមស្របបំផុត និងពុំមានឧបសគ្គអ្វីមករារាំងនោះទេ បើយើងពិចារណាទៅគោលជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ។

ខ្ញុំក៏សូមជូនជាការកត់សម្គាល់សម្រាប់អង្គជំនុំជម្រះថា ខ្ញុំជឿជាក់ថា តាមច្បាប់កម្ពុជា គឺខ្ញុំមានសិទ្ធិដាក់ឯកសារភស្តុតាងថ្មីៗបានគ្រប់ពេលរហូតដល់ចប់ដំណើរការក្តី។ ដូចនេះខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យខ្ញុំអនុវត្តសិទ្ធិនេះដោយមានប្រសិទ្ធភាពតាមច្បាប់កំណត់។

[០៩:២២:២៥]

រឿងមួយវិញទៀតនោះ ខ្ញុំយល់ឃើញថា សាក្សីដែលឡើងមកផ្តល់សក្ខីកម្មកន្លងមកនេះ គឺមិនគ្រប់គ្រាន់ទេក្នុងការបញ្ជាក់អំពីប្រវត្តិបក្សនៅមុនឆ្នាំ១៩៧៥។ ដោយសារតែសាក្សីទាំងនោះ គឺជាសាក្សីដែលភាគច្រើនស្នើដោយព្រះរាជអាជ្ញា ហើយតាមការសង្កេត គាត់ដូចជាមិនបានបង្ហាញការសហការជាដុំកំភួនអីទេ។ ចំណែកសាក្សីដែលស្នើដោយខ្ញុំ ដើម្បីឲ្យចូលមកផ្តល់សក្ខីកម្មពីបរិបទនេះ ដូចជាមិនទាន់មានចូលខ្លួនសោះ។ ហើយចំណែកអ្នកជំនាញវិញ គឺមិនទាន់មានអ្នកណាម្នាក់អាចមកចូលខ្លួនបានឡើយ។

ដូច្នេះ បញ្ហាក្នុងបរិបទនេះនៅមានច្រើន និងមិនជ្រះស្រឡះសម្រាប់ប្រជាជាតិទាំងមូលក្នុងការយល់ដឹងឲ្យស៊ីជម្រៅចំពោះរឿងរ៉ាវដែលបានកើតឡើងនោះទេ។ ម៉្យាងវិញទៀត បើតាមការកំណត់ដំណាក់កាលនៃការជំនុំជម្រះ ខ្ញុំគិតថា នេះប្រហែលជាឱកាសចុងក្រោយរបស់ខ្ញុំក្នុងការដេញដោលក្នុងបរិបទនៅមុនឆ្នាំ១៩៧៥ ដែលជាបច្ច័យរបស់រឿងរ៉ាវ និយាយឲ្យចំទៅ គឺក្បាលក្រពើនោះឯង។

[០៩:២៤:២៦]

តើគោលនយោបាយឈ្លានពាន ទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ដ៏ប្រល័យមកលើប្រជាជនកម្ពុជា មិនមានអ្វីដែលគួរឲ្យយើងពិភាក្សាមែនទេឬ? ហើយតើមូលហេតុអ្វីបានជាឯកសារដែលទាក់ទងនឹងការទម្លាក់គ្រាប់បែក និងមហិច្ឆតាលោភលន់ បំបាត់ពូជសាសន៍ លេបទឹកដីរបស់ប្រទេសជិតខាងតែងតែត្រូវបានរារាំង។ បញ្ហានោះមើលទៅឃើញយ៉ាងសាមញ្ញបំផុត គឺភាគីខាងព្រះរាជអាជ្ញាចង់បានប្រវត្តិសាស្ត្រដែលមិនពេញលេញមួយតែប៉ុណ្ណោះ។ តែខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះនឹងសម្រេចលើបញ្ហាទាំងនេះប្រកបដោយឥស្សរយស។

ជាថ្មីម្តងទៀត ខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាសម្រេចតាមសំណើរបស់ខ្ញុំនេះ ដើម្បីផ្តល់ដល់រូបខ្ញុំនូវឱកាសមួយ ដែលអាចឲ្យខ្ញុំមានទំនុកទុកចិត្តខ្លះៗលើអង្គជំនុំជម្រះក្នុងការស្វែងរកការពិត មានប្រយោជន៍ និងយុត្តិធម៌សម្រាប់ភាគីទាំងអស់។ សូមអរគុណ។

[០៩:២៦:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោក នួន ជា។ ហើយជាបន្ត តើមានជនជាប់ចោទផ្សេងទៀតហ្នឹងមានបំណងចង់ធ្វើអត្ថាធិប្បាយតបទៅនឹងឯកសារដែលបានដាក់ដោយភាគីតំណាងសហព្រះរាជអាជ្ញា ហើយនិងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ?

បាទ សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សម្រាប់លោក ខៀវ សំផន លោកមិនមានអ្វីនឹងឆ្លើយតបនៅពេលនេះទេ ហើយសូមសិទ្ធិឆ្លើយតបនៅដំណាក់កាលក្រោយ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសនៅក្នុងការលើកឡើងនូវទឡ្ហីករណ៍តទល់ពាក់ព័ន្ធនឹងឯកសារទាំងឡាយ ដែលមានយោងនៅត្រង់ជើងទំព័រនៅកថាខណ្ឌនានានៅក្នុងដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានកំណត់ថាមានការពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ ដូចដែលអង្គជំនុំជម្រះបានជម្រាបជូននៅក្នុងដីការបស់ខ្លួនលេខ E170 ពីកថាខណ្ឌ៥ តទៅ។

បាទ សូមអញ្ជើញ!

[០៩:២៧:៥៨]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន ដូចដែលខ្ញុំជម្រាបទៅកាន់លោក នូហ្ស៊ីៗ នឹងនិយាយអំពីឯកសារជាក់លាក់ពាក់ព័ន្ធទៅនឹងចំណុចហ្នឹង។ ចំពោះខ្ញុំៗសូមនិយាយតែពីរ ឬក៏បីនាទីតែប៉ុណ្ណោះ ដែលពាក់ព័ន្ធទៅនឹងលោក នួន ជា ដែលគាត់និយាយអម្បាញ់មិញនេះ។ លោក នួន ជា គឺគាត់ៗថា គាត់មិនអាចផ្តល់បានទេទៅលើបរិបទប្រវត្តិសាស្ត្រទូទៅនោះ។ ដូច្នេះហើយដូចដែលខ្ញុំបានជម្រាបកាលពីម្សិលមិញ គឺខ្ញុំសូមរក្សាសិទ្ធិធ្វើជាសេចក្តីថ្លែងការណ៍ទៅលើចំណុចនេះនាពេលក្រោយ។ ដូច្នេះ ខ្ញុំស្នើសុំកុំឱ្យអង្គជំនុំជម្រះបិទវគ្គសវនាការដំបូងនេះសិន។ ហើយនៅពេលនេះ ខ្ញុំនឹងផ្តល់វេទិកាទៅឲ្យសហសេវិករបស់ខ្ញុំដែលត្រូវការរយៈពេល ៤៥នាទី បន្ទាប់មកគឺខ្ញុំនឹងធ្វើការថ្លែងការណ៍ទៅតាមក្រោយ។ សូមអរគុណ។

[០៩:២៩:០៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ហ្សាស្កេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ដូចដែលខ្ញុំជម្រាបអីចឹង ក្រុមមេធាវី នួន ជា គឺចង់ឲ្យអង្គជំនុំជម្រះទុករយៈពេល ៤៥នាទី នៅពេលខាងមុខសម្រាប់ឲ្យយើងខ្ញុំដាក់ជាសេចក្ដីសន្និដ្ឋានពាក់ព័ន្ធទៅនឹងសារៈសំខាន់នៃប្រវត្តិបដិវត្តន៍បក្សកម្ពុជា។ យើងខ្ញុំចង់ពន្យល់ ហេតុអ្វីបានវាសំខាន់ ដែលតុលាការនេះ--

[០៩:២៩:៤១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើដូច្នេះទេ ពីនាទីនេះគឺផ្ដល់ឱកាសជា-- ដល់ភាគីគឺដល់លោកលើកឡើងនូវទឡ្ហីករណ៍តទល់ពាក់ព័ន្ធនឹងឯកសារទាំងឡាយ ដែលមានយោងនៅត្រង់ជើងទំព័រនៃកថាខណ្ឌនានានៅក្នុងដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានកំណត់ថា ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ ដែលអង្គជំនុំជម្រះគ្រោងលើកយកបញ្ហានេះមកពិភាក្សាដេញដោលនៅសម្រាប់វគ្គពីរ នៃដំណើរការពិភាក្សាដេញដោលចំពោះសំណុំរឿង០០២/០១។

ចំណែកឯបញ្ហាអម្បាញ់មិញនេះគឺលោកបាននិយាយម្សិលមិញហើយ យើងបានសម្រេចរួចហើយ គឺមិនអនុញ្ញាតឲ្យលោកឆ្លៀតឱកាសប្រើពេលវេលាដែលអង្គជំនុំជម្រះបានកំណត់ឲ្យលោកធ្វើកិច្ចការនេះទៅធ្វើការងារផ្សេងទៀតនោះឡើយ។

អង្គជំនុំជម្រះបានសម្រេចរួចហើយ អំពីដំណើរការប្រព្រឹត្តទៅនៃការតវ៉ាជំទាស់ទៅនឹងឯកសារដែលក្រុមមេធាវីការពារក្ដីលោក នួន ជា បានដាក់ ដែលជំទាស់ដោយក្រុមសហព្រះរាជអាជ្ញា ចំពោះបញ្ហានេះអង្គជំនុំជម្រះនឹងពិចារណាសម្រេចនៅពេលក្រោយៗពេលដែលក្រុមមេធាវីការពារក្ដី នួន ជា បានដាក់នូវសារណាតបទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញា ឲ្យបាននៅក្នុងចុងសប្ដាហ៍នេះយ៉ាងយូរ គឺចប់ត្រឹមថ្ងៃស្អែក។

[០៩:៣១:១៤]

ដូច្នេះ វេទិកានេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកប្រើប្រាស់ដើម្បីលើកឡើងនូវបញ្ហាផ្សេងទៀតក្រៅពីអ្វីដែលអង្គជំនុំជម្រះបានកំណត់នៅក្នុងចាប់ពីកថាខណ្ឌទីប្រាំនៃ E170 នោះទេ។ អង្គជំនុំជម្រះសង្ឃឹមជឿជាក់ថា មេធាវីស្ដាប់យល់ហើយទោះបីបកប្រែភាសាទៅជាភាសាអង់គ្លេស ឬក៏ភាសា

បាំាំងនោះ ដូចជាភាសាពាក្យពេចន៍ដែលយើងប្រើនេះទំនងជាមិនពិបាកស្តាប់នោះទេ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់នូវអ្វីដែលលោកប្រធានលើកឡើងនៅថ្ងៃនេះ ក៏ប៉ុន្តែប្រហែលជាការបកប្រែ យើងខ្ញុំមិនទទួលការបង្គាប់ឲ្យធ្វើការដាក់ជាលាយលក្ខណ៍អក្សរទៅលើបញ្ហាប្រវត្តិបក្សកុម្មុយនីស្តកម្ពុជានោះទេ។ ការដែលកង្វះតម្លាភាព និងការផ្អែកទៅលើសារណាជាលាយលក្ខណ៍អក្សរគឺមិនសមហេតុផល មិនត្រឹមត្រូវនោះទេ។

[០៩:៣២:២៩]

**ប្រធានអង្គជំនុំ៖**

យើងបានសម្រេចរួចហើយ អត់មានអនុញ្ញាតឲ្យលោកប្រើប្រាស់ពេលវេលានេះដើម្បីលើកបញ្ហាផ្សេងទៀតនោះឡើយ។ ចំពោះសំណើរបស់លោក អង្គជំនុំជម្រះនឹងសម្រេចនៅពេលក្រោយ ថាតើបញ្ហានេះត្រូវគួរតែត្រូវបានលើកបន្ថែមទៀតដែរឬទេ? អង្គជំនុំជម្រះបានជម្រាបរួចហើយ បញ្ហាដែលការតវ៉ាជំទាស់ទៅនឹងការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះចំនួន៣៥ ហើយនិងបន្ថែមបួនទៀតនោះ អង្គជំនុំជម្រះនឹងលើកពិចារណាសម្រេចឲ្យធ្វើ ឬមិនឲ្យធ្វើនៅក្នុងដំណើរការសវនាការលើកក្រោយ។ ចំណែកឯបញ្ហាមួយទៀត គឺអង្គជំនុំជម្រះបានជម្រាបរួចហើយ ថាបើមានសាក្សីឯណាដែលពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រកម្ពុជាដែលគាត់បានដឹងបានឮ ទោះបីយើងទៅធ្វើនៅដំណាក់កាលក្រោយក៏ដោយ ក៏ភាគីពាក់ព័ន្ធក៏អាចសួរដេញដោលពាក់ព័ន្ធទៅនឹងអង្គហេតុនៅក្នុងក្របខ័ណ្ឌបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាបានដែរ។ ដូចចប់សព្វគ្រប់ហើយ មិនមានអីផ្សេងទៀតទេ។

យើងបញ្ជាក់ឡើងវិញថា យើងមិនអនុញ្ញាតឲ្យលោកធ្វើអត្ថាធិប្បាយអ្វីផ្សេងក្រៅពីការអនុវត្តទៅតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះនៅក្នុងអនុស្សរណៈ E170 ចាប់ពីកថាខណ្ឌប្រាំ តទៅនោះឡើយ។

[០៩:៣៣:៥៧]

**លោក ហ្សាស្តើ ប៉ោ៖**

អរគុណលោកប្រធាន ខ្ញុំយល់អំពីការបង្គាប់របស់លោកប្រធាន ខ្ញុំនឹងផ្តល់វេទិកាទៅដល់លោកអ៊ីនូហ្ស៊ី ក៏ប៉ុន្តែយើងខ្ញុំចង់បញ្ជាក់ច្បាស់ថា ចំពោះបញ្ហានុំងគឺយើងខ្ញុំចង់លើកឡើងជាសាធារណៈ។

**ប្រធានអង្គជំនុំ៖**

អត់ឲ្យធ្វើទេ។

**លោក អេនគ្រូ អ៊ីន្ទូហ្សុី៖**

លោក ហ្សាស្តេី ប៉ៅ សូមអរគុណ។ សូមអរគុណលោកប្រធាន ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់លាស់មុនពេលដែលខ្ញុំលើកឡើងការជំទាស់ពាក់ព័ន្ធទៅនឹងបញ្ហារចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ។ ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ពីអង្គជំនុំជម្រះ ថាតើបញ្ហាប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជានេះនៅតែបើកឲ្យយើងដាក់សារណាដដែល ឬក៏យ៉ាងម៉េច? ឲ្យយើងបានយល់ច្បាស់ទៅលើចំណុចហ្នឹង។

[០៩:៣៥:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី ក្លូឌា ហ្វេនស៍ សូមពន្យល់បញ្ជាក់ឲ្យបានច្បាស់លាស់បញ្ហានេះ ចំពោះក្រុមមេធាវីការពារក្តី នួន ជា។ សូមអញ្ជើញលោកស្រី។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំយល់ថាបញ្ហាហ្នឹង គឺបញ្ជាក់កាលពីម្សិលមិញហើយ នៅពេលដែលមេធាវីលើកឡើង។ យើងខ្ញុំសូមបញ្ជាក់នៅថ្ងៃនេះ គឺយើងខ្ញុំមិនចង់ឲ្យលោកលើកឡើង ដោយផ្ទាល់មាត់នៅក្នុងតុលាការនោះទេ។ លោកត្រូវលើកជាលាយលក្ខណ៍អក្សរ ដែលយើងត្រូវយកមកពិចារណា និងចំពោះបញ្ហាដែលយើងបញ្ជាក់ហ្នឹង និងបញ្ហាផ្សេងទៀត។

[០៩:៣៥:៤៩]

**លោក អេនគ្រូ អ៊ីន្ទូហ្សុី៖**

សូមអរគុណលោកស្រីចៅក្រម ហ្វេនស៍ វាច្បាស់ហើយសម្រាប់យើងខ្ញុំនៅពេលនេះ។

នៅពេលនេះ ខ្ញុំសូមលើកការជំទាស់ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ ដែលបានកំណត់នៅក្នុងឯកសារ E170។ ខ្ញុំនឹងលើកឡើងដោយសង្ខេបទេ មានចំណុចចំនួនបី។ ទីមួយ សូមបញ្ជាក់ការជំទាស់ទូទៅរបស់ក្រុមយើងខ្ញុំ ពាក់ព័ន្ធទៅនឹងឯកសារមុនៗ ដែលយើងដាក់នៅក្នុងថ្ងៃ១៦ ខែមករា។ យើងខ្ញុំសូមរក្សាសិទ្ធិដាក់ជាលាយលក្ខណ៍អក្សរ តាមការបង្គាប់របស់មន្ត្រីច្បាប់ជាន់ខ្ពស់នៅក្នុងអនុស្សរណៈ។ ចំណុចមួយដែលលើកឡើងកាលពីមុន ហើយខ្ញុំចង់បញ្ជាក់នៅក្នុងថ្ងៃនេះផងដែរ យើងខ្ញុំសូមបញ្ជាក់ថា ចំពោះចម្លើយសាក្សី ដែលពាក់ព័ន្ធទៅនឹងអំពើរបស់ជនជាប់ចោទ ឬក៏

ពាក់ព័ន្ធទៅនឹងរឿងក្ដីនេះ បញ្ហារចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ គឺវាមិនពាក់ព័ន្ធ។ ដូច្នេះ ចំណុចទាំងអស់ ឯកសារទាំងអស់នោះ គឺត្រូវតែដាក់នៅក្នុងតុលាការ ដើម្បីដេញដោល។ ដូចដែលខ្ញុំដឹងហើយថា សហព្រះរាជអាជ្ញា បានលើកឡើងទៅលើបញ្ហាហ្នឹង។

ខ្ញុំឃើញថា ដូចជាខាងសហព្រះរាជអាជ្ញាគាត់ឡើងក្រោកឈរឡើងដើម្បីចង់លើកជាយោបល់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[០៩:៣៧:២៧]

**លោកស្រី ហ្វាល់ហ្គុនី ដេបណាត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមទោសដែលខ្ញុំស្កាត់នៅទីនេះ។ ខ្ញុំសូមបញ្ជាក់ថា ចម្លើយសាក្សីត្រូវបានដកចេញ តាមរយៈអនុស្សរណៈរបស់មន្ត្រីជាន់ខ្ពស់ច្បាប់ជាន់ខ្ពស់ ចេញពីការពិភាក្សានៅទីនេះពាក់ព័ន្ធទៅនឹងអង្គហេតុ រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ។ យើងខ្ញុំកំពុងរង់ចាំសេចក្ដីសម្រេចពីតុលាការពាក់ព័ន្ធទៅនឹងចំណុចហ្នឹង។ ដូច្នេះហើយពាក់ព័ន្ធទៅនឹងបញ្ហាចម្លើយសាក្សីនេះ មិនគួរយកមកធ្វើការលើកឡើងចំពោះការជំទាស់នេះទេ។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំសូមលើកឡើងជំទាស់ថា យើងប្រើចម្លើយសាក្សីនោះក្នុងលក្ខណៈទូទៅ។ ហើយអង្គជំនុំជម្រះក៏បានចែកជូននូវបញ្ជី នូវឯកសារជាច្រើនដែលយើងត្រូវយកមកពិភាក្សា នៅក្នុងថ្ងៃនេះ គឺនៅក្នុងចំណុចទីពីរ ដែលក្នុងនោះលើកឡើងអំពីលោក មាស មុត ដែលជាលេខានៅក្នុងកងទ័ពជើងទឹក។ ដូច្នេះខ្ញុំឃើញថា ចំណុចនេះ គឺវាពាក់ព័ន្ធនៅក្នុងបញ្ជីឯកសារដែលបានដាក់នោះ។ ដូច្នេះ ខ្ញុំគិតថា តើវាមិនពាក់ព័ន្ធយ៉ាងម៉េចទៅនឹងឯកសារហ្នឹង?

[០៩:៣៨:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៩:៤០]

**លោកស្រី ហ្វាល់ហ្គុនី ដេបណាត៖**

សូមអរគុណលោកប្រធាន។ ដើម្បីជាការបញ្ជាក់យើងមានបញ្ជីពីរ ពាក់ព័ន្ធទៅនឹងឯកសារអម្បាញ់មិញនេះនៅក្នុងសវនាការ។ ទីមួយគឺបញ្ជីពីខាងសហព្រះរាជអាជ្ញា ដែលក្នុងនោះមានឯកសារ

១៥។ ក្រោយមកមន្ត្រីច្បាប់ជាន់ខ្ពស់បានផ្ដល់បញ្ជីឯកសារ ១២០ឯកសារ។ ឯកសារទាំងពីរនេះ គឺមានឯកសារដែលជាកម្មវត្ថុនៃបញ្ជីឯកសារទីមួយត្រូវយកមកដេញដោលក្នុងសវនាការ។ ឧទាហរណ៍បញ្ជីទាំងពីររួមមានឯកសារ ដែលយោងនៅក្នុងកំណត់សម្គាល់ទីមួយពាក់ព័ន្ធទៅនឹងឯកសារប្រវត្តិសាស្ត្រ។ ដូច្នេះហើយឯកសារទាំងអស់នោះ គឺជាកម្មវត្ថុនៃការដេញដោលរួចមកហើយ។ លើសពីនេះទៀតឯកសារមួយចំនួននៅក្នុងបញ្ជីទាំងពីរ ដែលមាននៅក្នុងឧបសម្ព័ន្ធ១-៥ ក៏ជាកម្មវត្ថុនៅក្នុងការដេញដោលនៅក្នុងបញ្ជីទីមួយ នៅក្នុងសវនាការផងដែរ។

[០៩:៤០:៤២]

ឯកសារទាំងអស់នោះ មិនត្រូវយកមកដេញដោលសាជាថ្មីទៀតទេនៅក្នុងថ្ងៃនេះ។ ឯកសារដែលយើងបានយោង គឺ IS19.111 គឺឯកសារមួយដែលពាក់ព័ន្ធទៅនឹងចម្លើយសាក្សី ដែលចម្លើយនេះត្រូវបានដកចេញមិនឲ្យពិភាក្សានោះទេ។ ហើយឯកសារមួយទៀតក៏វាជាឯកសារសាក្សីផងដែរ ដែលនៅក្នុងជើងទំព័រឯកសារប្រវត្តិសាស្ត្រដែលក្នុងនោះវាពាក់ព័ន្ធទៅនឹងឯកសារឧបសម្ព័ន្ធ១-៤។

សូមអរគុណលោកប្រធាន។

**លោក អេនគ្រូ អ៊ីនូហ្សឺ៖**

លោកប្រធាន ប្រសិនបើអនុញ្ញាត គឺប្រហែលជាសាធារណជនគាត់ច្រឡំ។ ឯកសារនោះ គឺចែកជូនដោយអង្គជំនុំជម្រះ ហើយបញ្ជីនោះគឺជាឯកសារដែលត្រូវពិភាក្សាក្នុងថ្ងៃនោះ-- ថ្ងៃនេះ ប្រសិនបើខ្ញុំខុសសុំឲ្យកែតម្រូវខ្ញុំ ថាតើវាមានបញ្ជីចែកជូនភាគីសាជាថ្មីដែរឬទេ? បញ្ជីដែលខ្ញុំទទួលបាននេះ គឺបញ្ជីថ្ងៃ១៥ ខែមួយ។ ដូច្នេះវាជាការយល់ចំពោះខ្ញុំយ៉ាងច្បាស់ដែលថា ខ្ញុំត្រូវតែលើកឡើងជំទាស់ទៅនឹងបញ្ជីឯកសារមួយនេះ។ តើពិតជាដូច្នោះដែរឬទេ?

[០៩:៤២:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៥:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្ដល់វេទិកាទៅលោកស្រីចៅក្រម ហ្វេនស៍ ដើម្បីពន្យល់ដល់ក្រុមមេធាវីការពារក្ដី នួន ជា អំពីបញ្ហានេះ។ សូមអញ្ជើញ!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

វាជាការពិត នៅអនុស្សរណៈចុះថ្ងៃទី១៩ ខែពីរ ថ្ងៃនេះ គឺយើងត្រូវពិភាក្សាទៅលើឯកសារថ្ងៃ--ចុះថ្ងៃ០២ ខែកុម្ភៈ ឆ្នាំ២០១២។ ដូច្នេះអង្គជំនុំជម្រះគឺចង់ឲ្យពិភាក្សាទៅលើបញ្ជីឯកសារនេះ។ យើងបានកត់សម្គាល់ទៅលើយោបល់ទូទៅរបស់ក្រុមមេធាវីការពារក្តី តាមដែលខ្ញុំយល់ត្រឹមត្រូវនោះគឺគាត់សុំឲ្យកោះហៅអ្នកដែលសរសេររបាយការណ៍ទៅលើឯកសារពាក់ព័ន្ធទៅនឹងៗផ្នែកនៃសវនាការវគ្គនេះ។ នេះជាតាមអ្វីដែលខ្ញុំយល់។

[០៩:៤៧:០២]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

ខ្ញុំសូមបញ្ជាក់លោកស្រីចៅក្រមចង់បានន័យថា ខ្ញុំមិនអាចយោងទៅលើឯកសារដែលមាននៅក្នុងបញ្ជីនេះទេ ឬក៏យ៉ាងម៉េច? ខ្ញុំបានមើលទៅលើអនុស្សរណៈទី១៧០ ដែលយើងត្រូវលើកពាក់ព័ន្ធទៅនឹងឯកសារទាំងអស់នេះ។ ដូច្នេះ ចំពោះខ្ញុំ ខ្ញុំយល់ហើយថាឯកសារ E170 និងអ្វីដែលសរសេរយោងទៅលើឯកសារនៅក្នុងនោះ គឺវាត្រូវយកមកដេញដោល លើកលែងតែខ្ញុំយល់ច្រឡំ។ បញ្ជីរបស់ខ្ញុំនេះគឺវាដូចជាដាក់ក្នុង*មេម៉ូរ*ហើយ អនុស្សរណៈរួចហើយ។

[០៩:៤៧:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៨:០៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អង្គជំនុំជម្រះនឹងសូមធ្វើការសម្រាកប្រហែលជាប៉ុន្មាននាទី ដើម្បីធ្វើការបញ្ជាក់បំភ្លឺជូនលោក ហើយជាពិសេសពាក់ព័ន្ធទៅនឹងបញ្ជីដែលមានសរសេរនៅក្នុងអនុស្សរណៈ។ បន្ទាប់មក គឺថាយើងនឹងបញ្ជាក់ឲ្យបានច្បាស់ថាតើយើងអនុញ្ញាតឲ្យធ្វើអ្វីនៅក្នុងថ្ងៃនេះ។ យើងខ្ញុំគិតថាសម្រាកប្រហែលជា ១៥នាទីសិន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោកស្រី ហ្វាល់ហ្គុនី ដេបណាត៖**

វាជាការជួយទៅដល់អង្គជំនុំជម្រះ យើងខ្ញុំបានផ្តល់ជូនទៅលើបញ្ជីរបស់យើងខ្ញុំ ដែលបញ្ជីនោះ

មានឯកសារ១២០ ដើម្បីឲ្យអង្គជំនុំជម្រះយល់ថា មិនមានឯកសារដែលយកមកដេញដោលជាន់ទៅនឹងវគ្គមុន។ ដូច្នេះហើយយើងខ្ញុំសូមផ្តល់ឯកសារនេះ ដែលជាជំនួយក្នុងការជួយជ្រោមជ្រែងទៅដល់អង្គជំនុំជម្រះ។ សូមអរគុណ។

[០៩:៤៩:០៩]

**លោក អេនឌ្រូ អ៊ីអ៊ុនហ្ស៊ី៖**

ដើម្បីបន្ថែមទៅលើកំណត់ប្រតិចារឹក យើងខ្ញុំនៅថ្ងៃនេះរៀបចំខ្លួនដើម្បីដេញដោលទៅលើឯកសារទាំងអស់នេះ។ ដូច្នេះហើយ គឺយើងខ្ញុំគ្រាន់តែចង់បញ្ជាក់ថា យើងខ្ញុំចង់ដេញដោលទៅលើឯកសារដែលយើងខ្ញុំបានត្រៀម។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ និងជុំវិញបន្ទប់សវនាការ។ ខ្ញុំក៏អាចថាជាការជួយជ្រោមជ្រែងទៅដល់តុលាការផងដែរ មានបញ្ជីមួយចំនួន សហព្រះរាជអាជ្ញាក៏ផ្តល់បញ្ជី ប៉ុន្តែមានបញ្ជីផ្សេងទៀត។ នៅថ្ងៃទី១០ យើងកត់សម្គាល់មន្ត្រីច្បាប់ជាន់ខ្ពស់ពីររូប គឺលើកឡើងជាន់គ្នា។ យើងខ្ញុំសូមចង្អុលបញ្ជាក់ថា វាជាការជាន់គ្នា។ យើងឃើញអ៊ីម៉ែលពីខាងមន្ត្រីច្បាប់ជាន់ខ្ពស់ ដែលក្នុងនោះផ្តល់បញ្ជីលម្អិតមកកាន់យើង ដែលវាសរុបឯកសារទាំងអស់៩៥ ដែលយើងត្រូវយកមកដេញដោលនៅក្នុងថ្ងៃនេះ។

ដូច្នេះយើងខ្ញុំយល់ថា បញ្ជីនុំង គឺជាបញ្ជីដែលវាគ្រប់គ្រងក្នុងសវនាការថ្ងៃនេះ គឺបញ្ជីដែលមន្ត្រីច្បាប់ជាន់ខ្ពស់បញ្ជាក់យ៉ាងច្បាស់ក្រោយពីយើងចង្អុលបញ្ជាក់ថា បញ្ជីមុនដែលមានឯកសារ១២០ ដែលថា ១២០នោះ វាមានឯកសារជាន់គ្នា។ នោះជាអ្វីដែលយើងយល់។ យើងខ្ញុំជឿថា យើងខ្ញុំបានទទួលបញ្ជីនេះកាលពីថ្ងៃពុធមុន-- ថ្ងៃព្រហស្បតិ៍មុន ឬក៏ថ្ងៃសុក្រមុន។

**លោក អេនឌ្រូ អ៊ីអ៊ុនហ្ស៊ី៖**

ប្រសិនបើអនុញ្ញាត ហើយវាអាចជួយទៅដល់អង្គជំនុំជម្រះ យើងឃើញមានបញ្ជីដែលមានឯកសារចំនួនប្រាំមួយ។ ដូច្នេះហើយខ្ញុំអាចផ្តល់ជូនអង្គជំនុំជម្រះនៅពេលនេះ ដើម្បីជួយទៅដល់អង្គជំនុំជម្រះក្នុងការពិភាក្សាពេលឈប់សម្រាក។

[០៩:៥១:១៣]

**ប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញលោកមេធាវីការពារក្ដី ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណ។ ខ្ញុំបាទសូមធ្វើការកត់សម្គាល់ទាក់ទងទៅនឹងសំណើរបស់តំណាងសហព្រះរាជអាជ្ញា ដែលថាដាក់បញ្ជីថ្មីនេះ។ ខ្ញុំបាទគិតថា ការទទួលយកបញ្ជីថ្មីនេះប្រហែលជាមិនអាចធ្វើបានទេសម្រាប់ពេលនេះ ហើយបើសិនជាត្រូវទទួលយកបញ្ជីយកមកធ្វើការពិភាក្សា គឺត្រូវផ្ដល់ពេលវេលាឱ្យយើងខ្ញុំ ដើម្បីធ្វើការសិក្សាទៅលើបញ្ជីនោះផងដែរ។

[០៩:៥១:៤០]

ប៉ុន្តែបើទាក់ទងទៅនឹងបញ្ជីដែលក្រុមអ្នកច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះបានផ្ញើឱ្យ ដែលមានឯកសារចំនួន៩៥នោះ។ បើសិនជាដកចេញនូវឯកសារណាមួយ អាចមិនមែនជាចំណោទទេ ក៏ប៉ុន្តែបើសិនថែមឯកសារបញ្ចូលក្នុងបញ្ជីនោះ គឺត្រូវផ្ដល់ពេលវេលាឱ្យភាគី ដើម្បីពិនិត្យទៅលើបញ្ជីទាំងនោះឱ្យបានល្អិតល្អន់ជាមុនសិនដែរបាទ។

ដូច្នេះខ្ញុំបាទសូមបញ្ជាក់ជំហរថា សូមជំទាស់ចំពោះការដាក់បញ្ជីថ្មីសម្រាប់ការពិភាក្សានៅពេលនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយឥឡូវនេះដោយមានបញ្ហាផង ហើយពេលវេលាក៏សមល្មមនឹងសម្រាកដែរ អង្គជំនុំជម្រះប្រកាសសម្រាក៤០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ០៩:៥៣ នាទី ដល់ម៉ោង ១០:៣៨ នាទី)*

[១០:៣៨:៥៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ដោយមានបញ្ហាអំពីឯកសារដែលពាក់ព័ន្ធនឹងកិច្ចដំណើរការពិភាក្សា ជជែក តទល់នៅពេលនេះ។ ហើយឥឡូវនេះក្រោយពីបានពិចារណាពិនិត្យពិចារណាលើបញ្ហានេះ ខ្ញុំក្នុងនាមជាប្រធានអង្គជំនុំជម្រះសូមប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីឆ្លើយបំភ្លឺជម្រាបជូនទៅភាគីអំពីបញ្ហាឯកសារនេះ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទសូមអរគុណលោកប្រធាន។ គោលបំណងនៃសវនាការនេះ អង្គជំនុំជម្រះបានចេញអនុស្សរណៈមួយចុះថ្ងៃទី១៩ កុម្ភៈ ឆ្នាំ២០១២ ក្នុងបំណងត្រៀមលក្ខណៈសវនាការនេះនូវបញ្ជីមួយចំនួនដែលថា លើកមកដេញដោលនៅថ្ងៃនេះ ហើយនិងបានបញ្ជូនទៅភាគីទាំងអស់ហើយ។ បញ្ជីចុងក្រោយគឺជាបញ្ជីដែលបញ្ជូនទៅដល់ភាគីនៅថ្ងៃទី១០ កុម្ភៈ ឆ្នាំ២០១២ ហើយនៅក្នុងបញ្ជីនេះមានឯកសារចំនួន៩៥។

[១០:៤១:00]

ឯកសារមួយចំនួននេះប្រហែលជាមានខ្លឹមសារខុសពីការចង្អុលបង្ហាញនៅក្នុងអនុស្សរណៈមុន ក៏ប៉ុន្តែទោះយ៉ាងណាក្តី បញ្ជីចុងក្រោយនេះ គឺជាមូលដ្ឋាននៃភាគីទាំងអស់គ្នាដែលត្រូវពិភាក្សាលើ។ ហើយអង្គជំនុំជម្រះចង់ឲ្យអង្គជំនុំជម្រះលើកការជំទាស់ទៅលើឯកសារចំនួន៩៥ ដែលមាននៅក្នុងបញ្ជីនេះ។ អង្គជំនុំជម្រះក៏ចង់រំឭកផងដែរថា គោលបំណងនៃសវនាការនេះ គឺពិភាក្សាអំពីភាពដែលអាចដាក់ឯកសារនេះមកពិភាក្សាបានដែរឬទេ? គឺមិនមែនការពិភាក្សាលើខ្លឹមសារនៃឯកសារទាំងអស់នេះនោះទេ។ ក៏ប៉ុន្តែគឺចង់ដឹងថា តើការសន្និតលើភាពអាចទទួលយកបាន ទុកចិត្តយកបាន ឬក៏យថាភាពនៃឯកសារនោះ មានលក្ខណៈយ៉ាងណា ពីព្រោះមានកំណត់ហេតុនៅជើងទំព័រហើយ។ អ៊ីចឹងត្រូវពិភាក្សាលើការសន្និតលើយថាភាព និងភាពទទួលយកបាន គួរឲ្យទុកចិត្តនេះ។ ឥឡូវនេះ ខ្ញុំផ្តល់វេទិកាទៅដល់ភាគីទាំងអស់។

[១០:៤២:៣៦]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីជាតិការពារក្តីលោក នួន ជា!

លោក១ ការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តមៈ**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ ហើយសូមអភ័យទោសដោយសារលើកសំណើ ត្រូវការលើកសំណើមិនបានមុនពេលតុលាការប្រកាសសម្រាក។ ហើយនាពេលនេះលោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់ក្នុងសវនាការសម្រាប់ថ្ងៃនេះ ដោយសារមូលហេតុសុខភាព គឺបញ្ហា ពិសេសបញ្ហាឈឺចង្កេះ។ ហើយតែសូមចូលរួមសវនាការដោយប្រយោលពីបន្ទប់រង់ចាំនៅខាងក្រោម។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាអនុញ្ញាត។ សូមអរគុណ។

[១០:៤៣:១៩]

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំមិនចូលរួមតាមដានកិច្ចដំណើរការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តការតាមដានកិច្ចដំណើរការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍នៅបន្ទប់ខាងក្រោម ដែលបានរៀបចំសម្រាប់ជនជាប់ចោទរូបនេះរួចហើយ។ ដោយសារបញ្ហាសុខភាពមិនអាចអង្គុយស្តាប់យូរបាននៅក្នុងកិច្ចដំណើរការផ្ទាល់នាពេលនេះ។

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់ខ្លួន ដោយលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការពីចម្ងាយ ពីបន្ទប់ខាងក្រោម តាមរយៈឧបករណ៍សោតទស្សន៍ក្នុងអំឡុងពេលធ្វើសវនាការសម្រាប់ថ្ងៃនេះ។ តែអង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក អៀង សារី ប្រគល់មកអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ។ ហើយបង្គាប់ឲ្យខាងផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធសោតទស្សន៍ សំឡេង និងរូបភាពសម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅក្នុងអំឡុងពេលធ្វើសវនាការសម្រាប់ថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅបន្ទប់ខាងក្រោមនៃបន្ទប់សវនាការនេះដែលមានរៀបចំឧបករណ៍សោតទស្សន៍ជាស្រេចសម្រាប់គាត់ តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ហើយសូមនាំឲ្យគាត់ទៅចុះ!

[១០:៤៤:៥៦]

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោកស្រី ហ្វាល់ហ្គុនី ដេបណាត៖**

សូមអរគុណលោកប្រធាន។ លោកប្រធានជាទីគោរព ខ្ញុំស្នើសុំអង្គជំនុំជម្រះឲ្យរម្លឹកមេធាវីទាំងអស់កុំឲ្យប្រើប្រាស់ឈ្មោះជាក់លាក់នៃសាក្សីសក្តានុពល ឬក៏សាក្សីសំខាន់ៗនៅក្នុងបញ្ជីសាក្សីរបស់អង្គសវនាការក្នុងពេលធ្វើសវនាការនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយអង្គជំនុំជម្រះក៏សង្ឃឹមជឿជាក់ដូច្នេះដែរ ដោយសារមូលហេតុអំមិញនេះយើងបានបញ្ជាក់ហើយអំពីការជជែកពិភាក្សាតទល់អំពីបញ្ហាទូទៅនៃឯកសារ ដែលពាក់ព័ន្ធនឹងការសម្រេចរបស់អង្គជំនុំជម្រះកាលពីថ្ងៃទី២៦ មករា ឆ្នាំ២០១២ ដែលការសន្មតឯកសារដែលបានយោងនៅក្នុងដីកាដំណោះស្រាយទាំងអស់ជាឯកសារពាក់ព័ន្ធ និងអាចជឿជាក់បាន។ ហើយដូច្នេះទេ នៅក្នុងអំឡុងពេលនៃកិច្ចពិភាក្សានេះ សូមលើកតែបញ្ហាទូទៅ ហើយជៀសវាងក្នុងការលើកឡើងជាក់លាក់ចំពោះសាក្សីឬក៏ដើមបណ្តឹងរដ្ឋប្បវេណីនោះ។ ហើយប្រសិនបើជៀសមិនផុតទេនោះ គឺគប្បីប្រើប្រាស់នូវរហស្សនាមដែលបានកំណត់រួចហើយ។ សូមអញ្ជើញ!

[១០:៤៦:៣២]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន សូមអរគុណចៅក្រម ឡាវែន ដែលបានបញ្ជាក់បំភ្លឺ។ ខ្ញុំមិនលើកឡើងឆ្លើយតបទៅលើសេចក្តីថ្លែងការណ៍នេះទេ ក៏ប៉ុន្តែយើងកត់ត្រាទុកនូវបញ្ហាទាំងអស់នេះ ហើយយើងខ្ញុំអាចបញ្ចប់បញ្ហារបស់យើងនៅមុនម៉ោងអាហារថ្ងៃត្រង់។ ខ្ញុំលើកឡើងឯកសារលេខ IS19.111 ដែលជាកិច្ចសម្ភាសរបស់អតីតលេខាភូមិភាគ-- លេខាយោធា ឯកសារ D100--

**អ្នកបកប្រែ៖**

បាទ សូមលោកប្រធានឲ្យជួយឲ្យមេធាវីគាត់អាននូវលេខប្រតិចារឹក លេខឯកសារឡើងវិញ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីចាប់ផ្តើមម្តងទៀត ដោយសារលោកនិយាយលឿនពេក ហើយការបញ្ជាក់នូវអត្តសញ្ញាណឯកសារមិនច្បាស់ សូមឲ្យយឺត ហើយបញ្ជាក់ឲ្យច្បាស់ដើម្បីប្រតិចារឹកផង ដើម្បីអ្នកបកប្រែភាសាហ្នឹងអាចតាមទាន់ក្នុងការបកប្រែភាសា។

[១០:៤៧:៤៣]

**លោក អេនឌ្រូ អ៊ីនួហ្វ៊ី៖**

ខ្ញុំនឹងគោរពតាម សូមអរគុណ។ ឯកសារទីពីរ គឺ D210 *ស្រ្លាក* 2 ជាលិខិតឆ្លើយតបពី ស្ទីវិន ហេដឌ័រ ដែលចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ពាក់ព័ន្ធទៅនឹង អ៊ុក ប៊ុនឈឿន និង ស៊ីម កា និងអ្នកដទៃទៀត។

ឯកសារទីបី គឺ D248 *ស្រ្លាក* 2.2 ជាកំណត់ប្រតិចារឹកនៃការសម្ភាសដែលធ្វើឡើងដោយលោក ស្ទីវ ហេដឌ័រ។

ឯកសារទីបួន គឺ D269 *ស្រ្លាក* 9 *ស្រ្លាក* 1.15 គឺជាកំណត់សម្គាល់លាយលក្ខណ៍អក្សរដោយ អ៊ុក ប៊ុនឈឿន ដែលសម្ភាសដោយ ប៉ែន យៀរនិន។

ឯកសារទីប្រាំ D269*ស្រ្លាក 9 ស្រ្លាក* 1.15.1 ជាកំណត់ត្រាជាលាយលក្ខណ៍អក្សរ កិច្ចសម្ភាស អ៊ុក ប៊ុនឈឿន ដោយ ប៉ែន យៀរនិន ដែលគេបានវាយដោយកុំព្យូទ័រឡើងវិញ។

ឯកសារចុងក្រោយ គឺ D313 *ស្រ្លាក* 1.2.406 ជាកិច្ចសម្ភាសជាមួយនឹង ជា ស៊ីម, ហេង សំរិន ចុះថ្ងៃៗទី២ ខែធ្នូ ឆ្នាំ១៩៩១ នៅក្នុងទីក្រុងភ្នំពេញ។

ពាក់ព័ន្ធទៅនឹងឯកសារទាំងប្រាំមួយ ដូចដែលខ្ញុំបានកំណត់អត្តសញ្ញាណទាំងអស់នេះ គឺវាជាឯកសារពាក់ព័ន្ធទៅនឹង មាស មុត ដែលជាមេបញ្ជាការជនសង្ស័យនៅក្នុងសំណុំរឿង០៣ ហើយជាហើយនិងឯកសារពាក់ព័ន្ធទៅនឹង ស៊ីម កា, អ៊ុក ប៊ុនឈឿន ជាសក្សីដែលយើងសុំកោះឲ្យមកតុលាការ និងទាក់ទងទៅនឹង ជា ស៊ីម ប្រធានព្រឹទ្ធសភា ហើយនិងលោក ហេង សំរិន ប្រធានរដ្ឋសភា។

បុគ្គលទាំងអស់នេះ គឺយើងបានលើកឡើង ថាគួរតែកោះហៅមកស្តាប់ចម្លើយនៅក្នុងតុលាការ ហើយចំណុចមួយទៀតជាទូទៅ គឺយើងគួរពិនិត្យពិចារណាអំពីទម្ងន់នៃកិច្ចសម្ភាសទាំងអស់នេះ ពាក់ព័ន្ធទៅនឹងអំពើរបស់ជនជាប់ចោទ ហើយចំពោះសវនាការវាដែលពាក់ព័ន្ធទៅនឹងបញ្ហារចនាសម្ព័ន្ធ និងប្រព័ន្ធទំនាក់ទំនងការងារ យើងគិតថាសាក្សីទាំងអស់នោះ គឺវាពាក់ព័ន្ធទៅនឹងផ្នែកដែលជាវគ្គសវនាការដំបូងដែលមិនទាន់បានបិទនៅឡើយនៅពេលនេះ។

[១០:៥០:២៦]

ចំពោះការជំទាស់ ទីមួយ គឺអង្គជំនុំជម្រះមិនបានដាក់ឈ្មោះទាំងអស់នោះនៅក្នុងបញ្ជីបណ្តោះអាសន្ន ដូចដែលយើងបានជម្រាបអ៊ីចឹង។ យើងកោះ-- ចង់កោះឲ្យមកផ្តល់ជាចម្លើយ។

ចំណុចទីពីរ គឺយើងសូមជំទាស់ ដែលអង្គជំនុំជម្រះមិនបានចាត់វិធានការកែតម្រូវ ចំពោះបុគ្គលទាំងអស់នេះ។ បុគ្គលទាំងបួន ដូចដែលខ្ញុំបានលើកឡើង ហើយមិនបានជំរុញរដ្ឋាភិបាល ហើយក៏មិនបានសុំឱ្យគាត់-- សុំឱ្យបុគ្គលទាំងអស់នោះ ចូលមកក្នុងតុលាការ។ ដូច្នេះហើយ ទាំងអស់នេះហើយ វាពាក់ព័ន្ធទៅនឹងឯកសារដែលយើងបានស្នើឡើង។

ចំណុចចុងក្រោយ យើងខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា យើងខ្ញុំនឹងទទួលសំណើពីលោកប្រធាន នៅថ្ងៃទី៨ ខែកុម្ភៈ ដែលវាពាក់ព័ន្ធទៅនឹងវិធាន៣៥។ ពាក់ព័ន្ធទៅនឹងការថ្លែងការណ៍របស់លោក ហ៊ុន សែន ធ្វើឡើងនៅប្រទេសវៀតណាម--។

[១០:៥១:៣១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចបញ្ហាហ្នឹងរួចហើយ។ ឥឡូវហ្នឹង ឯកសារគឺ៩៥ឯកសារ ដែលត្រូវលើកមកជជែកដេញដោលតទល់នៅពេលនេះ។ បញ្ហាផ្សេងទៀតនោះ គឺអង្គជំនុំជម្រះបានសម្រេចរួចហើយ ឱ្យលោកដាក់ជាលាយលក្ខណ៍អក្សរ។ ហើយអង្គជំនុំជម្រះនឹងទទួលយកបញ្ហានោះ ទៅពិនិត្យពិចារណាសម្រេចនៅក្នុងអំឡុងពេលសវនាការលើកក្រោយ។

ដូច្នេះ ហួសពីអ្វីដែលជាកម្មវត្ថុ និងគោលបំណងនៃការដំណើរការសវនាការនៅថ្ងៃនេះ។ អង្គជំនុំជម្រះបានជម្រាបច្បាស់លាស់ហើយ។

**លោក អេនច្រូ អ៊ីអាន្ធូហ្ស៊ី៖**

សូមអរគុណ ដែលបានបញ្ជាក់បំភ្លឺ ខ្ញុំមិនចូលទៅដល់ចំណុចនេះទៀតទេ ប៉ុន្តែខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះនឹងទទួលយកសំណើរបស់ខ្ញុំ ហើយធ្វើឡើង-- តាមទៅតាមពេលសមស្រប។ ខ្ញុំយល់ថា លោក ឃីស៊ីងហ្គ័រ នឹងមកតំបន់នេះ ក្នុងរយៈពេលប៉ុន្មានខែទៀត។ ដូច្នេះហើយ ថាតើអង្គជំនុំជម្រះគិតថា គួរតែអញ្ជើញគាត់មកផ្តល់ជាសក្ខីកម្មដែរឬទេ? ទៅតាមការសម្រេចរបស់អង្គជំនុំជម្រះដែលវាពាក់ព័ន្ធទៅនឹងការផ្តល់សក្ខីកម្មនេះ វាអាចពាក់ព័ន្ធទៅនឹងផ្នែកទីមួយនៃសវនាការរបស់យើង ពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុនីយស្តកម្ពុជា។ សូមអរគុណ។

[១០:៥៣:០៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ លោកមេធាវីការពារក្តីរបស់លោក នួន ជា បាននិយាយអំពីករណីលោក ឃើស៊ីងហ្គ័រ ខ្ញុំចង់សុំបញ្ជាក់-- សុំឲ្យគាត់បញ្ជាក់មើល៍ ថាតើមាននៅក្នុងចំណោមឯកសារទាំង៩៥នេះ ដែរឬទេ? សូមអរគុណលោកប្រធាន។

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

អត់ទេ។ ខ្ញុំគិតថា អត់មាននៅក្នុងបញ្ជីនោះទេ។

**ប្រធានអង្គជំនុំ៖**

បានហើយបញ្ហា បើអត់ទេចប់ហើយ ពីព្រោះអង្គជំនុំជម្រះឲ្យជជែកតែរឿងឯកសារ៩៥។ បានហើយ។

ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវ៉ាស៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ក៏ដូចជាសាធារណជនទាំងក្នុងបន្ទប់សវនាការ និងក្រៅបន្ទប់សវនាការ។ ជាការពិតហើយ យើងត្រូវពិភាក្សាឯកសារទាំង៩៥នេះ។ ខ្ញុំសូមលើកជាឯកសារ គឺថាជាដុំៗតែម្តង មិនលើកមួយៗ ក្នុងចំណោមឯកសារទាំង៩៥នេះទេ។ ខ្ញុំសូមលើកវាជាផ្នែកៗតែម្តង។ ប្រសិនណាបើអង្គជំនុំជម្រះអនុញ្ញាតឲ្យនៅក្នុងរយៈពេល ៣០នាទី។ មានឯកសារមួយចំនួនដែលខ្ញុំត្រូវចំណាយពេលច្រើនគឺ ឯកសារ D177/3.1 នេះគឺជាឯកសារថ្ងៃទី១៦ ខែកុម្ភៈ ជាការជំទាស់ទៅនឹងដីកាដំណោះស្រាយទាក់ទងទៅនឹងៗចលនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង។ ទាក់ទងទៅនឹងពេលពេលវេលាដែលត្រូវបានរៀបចំឡើងដោយ ក.ស.ព ដែលឯកសារនេះ M-O-O-R-E ខ្ញុំគិតថា គាត់ទៅឈប់ធ្វើការជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញាទៀតហើយ។ នៅពេលដែលបានលើកឡើងនៅពេលដែលលោក អៀង សារី ធ្វើដំណើរទៅក្រៅប្រទេស ហើយចង់ព្យាយាមថា តើអ្នកទាំងអស់នេះនៅពេលដែលគេបញ្ជូនទៅ ស-២១។

[១០:៥៦:១៦]

ប្រហែលជាក្របខ័ណ្ឌពេលវេលានេះ គឺថាត្រូវបានរៀបចំឡើងដើម្បីបង្ហាញថានៅពេលណានៅពេលអ្នកទាំងអស់នេះទៅនោះដោយរបស់ណា នៅពេលលោក អៀង សារី ចេញក្រៅប្រទេស។

យើងមិនបានដឹងថា តើការិយាល័យសហព្រះរាជអាជ្ញាមានការខិតខំប្រឹងប្រែងឲ្យអស់ពីចិត្តពីថ្លើមដើម្បីទទួលឯកសារមកពីប្រទេសចិន ថាតើ-- (សូមកែប្រែ) អូ.ស៊ី.អាយ.ជេ នោះបានប្រឹងប្រែងប៉ុនណាដែរដើម្បីឲ្យទទួលបានឯកសារពីប្រទេសចិន។ ដោយសារប្រទេសចិនមានយន្តហោះ និងមានសេវាហោះហើរមកកាន់ប្រទេសកម្ពុជា។ អ៊ីចឹងខ្ញុំមិនដឹងថា តើការិយាល័យសហចៅក្រមស៊ើបអង្កេតខិតខំប្រឹងប្រែងរកទាំងភស្តុតាងដោះបន្ទុក ដាក់បន្ទុកដោយរបៀបណានោះទេ? យើងខ្ញុំបានស្នើសុំថា លោក ម័រ (Moore) គួរតែត្រូវបានកោះហៅដើម្បីឲ្យផ្តល់ព័ត៌មានបន្ថែមទៅលើឯកសារនេះ ដើម្បីយកមសួរតទល់ជាមួយនឹងគាត់។

[១០:៥៧:២៣]

ប្រសិនជាណាគាត់មិនត្រូវបានហៅមកឲ្យផ្តល់ចម្លើយនេះទេ យើងខ្ញុំសូមស្នើឲ្យមានការកំណត់ពេលវេលាបន្ថែមថាតើយើងនឹងអាចរកឯកសារនេះដោយរបៀបណានោះ? ហើយបន្ទាប់មកទៀតក្រុមរបស់យើងខ្ញុំនឹងលើកឯកសារទាក់ទងទៅនឹងសារទូរលេខ នូវឯកសារពាក់ព័ន្ធទៅនឹងក្រសួងពាណិជ្ជកម្ម។ ជាពិសេសទាក់ទងទៅនឹងចំណងជើងនៃឯកសារទាំងអស់នេះ។ ការព្រួយបារម្ភចម្បងបំផុតរបស់ក្រុមយើងខ្ញុំគឺថា យ៉ាងហោចណាស់ក៏ត្រូវផ្តល់ការបញ្ជាក់ឲ្យបានច្បាស់ថាតើសារទូរលេខ និងឯកសារទាំងអស់នេះត្រូវបានគេរៀបចំឡើងដោយរបៀបណា? ហើយថាតើត្រូវទទួលយកសារទូរលេខហ្នឹងរបៀបនេះទាំងអស់ដោយរបៀបណា? គឺថាមិនត្រូវទទួលយកឯកសារទូរលេខនេះ ដោយមិនធ្វើការសាកសួរធ្វើផ្តល់សក្ខីកម្មណាមួយនោះទេ?

[១០:៥៨:៣៣]

ជាពិសេស ថានៅពេលណាទទួលបានសារទូរលេខ តើសារទូរលេខត្រូវបានគេបញ្ជូនទៅអ្នកណាម្នាក់ដោយរបៀបណា? ក្នុងនោះមានដាក់ថា “ចម្លងជូន”។ អ៊ីចឹងតើគេចម្លងជូនដោយរបៀបណា? បានទទួលដោយរបៀបណា? ហើយខាងក្រសួងពាណិជ្ជកម្មហ្នឹង គឺត្រូវតែមកសាកសួរថាតើឯកសារនេះវាពាក់ព័ន្ធដោយរបៀបណា? ខ្ញុំបានលើកឡើងកាលពីមុនរួចមកហើយ គឺការព្រួយរបស់យើងខ្ញុំថាតើយថាភាព និងភាពគួរឲ្យជឿជាក់បាននៃឯកសារនេះ គឺវាមានកម្រិតប៉ុនណា?

យើងខ្ញុំយល់ឃើញថា ឯកសារទាំងនេះ ហាក់បីដូចជាថាត្រូវបានបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជា នៅពេលនោះ គឺថាត្រូវបានខាងផ្នែកក្រសួងពាណិជ្ជកម្មនេះទទួលបាន។ ក៏ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា នឹងទទួលយកនូវការជំទាស់ទៅនឹងឯកសារណាមួយ ប្រសិនណាភាគីណា

មួយត្រូវលើកឡើងអំពីយថាភាព ឬភាពទទួលយកបាននៃឯកសារណាមួយនេះ។ ទាក់ទងទៅនឹងការសន្មតអំពីយថាភាព និងភាពគួរឲ្យជឿជាក់បាននៃឯកសារទាំងនេះ។ ហើយបន្ទុកនៃការបង្ហាញនេះគឺជាបន្ទុករបស់ភាគីនីមួយៗ។

[១១:០០:០៥]

ឯកសារមួយប្រភេទទៀតនោះគឺ ឯកសារ ស្ទីវ ហេដឌ័រ ដោយសារគាត់ជាអ្នកជួយរៀបចំធ្វើនូវដីកាបញ្ជូនរឿងទៅស៊ើបសួរ ហើយក្រោយមកគាត់ទៅធ្វើការនៅ-- ដែលនៅពេលដែលគាត់ធ្វើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ ហើយយើងខ្ញុំចង់ដឹងអំពីសុពលភាព ក៏ដូចជាយថាភាពនៃឯកសារទាំងនេះ ហើយគាត់បានធ្វើការសម្ភាសមួយចំនួន ខ្ញុំក៏ដូចជាសហភាតាខ្ញុំ អាង ឧត្តម បានលើកឡើងយ៉ាងច្បាស់ហើយថា វាមានបញ្ហាមួយចំនួនពាក់ព័ន្ធទៅនឹងការបកប្រែសំណេរនៃឯកសារទាំងនេះ។ ហើយយើងខ្ញុំយល់ឃើញថា អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចតាមសំណើរបស់ក្រុមយើងខ្ញុំដែលបានស្នើសុំនោះហើយ។ ហើយដោយយើងខ្ញុំត្រូវចង្អុលបង្ហាញថាតើមានការបកប្រែសរសេរហ្នឹងខុសនៅត្រង់ផ្នែកណានោះ។

[១១:០១:១៥]

ហើយជាពិសេសខ្ញុំយោងទៅលើឯកសារ D248/2.2 យើងខ្ញុំយល់ឃើញថា ឯកសារនេះគឺមិនមានជាភាសាអង់គ្លេសទេ នេះបើតាមការយល់ឃើញរបស់យើងខ្ញុំ ក៏ប៉ុន្តែអាចខុស។ ឯកសារ D210/2 គឺជាលិខិតមកពី ស្ទីវ ហេដឌ័រ ជូនមកការិយាល័យសហចៅក្រមស៊ើបអង្កេត។ នេះអាស្រ័យទៅលើអង្គជំនុំជម្រះជាអ្នកសម្រេចថាតើគួរទទួលយកលិខិតនេះដោយរបៀបណានោះ។ ប៉ុន្តែនិយាយដោយស្មោះទៅ គឺការទំនាក់ទំនងបែបនេះ វាជាប្រភេទនៃឯកសារមួយ ដែលលោក លោកស្រីចៅក្រមជាចៅក្រមវិជ្ជាជីវៈ ដែលត្រូវយកមកពិចារណា។

ខ្ញុំឥឡូវនេះកំពុងតែថ្លឹងថ្លែងចំពោះការជំទាស់របស់យើងខ្ញុំ។ ថ្លឹងថ្លែងឲ្យបានត្រឹមត្រូវថាត្រូវជំទាស់ដោយរបៀបណានោះ។ ហើយមានការសម្ភាសជាមួយលោក អៀង សារី ដែលមាននៅក្នុងសំណុំរឿង គឺឯកសារ D29 ។ គឺជាឧបសម្ព័ន្ធ៣៩ D366/7/1.5 ឯកសារពីរដំបូងនេះ គឺជាឯកសារដូចគ្នាតែម្ដង គឺជាឧបសម្ព័ន្ធ D29/01 ហើយនិងឯកសារ D29/I.03 គឺជាកំណត់ហេតុដែលសរសេរដោយដៃ។ ខ្ញុំសូមដកស្រង់សម្ដីៈ“សម្រាប់ការប្រើប្រាស់តែផ្ទៃក្នុងប៉ុណ្ណោះ”។ សូមបញ្ចប់ការដកស្រង់។ នៅក្នុងខែឧសភា ឆ្នាំ២០០០។ ហើយសូមដកស្រង់សម្ដីមួយទៀត គឺជាកំណត់ត្រាដោយដៃដែរ គឺជា

កំណត់ត្រាដោយ SH ភ្នំពេញ។ យើងខ្ញុំជឿថា គឺជាសំណោររបស់ ស្ដេហ្វិន ហេដឌ័រ នេះហើយ។

[១១:០៣:៥០]

ឯកសារមួយប្រភេទទៀតដែលខ្ញុំត្រូវលើកឡើងនោះ គឺឯកសាររបស់ ឌុច។ ដូច្នេះ ខ្ញុំសូមស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកនូវសារណាមួយចំនួនរបស់យើងខ្ញុំ ដែលខ្ញុំបានដាក់ជូនហើយ។ ដូច្នេះជំហររបស់ក្រុមយើងខ្ញុំគឺច្បាស់ហើយ។ ពីដំបូងនោះ គឺថាយើងមានការដាក់នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០១ (ស៊ីក) ដែលយើងខ្ញុំបានបញ្ជាក់ថា តើ ឌុច គួរតែនាំខ្លួនមកផ្ដល់សក្ខីកម្មក្នុងឋានៈជាសាក្សីដែរឬយ៉ាងណា? តើត្រូវនាំខ្លួនគាត់មកសួរតទល់ក្នុងនាមជាសាក្សីមួយជាទៀងទាត់ឬយ៉ាងណា? នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១។ បើសិនណាជាគាត់ត្រូវបានកោះហៅមក គាត់ត្រូវតែស្បថក្នុងឋានៈជាសាក្សី។

ប៉ុន្តែនៅក្នុងខែមេសា ថ្ងៃទី២៦ មេសា ២០១១ យើងខ្ញុំបានដាក់នូវសំណើមួយទៀត សំណើមួយដែលមានមុខព្រួញពីរ ដែលយើងខ្ញុំយល់ឃើញថា សហព្រះរាជអាជ្ញា ក៏ដូចជាអង្គជំនុំជម្រះបានរកឃើញថា ឌុច គឺថានៅពេលដែលគាត់បានផ្ដល់សក្ខីកម្មនៅក្នុងរឿងក្ដីរបស់គាត់ផ្ទាល់នោះ មានន័យថាយ៉ាងដូច្នេះ។ គាត់អាចនិយាយការពិតក៏ថាបាន ឬក៏គាត់អាចផ្ដល់នូវសក្ខីកម្មក្លែងក្លាយក៏ថាបាន។

[១១:០៥:៥០]

នៅត្រង់ចំណុចនេះ យើងខ្ញុំបញ្ជាក់ថា ដោយសារតែទាំងការិយាល័យសហព្រះរាជអាជ្ញា ក៏ដូចជាអង្គជំនុំជម្រះបានលើកឡើងហើយថា វាគឺថាត្រូវអាស្រ័យតែមេធាវីការពារក្ដីនោះទេ ដែលថាតើផ្នែកណានៃសក្ខីកម្មរបស់ ឌុច នោះ ដែលនាំ-- អាចនាំឲ្យអង្គជំនុំជម្រះយល់ខុសនោះ។ ប៉ុន្តែយើងខ្ញុំមិនបានទទួលចម្លើយពីខាងការិយាល័យសហព្រះរាជអាជ្ញានោះទេ។ បើទុកតែការិយាល័យសហព្រះរាជអាជ្ញាបានបញ្ជាក់ថា ខ្លួននឹងមិនស្វែងរកព័ត៌មានណាមួយពី ឌុច ទេ បើសិនណាជា ឌុច ត្រូវបានកោះហៅមកផ្ដល់ចម្លើយក្នុងឋានៈជាសាក្សី។ ដោយសារថា បើសិនណាជា ឌុច មិនបានផ្ដល់-- បើខ្លួនយល់ឃើញថា ឌុច ផ្ដល់ចម្លើយដោយស្មោះត្រង់កាលពីពេលមុននោះទេ។

[១១:០៦:៣៤]

ជាពិសេសនៅក្នុងសារណាដាក់លាក់នេះ យើងខ្ញុំយល់ថា ខ្ញុំបានទទួលចម្លើយពីអង្គជំនុំជម្រះថាគ្មានចម្លើយណាមួយរបស់គាត់នោះ ដោយសារថា ឌុច បានផ្ដល់ចម្លើយជាច្រើននៅក្នុងសវនាការជំនុំជម្រះរឿងក្ដីរបស់គាត់ ដែលថាមិនគួរយកចម្លើយចំណុចណាមួយមកប្រើប្រាស់ដោយមិនហៅ ឌុច មិនកោះហៅ ឌុច មកឲ្យផ្ដល់ មកធ្វើការសាកសួរដេញដោលនោះទេ។ នេះដោយសារថា-- នេះដោយសារ

តែគាត់ទទួលការផ្តន្ទាទោសហើយ ហើយពីមុនផ្តន្ទាទោសនោះ គឺថាសវនាការរបស់ ឌុច មិនមែនជាចាត់ទុកថាជាសវនាការនោះទេ នៅក្នុងប្រព័ន្ធស៊ីវិលនោះ។ យើងអាចហៅថា ជាការដោះដូរទៅនឹងការសារភាព ដោយសារថាជនជាប់ចោទនាពេលនោះទទួលសារភាព ហើយព្យាយាមបង្កើតអង្គហេតុដើម្បីគាត់ទទួលសារភាពថា គាត់មានពិរុទ្ធភាព។ ប៉ុន្តែវាមានការច្របូកច្របល់ ថាតើការសារភាពរបស់គាត់ហ្នឹងវាយ៉ាងម៉េចដែរ? ហេតុអីបានជាចំណុចនេះវាមានសារៈសំខាន់?

[១១:០៧:៥២]

យើងខ្ញុំសូមលើកឡើងថា នៅពេល ឌុច ផ្តល់នូវសក្ខីកម្មទាំងអស់នេះទៅដល់ ក.ស.ច.ស នោះគឺយើងខ្ញុំថា ទាំងការិយាល័យសហព្រះរាជអាជ្ញា ក៏ដូចជាអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ហើយថាគឺគាត់អាចនឹងមិនផ្តល់ចម្លើយគួរឲ្យជឿជាក់បានប៉ុន្មាននោះទេ។ បើអ៊ីចឹង ឌុច ខ្លួនឯង គឺថាដើម្បីឲ្យទទួលបានការផ្តន្ទាទោសមួយសមស្របសម្រាប់ខ្លួនឯង គឺគាត់ព្យាយមបង្កើតនូវចម្លើយ ដើម្បីធ្វើឲ្យអង្គជំនុំជម្រះមានការយល់ច្រឡំ យល់ខុស ដោយការគាត់ទម្លាក់កំហុសទៅលើអ្នកដទៃ។

អ៊ីចឹងយើងខ្ញុំជឿជាក់ថា គាត់គឺជាសាក្សីមួយដ៏សំខាន់។ ចម្លើយទាំងឡាយណាដែលគាត់បានផ្តល់កាលនោះនោះ គឺថាមិនគួរទទួលយកភ្លាមនោះទេ។ លើកលែងតែភាគីមានឱកាសសួរគាត់ សួរតទល់ចំពោះរូបគាត់ ហើយគាត់ត្រូវតែផ្តល់សម្បថសិន។ ទីមួយ គឺដើម្បីធានាថា គាត់ គឺគាត់មក បើគាត់ចូលខ្លួន គាត់ត្រូវតែស្បថ ហើយមិនគួរទទួលយកចម្លើយណាមួយដោយមិន-- ដែលគាត់ទទួលស្គាល់ថាគាត់គឺថាមិនបានផ្តល់ចម្លើយដោយស្មោះត្រង់ទាំងអស់ទេ។ ដូច្នេះ យើងខ្ញុំសូមជំទាស់ចំពោះការទទួលយកចម្លើយណាមួយដាក់ក្នុងសំណុំរឿង ដោយមិនហៅ ឌុច មកឲ្យផ្តល់សក្ខីកម្មនោះទេ។

[១១:០៩:២១]

អ៊ីចឹងឯកសារមួយប្រភេទទៀតនោះ គឺពាក់ព័ន្ធទៅនឹងចម្លើយសារភាពនៅមន្ទីរស-២១។ ចំណុចនេះក៏បានលើកឡើងកាលពីមុនរួចមកហើយដែរ មានចម្លើយសារភាពមួយនៅក្នុងបញ្ជីនៃចម្លើយសារភាពគឺ IS5.30។ យើងខ្ញុំមានជំហរច្បាស់លាស់ហើយថា ដើម្បីឲ្យវាមានភាពស៊ីសង្វាក់គ្នា គឺថាចម្លើយសារភាពមិនគួរយកមកប្រើប្រាស់នៅក្នុងតុលាការនេះទេ ពីព្រោះមានផ្នែកខ្លះនៅក្នុងចម្លើយសារភាពអាចត្រូវបានយកមកប្រើប្រាស់ ដើម្បីបង្ហាញថា អ្នកណាម្នាក់មានវត្តមាននៅស-២១ និងដើម្បីបង្ហាញអំពីដំណើរការនៃការទទួលបានចម្លើយសារភាព នៅពេលដែលយើងពិនិត្យមើលទៅលើខ្លឹមសារនៃចម្លើយសារភាពទាំងនេះ។

តាមការបង្ហាញរបស់ក្រុម អៀង សារី គឺយើងខ្ញុំថា បើសិនណាជាយកចម្លើយសារភាពណាមួយមកប្រើប្រាស់ មេធាវីការពារក្តីសូមរក្សាជំហររបស់ខ្លួនថាត្រូវតែមានឱកាសសួរចម្លើយ ឌុច សិនថាតើវាមានការពាក់ព័ន្ធ ហើយវាចាំបាច់ដែរឬក៏អត់?

អ៊ីចឹងប្រសិនណាយើងទទួលយកចម្លើយសារភាពទាំងនេះមកប្រើប្រាស់ គឺយើងផ្តល់ទម្ងន់ទៅនឹងចម្លើយសារភាពណាដែលវាស្របទៅនឹងយុត្តិសាស្ត្រអន្តរជាតិតែប៉ុណ្ណោះ គឺយុត្តិសាស្ត្រអន្តរជាតិដែលយកចម្លើយសារភាពមកប្រើប្រាស់។ ខ្ញុំគិតគឺថានេះ គឺមិនមែនពាក់ព័ន្ធតែនឹងសម្រាប់ការិយាល័យសហព្រះរាជអាជ្ញាទេ គឺទាំងអង្គជំនុំជម្រះក្នុងការសម្រេចទៅលើចំណុចទាំងនេះផង។

[១១:១១:១៥]

មួយទៀតគឺ ការស្តាប់ចម្លើយសាក្សីដែលមិនមែនធ្វើឡើងដោយតែការិយាល័យសហព្រះរាជ--សហចៅក្រមស៊ើបអង្កេតនោះទេ។ ទោះបីជាការសម្ភាសដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតក៏ដោយ ក៏វាគួរ មិនគួរឲ្យជឿជាក់បានទាំងស្រុងនោះដែរ ដោយសារតែវាគ្រាន់តែជាសេចក្តីសង្ខេបតែប៉ុណ្ណោះ គឺមិនមែនជាការសម្ភាសទាំងស្រុងនោះទេ។ ដូចដែលខ្ញុំបានប្រើប្រាស់ហើយថា តើវិធីសាស្ត្រអីខ្លះដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានយកមកប្រើប្រាស់ដើម្បីប្រើប្រាស់ ដែលមានគុណវុឌ្ឍិដូចគ្នាទៅនឹងអ្វីដែលប្រើប្រាស់នៅកម្រិតអន្តរជាតិនោះ។

បើសិនណាជាអ្នកណាម្នាក់មិនត្រូវបានសម្ភាសដោយ ក.ស.ច.ស ទេ គឺមិនទទួលយកចម្លើយសារភាពនោះភ្លាមទេ ល្គឹកណាតែសាក្សីណាមួយដែលត្រូវបានស្តាប់ចម្លើយនេះ គឺត្រូវបានកោះហៅមកឲ្យធ្វើការសួរដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ។ នេះគឺជាជំហររបស់ក្រុមយើងខ្ញុំ។

[១១:១២:៣៧]

ទាក់ទងទៅនឹងបញ្ជីឯកសារនេះឯង គឺមានខ្សែវីដេអូ យើងខ្ញុំទុកសិទ្ធិឲ្យអង្គជំនុំជម្រះប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការសម្រេចទៅលើខ្សែវីដេអូនេះ។ ពីព្រោះខ្សែវីដេអូ ជួនកាលវាអាចធ្វើឲ្យមានការយល់ខុស យល់ច្រឡំទាក់ទងទៅនឹងការជ្រើសរើសប្រធានបទណាមួយ។ ប៉ុន្តែយើងខ្ញុំក៏យល់ផងដែរថា ខ្សែវីដេអូនេះ គឺវាអាចមានសារប្រយោជន៍ ហើយអង្គជំនុំជម្រះ គឺថាមានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយនៅពេលពិចារណាទៅលើបញ្ហាខ្សែវីដេអូនេះ។ ដូច្នេះ ក្រុមយើងខ្ញុំទុកបញ្ហានេះជូនទៅឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់អង្គជំនុំជម្រះ ដើម្បីពិចារណាទៅលើបញ្ហាខ្សែវីដេអូនេះ។

[១១:១៣:៣៥]

ឯកសារមួយប្រភេទទៀត យើងហៅថា ឯកសារហ្វីប៊ីស “F-B-I-S”។ នៅលើបញ្ជីឯកសារនេះ មានឯកសារមួយ D262.3 មានការពិភាក្សាទៅលើឯកសារនេះពីមុនមកហើយ ទាក់ទងទៅនឹងរបាយ-ការណ៍នៃប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិនេះ គឺនិយាយអំពីឯកសារដែលបង្កើតឡើងដោយ សេ.អ៊ី.អា ដែលយើងគិតថា វាភស្តុតាងដ៏សំខាន់ ដោយសារគេយល់ឃើញថា ភ្នាក់ងារ ស៊ី.អាយ.អេ គឺថាបានធ្វើការយ៉ាងល្អ។

[១១:១៤:៣១]

ឥឡូវបើសិនណាជាអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វាជាការចាំបាច់ត្រូវទទួលយកនូវរបាយការណ៍របស់ហ្វីប៊ីសនេះ យើងខ្ញុំសូមស្នើសុំឲ្យអង្គជំនុំជម្រះមិនទទួលយកភ្លាមទេ លើកលែងតែខ្លឹមសារនៃរបាយការណ៍នេះ គឺថាវាបញ្ជាក់ច្បាស់លាស់ ឬក៏ស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងភស្តុតាងដទៃទៀត។ គឺបើសិនណាយើងចាត់ទុកថា វាជាភស្តុតាងដោយប្រយោល *អេវីឌិន* ភស្តុតាងដោយប្រយោលបែបនេះ ភស្តុតាងដោយប្រយោលនៅក្នុងប្រព័ន្ធ-- ពាក្យ-- គឺហៅថាពាក្យចចាមអារ៉ាមនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល គឺៗគេអាចច្រានចោលក៏បានដែរ គឺចៅក្រមមិនចាំបាច់ទទួលយកវាទេ ល្គឹកណាតែភស្តុតាងបែបនេះត្រូវបានរៀបចំ ឬក៏ចេញឡើងដោយឯករាជ្យ។ ដូច្នេះ យើងខ្ញុំសុំស្នើថា ឲ្យប្រើប្រាស់វិធីដូចគ្នា មុននឹងទទួលយកឯកសារនេះ។

ខ្ញុំមិនមែនដាក់បន្ទុកលើកបញ្ហាតែប្រព័ន្ធច្បាប់ស៊ីវិលយកមកអះអាងនោះទេ គឺខ្ញុំសូមទុកឱកាសនេះជូនសមត្ថភាពរបស់ចៅក្រមវិជ្ជាជីវៈរបស់អង្គជំនុំជម្រះជាអ្នកសម្រេច។

[១១:១៥:៥៨]

ឯកសារមួយប្រភេទទៀត គឺទង់បដិវត្ត D ឯកសារ D243/2.1.19 ឯកសារនេះក៏បានពិភាក្សាដែរ ថាតើវាជាឯកសារពិតប្រាកដ ដោយគិតតាំងពីពណ៌ទង់ គិតតាំងពីពណ៌ក្រដាសជាដើម។ ជារួមគឺយើងខ្ញុំយល់ឃើញថា គឺឯកសារដើមនៃទង់បដិវត្តគឺជាភស្តុតាងដ៏រឹងមាំបំផុត។ វាអាចមានសារ-ប្រយោជន៍ដើម្បីយកមកបង្ហាញជូន ប្រសិនណាជាត្រូវទទួលយកឯកសារទង់បដិវត្តនេះ។

យើងខ្ញុំក៏ឃើញថា វាជាវិធីសាស្ត្រដ៏ល្អប្រសើរដែរ ដែលថាឯកសារជាផ្លូវការនេះ គឺជាឯកសារដែលមានប្រយោជន៍បំផុតមិនចង់ឲ្យមានការបង្កើតនូវប្រវត្តិណាមួយ ឬក៏បង្កើតបំភ្លើសនៃផ្នែកណាមួយនោះទេ។

[១១:១៧:០៣]

ជំហររបស់យើងខ្ញុំគឺថា បើសិនណាជាឯកសារទង់បដិវត្តត្រូវទទួលយក គឺអង្គជំនុំជម្រះត្រូវពិចារណាឲ្យបានហ្មត់ចត់ និងត្រូវគិតថាតើឯកសារនេះវាត្រូវមានទម្ងន់ប៉ុនណា ហើយយើងខ្ញុំក៏សុំស្នើផងដែរថា ឯកសារនេះដំបូងគឺត្រូវតែចាត់ទុកក៏ជាពាក្យចចាមអារ៉ាមអ៊ីចឹងដែរ។ បើសិនណាជាភស្តុតាងចចាមអារ៉ាមនេះ វាអាចបំភ្លើស ឬក៏ត្រូវតែទទួលចម្លើយពីសាក្សី ឬក៏ពីឯកសារណាមួយថាតើឯកសារទង់បដិវត្តនេះ វាមានទម្ងន់ប៉ុនណា? អង្គជំនុំជម្រះត្រូវផ្តល់ទម្ងន់ទៅឯកសារនេះប៉ុនណា? ដោយសារថា តាមជំហររបស់យើងខ្ញុំនេះ គឺអង្គជំនុំជម្រះប្រើប្រាស់ឯកសារថតចម្លង ហើយយើងក៏មានសវនាការដែលនិយាយគ្នាទៅលើភាពទទួលយកបាននៃឯកសារនេះផងដែរ។

[១១:១៨:២២]

ទាក់ទងទៅនឹងកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ មានឯកសារ D248/6.1.6 ឯកសារនេះ គឺក៏វាមិនខុសគ្នាទៅនឹងឯកសារទង់បដិវត្តដែរ។ យើងខ្ញុំបានដឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពីមុនដែលបានបង្ហាញនូវឯកសារមួយចំនួនដែលវាខ្វះយថាភាព តែឯកសារទាំងនេះត្រូវបានទទួលយកហើយ ប៉ុន្តែជំហររបស់យើងខ្ញុំគឺថាបើទុកជាឯកសារទាំងអស់នេះអាចទទួលយកបានក៏ដោយ ក៏មិនគួរទទួលយកដោយជាស្វ័យប្រវត្តិដោយមិនមើលទៅលើខ្លឹមសារនៃកំណត់ហេតុនៃកិច្ចប្រជុំនេះ ដោយមិនមានគេហៅថាការពិនិត្យទៅលើយថាភាពដោយឯករាជ្យរបស់ឯកសារភាព ឯកសារនេះដែរ។

អ៊ីចឹងត្រូវពិនិត្យមើលថាតើខ្លឹមសាររបស់ឯកសារនេះគួរឲ្យជឿជាក់បានឬក៏អត់? និយាយអ៊ីចឹងខ្ញុំក៏ត្រូវតែចាត់ទុកថា ឯកសារបែបនេះក៏ជាភស្តុតាងបែបចចាមអារ៉ាមដែរ។ បើពិចារណាឯកសារនេះជាឯកសារផ្លូវការ គឺដោយសារតែឯកសារត្រូវបាន ក.ស.ច.ស ពិនិត្យហើយ យ៉ាងណានោះ គឺយើងខ្ញុំសុំជំទាស់ទៅនឹងឯកសារនេះ គឺថាអាចទទួលយកបាន ប៉ុន្តែត្រូវគិតពិចារណាទៅលើទម្ងន់នៃឯកសារនេះតែម្តង។

ខ្ញុំសូមអភ័យទោសពីអង្គជំនុំជម្រះផង ក្នុងករណីដែលខ្ញុំលើកឡើងដដែលៗទៅលើឯកសារនេះ។

[១១:២០:១២]

ឯកសារមួយប្រភេទទៀតនោះ គឺឯកសារដែលមិនបានបកប្រែជាភាសាផ្លូវការរបស់តុលាការទាំងស្រុងនៅឡើយទេ។ ខ្ញុំមិនមែនជាអ្នកនិយាយភាសាអាល្លឺម៉ង់ នោះទេ ប៉ុន្តែខ្ញុំដឹងថាឯកសារនេះឯកសារ D359/1/1.41 និងឯកសារ D359/1/1.1.44 យើងខ្ញុំជឿជាក់ថា ឯកសារនេះជាភាសា

អាល្លឺម៉ង់។ អ៊ីចឹងបើត្រូវយកឯកសារមកប្រើប្រាស់ ឯកសារនេះត្រូវតែបកប្រែជាភាសាផ្លូវការដើម្បីផ្ដល់ឱកាសឲ្យក្រុមមេធាវីការពារក្ដីធ្វើការជំទាស់តវ៉ា។

ខ្ញុំយល់ឃើញថា ភាគីដែលអាចរកបាននូវអ្នកចេះនិយាយភាសាអាល្លឺម៉ង់ ឬក៏យ៉ាងណានោះ គឺយើងខ្ញុំសូមយល់ឃើញថា យើងខ្ញុំមិនមានធនធានខាងផ្នែកភាសានេះទេ។ តែយ៉ាងខ្ញុំយល់ឃើញថា ឯកសារនេះទាន់បានបកទៅជាភាសាបារាំង ខ្មែរ និងអង់គ្លេស នៅឡើយទេ។ យើងនៅនេះយើងសង្ឃឹមថា អង្គជំនុំជម្រះក៏នឹងអាចយល់ឃើញថា នេះជាកំហុសមួយដ៏សាមញ្ញបំផុតទាក់ទងទៅនឹងបញ្ហាឯកសារនេះ។

[១១:២១:៥៨]

ឯកសារមួយប្រភេទទៀត គឺសេចក្ដីថ្លែងការណ៍របស់លោក អៀង សារី E2/19.1។ ឯកសារមួយប្រភេទទៀត យើងហៅថា សុន្ទរកថា គឺរួមមានសុន្ទរកថារបស់ ប៉ុល ពត នៅទិវានៃកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជាលើកទី១០ D108/28.168។ ខ្ញុំសូមទុកឲ្យអង្គជំនុំជម្រះប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីពិចារណាទៅលើទម្ងន់នៃឯកសារប្រភេទសុន្ទរកថានេះ ខ្ញុំបានលើកឡើងកាលពីមុនរួចមកហើយ។

[១១:២២:៥៨]

សុន្ទរកថាមួយទៀត គឺ D56/Doc/10/03 គឺទាក់ទាក់ទៅនឹងពិធីទទួលភោជនីយអាហារបាយល្ងាចដែលរៀបចំឡើងសម្រាប់ប្រតិភូ ដានីញ៉ែល ប៊ុនស្ដីន (Daniel Burstein) ដែលខ្ញុំមិនមានភាពគួរឲ្យជឿទុកចិត្តបាន រកឃើញនូវភាពគួរឲ្យជឿទុកចិត្តបានលើឯកសារនេះទេ។ ឯកសារនេះបង្កើតឡើងដោយ ដែល ដានីញ៉ែល ប៊ុនស្ដេន (Daniel Burstein) នេះ គាត់បានមកប្រទេសកម្ពុជា ប្រហែលជាក្នុងខែមេសា នៅក្នុងឬក៏ ប្រហែលជាក្នុងខែមេសា ១៩៧៨។ យើងខ្ញុំសូមជំទាស់ចំពោះការទទួលយកនូវសុន្ទរកថានេះ លើកលែង តែមានការរកឲ្យឃើញនូវយថាភាពដែលគួរឲ្យទទួលយកបាន។

ដូច្នេះ យើងខ្ញុំស្នើសុំឲ្យកោះហៅឲ្យ ប៊ុនស្ដេន នេះមកធ្វើជាសាក្សី ដោយសារនៅពេលនោះ គាត់យល់ឃើញថាជាអ្នកធ្វើដំណើរមួយដែលមានការឃោគយល់ទៅដល់ប្រទេសដែលកាន់លទ្ធិកុម្មុយនីស្ដ។ ដូច្នេះយើងយល់ យើងអាចមើលទៅលើគេហទំព័រអ៊ីចឹង យើងអាចនឹងឃើញហើយ។ ដូច្នេះ យើងថាបើសិនណាសុន្ទរកថាបែបនេះត្រូវទទួលយក យើងខ្ញុំសូមស្នើឲ្យអង្គជំនុំជម្រះមេត្តាកោះហៅបុគ្គល ប៊ុនស្ដេន នេះគឺថាមកធ្វើជាសាក្សី។

[១១:២៥:០០]

ឯកសារបន្ទាប់មួយទៀត យើងចាត់ទុកជាឯកសាររបស់ណាតូ។ ឯកសារ D199/26.2.174 មានចំណងជើងថា "ការវិវត្តន៍នយោបាយថ្មីៗនៅក្នុងប្រទេសកម្ពុជា"។ យើងខ្ញុំជឿជាក់ថា ជាឯកសារដែលមានជាភាសាបារាំង។ យើងខ្ញុំក៏មិនជំទាស់ចំពោះការទទួលយកឯកសារនេះដែរ បើសិនណាជាមិនទាន់រកនូវយថាភាពរបស់ឯកសារនេះទេ។ ដូច្នេះបើអង្គជំនុំជម្រះទទួលយកឯកសារនេះ យើងខ្ញុំសូមស្នើសុំថា ត្រូវពិចារណាទៅលើខ្លឹមសារនេះ ថាតើវាស៊ីសង្វាក់គ្នាដោយឯករាជ្យដែរឬក៏អត់នោះ?

បន្ទាប់មកយើងមានសំណុំឯកសារមួយសំណុំទៀត ដែលយើងហៅថាជា "សេចក្តីថ្លែងការណ៍របស់កម្ពុជាប្រជាធិបតេយ្យ" ដែលក្នុងនោះរួមមានឯកសារ D108/43/7 វាជាសេចក្តីថ្លែងការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ថ្លែងជូនកងទ័ពកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនដែលត្រូវបានឈ្លានពានដោយកងទ័ពវៀតណាមមកលើរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានថ្លែងឡើងដោយគណៈប្រធានរដ្ឋខៀវ សំផន។ ហើយបន្ទាប់មកមានឯកសារ D108/43/9 ជាសេចក្តីថ្លែងការណ៍ដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះនិយាយអំពីប្រទេសកម្ពុជាកាត់ផ្តាច់ទំនាក់ទំនងជាមួយនឹងវៀតណាមចុះថ្ងៃទី០៣ ខែមករា ឆ្នាំ៧៨។

[១១:២៧:១៨]

ហើយឯកសារ D5356-Doc2036 ជាសារាចរសេចក្តីណែនាំរបស់សភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យ និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជូនចំពោះរណសិរ្សស្នេហាជាតិនៃការបង្រួបបង្រួមជាតិកម្ពុជា។ ដូច្នេះ យើងយល់ឃើញថា ទាំងអស់នេះជាសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ យើងខ្ញុំសូមលើកឡើងថា ប្រសិនបើទទួលយកនោះ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងទទួលយកនោះ ទម្ងន់គួរតែមានលក្ខណៈតិចតួចតែប៉ុណ្ណោះ លើកលែងតែមានតម្រុយឬសញ្ញាបញ្ជាក់ឯករាជ្យណាមួយអាចបង្ហាញឲ្យយើងឃើញទាំងអស់គ្នា។

[១១:២៨:១៦]

ប្រភេទឯកសារមួយទៀត យើងហៅថាជាសារព័ត៌មាន សេចក្តីថ្លែងការណ៍នៅក្នុងសារព័ត៌មាន ឯកសារ D356-Doc 066 ជាសារព័ត៌មានអន្តរជាតិ ជាគម្រប់ខួបលើកទីប្រាំបួន នៃការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា D29 ឯកសារភ្ជាប់៨៦ នួន ជា គាត់បដិសេធអំពីការវាយប្រហារមកលើ-- បដិសេធអំពីតួនាទី ដែលក្នុងនោះវាពាក់ព័ន្ធទៅនឹងឯកសារលេខ 230707 សេចក្តីថ្លែងការណ៍នេះមិនមានភាព

ទុកចិត្តបាននោះទេ ប្រសិនបើលោក លោកស្រីចៅក្រមទទួលយកនោះ យើងគួរតែរកតម្រុយជឿជាក់ឯករាជ្យមួយយកមកបង្ហាញ។

[១១:២៩:២៣]

គឺខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមអនុគ្រោះបន្តិច ដោយសារខ្ញុំមានឯកសារដទៃទៀត។ ឯកសារមួយទៀតគឺ អឹម.អេហ្វ.អេ (MFA) ដែលជាឯកសារនៅក្នុងស្ថានទូត។ វាទំនងជារដ្ឋ-- ក្រសួងការបរទេសជាមួយនឹងទូតនៅប្រទេសថៃអាចមានឯកសារមួយចំនួន ដែលឯកសារនោះស្ដីអំពីការតាមដានវិទ្យុផ្សាយព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះគេព្យាយាមស្ដាប់នូវអ្វីដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ដូចនៅសព្វថ្ងៃអ៊ីចឹង យើងដឹងអំពីព្រឹត្តការណ៍ដែលកើតឡើងនៅប្រទេសខាងជើង យើងព្យាយាមមើលទូរទស្សន៍ ឬក៏ស្ដាប់វិទ្យុ ថាតើមានន័យយ៉ាងម៉េចនៅកូរ៉េខាងជើងនោះ? យើងឃើញមានឯកសារមួយចំនួនទៀត ដែលខ្ញុំនឹងព្យាយាមអានឯកសារ ដែលខ្ញុំនឹងអានឯកសារ ដើម្បីឲ្យយើងមានដាក់ចូលក្នុងបញ្ជី ក៏ប៉ុន្តែជំហររបស់យើងខ្ញុំគឺដូចតែគ្នា។ យើងយល់ថា ទាំងអស់នេះគឺជាឯកសារដែលបានបង្កើតឡើងដោយក្រសួងការបរទេសបារាំង មិនមែនចែកជូនទៅភាគីខាងក្រៅនោះទេ។ បានន័យថា គឺគេបង្កើតឡើងដើម្បីអូសទាញបុគ្គលដទៃទៀតដែលចង់ចូលរួមនៅក្នុងគោលបំណងរបស់បារាំង។

[១១:៣០:៥៧]

ដូច្នេះ យើងខ្ញុំសូមលើកឡើងថា រដ្ឋាភិបាលនៅក្នុងស្ថានភាពមួយចំនួននោះ មិនត្រូវព្យាយាមធ្វើឲ្យគេយល់ច្រឡំចំពោះខ្លួនឯងនោះទេ។ ដូច្នេះ ដូចដែលយើងឃើញអ៊ីចឹង គឺសហរដ្ឋអាមេរិកគឺគេព្យាយាមធ្វើឲ្យយើងយល់ច្រឡំនិងបដិសេធចំពោះការទម្លាក់គ្រាប់បែកនៅប្រទេសកម្ពុជា នៅពេលដែលគេចេញប្រតិបត្តិការនៅពេលនោះ។ ដូច្នេះឯកសារទាំងអស់នេះ MFA នេះគឺជាឯកសារដែលបង្កើតឡើងព្យាយាមទស្សន៍ទាយនូវអ្វីដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះ ចំពោះហេតុផលទាំងអស់នេះហើយ ឯកសារទាំងអស់នោះបានបង្កើតឡើងក្នុងលក្ខណៈសុទ្ធចិត្ត ដូច្នេះយើងមិនគួរទទួលយកនោះទេ លើកលែងតែមានតម្រុយ ឬសញ្ញាណនៃភាពទុកចិត្តបាន អាចបង្ហាញឲ្យយើងឃើញ។ យើងឃើញនិងទទួលស្គាល់ថា ព័ត៌មានទាំងអស់នោះចេញពីប្រភពគួរឲ្យជឿជាក់។ ឯកសារនេះ គឺមានលេខ D199/26.2.38។ ខ្ញុំមិនអានចំណងជើងឯកសារទេ ដើម្បីយើងសន្សំពេលវេលារបស់យើង កុំឲ្យយើងអស់ពេលវេលា លើកលែងតែអង្គជំនុំជម្រះបង្គាប់ខ្ញុំឲ្យអានចំណងជើង។ ឯកសារ D199/26.2.70,

D199/26.2.36, ឯកសារ D199/26.2.65, D199/26.2.28, ឯកសារ D199/26.2.269--2.154, D199/26.2.47, D199/26.2.43, D199/26.2.105។ ខ្ញុំអាចធ្វើការថតចម្លងនូវសំណុំបញ្ជីកឯសារទាំងអស់នេះបាន និងបញ្ជាក់ពីលេខឯកសារផង ដើម្បីជួយសម្រួលដល់ភាគីទាំងឡាយដែលគាត់មិនបាន-- កត់ត្រាមិនទាន់។

[១១:៣៣:៤៨]

បញ្ជីមួយប្រភេទទៀតដែលហៅថា សៀវភៅនិងអត្ថបទ។ នៅក្នុងសំណុំឯកសារមួយនេះគឺយើងហៅវាថា ឯកសារ D288/6.5/2.29 ដែលយើងហៅថា "ផែនការរួមគ្នាចុងក្រោយ"។ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រង់ពីរផ្នែកដាច់ដោយឡែកពីគ្នា លើលេខជើងទំព័រ ដែលលេខជើងទំព័រ ២២៤៦ ដកស្រង់ចេញពីទំព័រទី១០ លេខជើងទំព័រ៣៧៨២ ដកស្រង់ចេញពីទំព័រ៣១៣។ យើងខ្ញុំសូមទាញការចាប់អារម្មណ៍របស់អង្គជំនុំជម្រះលើចំណុចមួយចំនួន។ យើងជឿថា អត្ថបទនេះគឺបង្កើតឡើងដោយលោក ខានឹង នៅក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៥ ដល់ ៧៨ យើងមិនច្បាស់លាស់នោះទេ ប៉ុន្តែយើងគិតថាបង្កើតឡើងដោយគាត់ហ្នឹង។

[១១:៣៥:០៩]

ប្រហែលជាខាងការិយាល័យសហព្រះរាជអាជ្ញាអាចផ្តល់ជាពន្លឺទៅលើចំណុចហ្នឹង។ យើងក៏បានយល់ឃើញផងដែរថា យើងឃើញមានឯកសារពីរប្រភេទខុសគ្នា ដាច់ដោយឡែកពីគ្នានៅក្នុងលេខឯកសារដូចគ្នា ក៏ប៉ុន្តែឯកសារហ្នឹងខុសគ្នា ពីរហ្នឹងខុសគ្នា។

ដូច្នេះដើម្បីជាគោលបំណងនៃសវនាការមួយនេះ និងដើម្បីជាគោលបំណងសវនាការវគ្គក្រោយផងដែរ យើងលើកឡើងអំពីលេខជើងទំព័រ៣៧៨២ ក៏ប៉ុន្តែយើងទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះថាឯកសារនេះ មានទម្រង់ខុសគ្នាៗ ប៉ុន្តែលេខយោងដូចគ្នា។ មួយ គឺភ្ជាប់ទៅនឹងឯកសារភ្ជាប់ជាមួយនឹងសៀវភៅ ហើយមួយទៀតគឺជាការវាយដោយកុំព្យូទ័រ ដែលមានការកែប្រែខ្លះ។ ដូច្នេះឯកសារដែលវាយដោយកុំព្យូទ័រនេះ ទំនងជាសេចក្តីព្រាងនៃឯកសារ។

[១១:៣៦:១៥]

ប្រសិនបើខ្ញុំមើលទៅ ក៏មានឃើញសរសេរអក្សរខ្មែរដោយដៃនៅក្នុងហ្នឹងផងដែរ ហើយក៏មានចំណារនៅលើហ្នឹងផងដែរ។ យើងនឹងជំទាស់ទៅលើឯកសារជាក់លាក់នេះ។ លើកលែងតែយើងបានព័ត៌មានបន្ថែមពីលើហ្នឹង អ្នកណាបង្កើតឯកសារហ្នឹង រៀបចំឯកសារហ្នឹង ហើយនៅពេលដែលយើង

មានព័ត៌មានទាំងអស់នោះហើយ យើងធ្វើយ៉ាងណា អាចឲ្យយើងមានលទ្ធភាពដាក់សេចក្ដីសន្និដ្ឋានរបស់យើង។ ជាការពិតប្រសិនបើអង្គជំនុំជម្រះទទួលយកឯកសារមួយនេះ តាមឯកសារ ដោយផ្អែកទៅលើឯកសារនេះ ដោយមិនទទួលយកការបញ្ជាក់បំភ្លឺ ថាតើអ្នកណាបង្កើតរៀបចំឯកសារនេះនោះ? ដូច្នេះបើសិនជាករណីហ្នឹងមែននោះ គឺយើងខ្ញុំស្នើឲ្យផ្ដល់ទម្ងន់តិចតួចបំផុតទៅលើឯកសារមួយនេះ។

ខ្ញុំជឿថា លោក លោកស្រីចៅក្រម យើងខ្ញុំបានមកបញ្ចប់បទបង្ហាញរបស់ខ្ញុំត្រឹមនេះ លើកលែងតែមានសំណួរចង់ចោទសួរពីអង្គជំនុំជម្រះបន្ថែមទៀត ខ្ញុំមិនមានអ្វីបន្ថែមទៀតទេ។ ការបង្ហាញរបស់ខ្ញុំលើឯកសារប្រាកដជាច្បាស់ជូនអង្គជំនុំជម្រះហើយ។ សូមអរគុណច្រើន។

[១១:៣៧:៣៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ហើយជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្ដល់វេទិកាទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះនៃអង្គសវនាការទាំងមូល។ មុននឹងចាប់ផ្ដើមធ្វើបទបង្ហាញនេះ ខ្ញុំបាទសូមជម្រាបជូនថា យើងខ្ញុំមានឯកសារជាកូពី បើសិនជាភាគីណាចង់បានឯកសារដែលខ្ញុំនឹងធ្វើការបង្ហាញនេះ អាចទាក់ទងជាមួយសហការីរបស់ខ្ញុំ ដើម្បីយកទៅតាមដាន ហើយម្យ៉ាងទៀតយើងអាចថាជាការងាយស្រួលសម្រាប់ធ្វើការផ្ទៀងផ្ទាត់ជាមួយគ្នា មិនមែនជាការដាក់ជាភស្ដុតាងអីទេ។ បាទ គឺសម្រាប់ការពិភាក្សានៅពេលនេះ។

**ប្រធានអង្គជំនុំ៖**

ឯកសារនោះយ៉ាងម៉េចទៅឯកសារដែលលោកមានបំណងចែកជូនដល់ភាគីដែលមានបំណងចង់បានហ្នឹង តើនៅក្នុងចំណោមឯកសារ៩៥ ដែលអង្គជំនុំជម្រះបានកំណត់នៅក្នុងការពិភាក្សាតទល់នាពេលនេះ ឬក៏យ៉ាងម៉េច?

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន គឺឯកសារនេះយើងធ្វើទៅតាមបញ្ជីដែលអង្គជំនុំជម្រះដាក់ឲ្យ ហើយជាឯកសារដែលមានចំនួន៩៥នេះ ហើយគ្រាន់តែយើងធ្វើការបញ្ជាក់បន្ថែមចំពោះមូលហេតុនៃការបដិសេធជំទាស់របស់យើង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

[១១:៣៩:២៩]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ឥឡូវខ្ញុំបាទសូមធ្វើការបង្ហាញជាលក្ខណៈរួមអំពីមូលដ្ឋាននៃការជំទាស់របស់យើងទៅលើឯកសារទាំង៩៥នេះ។ ការពិនិត្យទៅលើឯកសារនីមួយៗ គឺជាភារកិច្ចរបស់តុលាការ ហើយចំណែកការជំទាស់របស់ភាគីទាំងឡាយគឺជាកម្មវត្ថុមួយ ដើម្បីជួយដល់អង្គជំនុំជម្រះការបំពេញកិច្ចការរបស់ខ្លួនទៅលើការសម្រេចនេះ។ ហើយជាការសំខាន់ គឺថាអង្គជំនុំជម្រះមិនត្រូវដាក់បង្ហាញនូវឯកសារដែលមានចំនួនច្រើន ហើយដែលឯកសារទាំងនោះ មិនមានតម្លៃគួរឲ្យជឿជាក់ បានន័យថា ការជឿជាក់ទៅលើឯកសារនោះ វាពុំមានមូលដ្ឋានគ្រប់គ្រាន់ ឬក៏គ្មានទាល់តែសោះ។

[១១:៤០:៤០]

ដូច្នេះ ការដាក់ជូនអង្គជំនុំជម្រះគួរតែផ្តោតទៅលើភស្តុតាងសំខាន់ៗដែលមាននៅក្នុងសំណុំរឿងនេះវិញ។ ខាងមេធាវីការពារក្តី សូមទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះថា ការកត់សម្គាល់ទៅលើជើងទំព័រដែលពាក់ព័ន្ធទៅនឹងសម្រង់នៃឯកសារណាមួយ ដែលមាននៅក្នុងជើងទំព័រនោះ គឺសូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យតែទៅលើខ្លឹមសារ ដែលចង្អុលបង្ហាញនោះតែប៉ុណ្ណោះ។ ព្រោះថាការចង្អុលបង្ហាញនៅក្នុងជើងទំព័រខ្លះ និងឈ្មោះឯកសារមួយ ដែលមានច្រើនទំព័រ ក៏ប៉ុន្តែការលើកយោងសំដៅតែទៅលើខ្លឹមសារជាក់លាក់ណាមួយ។ ឧទាហរណ៍នៅក្នុងឯកសារជាវីដេអូ ជួនកាលទៅការចង្អុលបង្ហាញឯកសារនោះ ជាវីដេអូមួយខ្សែ ប៉ុន្តែជាក់ស្តែងការចង្អុលបង្ហាញចំតែទៅលើតែ*ស៊ីហ្គុង* ណាមួយនៃវីដេអូនោះតែប៉ុណ្ណោះ អាចចាត់ទុកថា គ្រាន់តែជារូបភាពណាមួយនៃវីដេអូនោះតែប៉ុណ្ណោះ។

ដូច្នេះ ក្នុងករណីបែបនេះ គឺសូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យតែនៅលើចំណុចដែលលើកយោងនោះ គឺថាមិន-- អង្គជំនុំជម្រះមិនគួរពិនិត្យទៅលើឯកសារទាំងមូលនោះទេ។

[១១:៤២:២០]

ហេតុនេះ យោងតាមវិធាន៨៧(៣)(គ) នៃវិធានផ្ទៃក្នុង គឺថាបណ្តាឯកសារទាំងឡាយដែលយើងខ្ញុំនឹងបង្ហាញនៅពេលនេះ យើងខ្ញុំសូមបង្ហាញនូវការជំទាស់ដូចតទៅ។ នេះជាការបង្ហាញជាលក្ខណៈរួម ហើយយើងខ្ញុំនឹងបង្ហាញជាលក្ខណៈមួយៗដាច់ដោយឡែកទៀត តាមលំដាប់លំដោយ ដែលមាន

នៅក្នុងបញ្ជី ដើម្បីងាយស្រួលក្រុមប្រឹក្សាជំនុំជម្រះធ្វើការតាមដាន។

ទីមួយ គឺថាឯកសារ-- មានឯកសារដែលបង្ហាញនៅក្នុងសំណុំរឿង០០១ ដែលជាឯកសារត្រូវបានទាត់ចោទដោយក្រុមប្រឹក្សាជំនុំជម្រះក្នុងសាលាដំបូងរួចហើយ។ ដូច្នេះ ឯកសារប្រភេទនេះ មិនគួរត្រូវបានដាក់ឲ្យដេញដោលទៀតទេ។

ទីពីរ កំណត់ហេតុអះអាងនានារបស់បុគ្គលមួយចំនួនដែលធ្វើនៅក្រៅតុលាការ គឺជាប្រភេទឯកសារដែលពុំបានធ្វើការផ្ទៀងផ្ទាត់ទៅលើរបៀបនៃការធ្វើសម្ភាស ឬក៏របៀបនៃការទទួលយកនូវចម្លើយទាំងអស់នោះ ដែលខុសពីប្រព័ន្ធពីតុលាការ ដែលអាចឲ្យអ្នកដែលផ្តល់ចម្លើយត្រូវធ្វើការស្បថ ឬក៏មានការធ្វើកំណត់ត្រាច្បាស់លាស់ ដែលមិនមែនជាធ្វើការសេចក្តីសង្ខេបទៅលើចម្លើយរបស់បុគ្គលណាម្នាក់នោះ។

[១១:៥៩:២៦]

ទីបី ទាក់ទងទៅនឹងការអះអាងរបស់បុគ្គលទៅលើសកម្មភាព ឬក៏ទៅលើអាកប្បកិរិយារបស់លោក ខៀវ សំផន។ ខ្ញុំសូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក ខៀវ សំផន មានការដេញដោលចំពោះឯកសារដែលទាក់ទងទៅនឹងការបង្ហាញទៅលើសកម្មភាព ឬក៏អាកប្បកិរិយារបស់លោក ខៀវ សំផន នោះផងដែរ។

ទីបួន ទាក់ទងទៅនឹងឯកសារមួយចំនួនដែលយើងមើលទៅឃើញថា ច្បាប់ដើមត្រូវធ្វើជាភាសាខ្មែរ។ ឧទាហរណ៍ ការស្តាប់ ការផ្តល់បទសម្ភាសន៍រវាងថ្នាក់ដឹកនាំណាមួយនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលគាត់ធ្វើជាភាសាខ្មែរ។ ក៏ប៉ុន្តែពុំមានឯកសារនោះជាភាសាខ្មែរនៅក្នុងសំណុំរឿងទេ បែរជាមានតែភាសាបរទេស អាចជាភាសាបារាំង ឬជាភាសាអង់គ្លេសជាដើម។ ដូច្នេះ វាមិនអាចឲ្យយើងធ្វើការផ្ទៀងផ្ទាត់ទៅលើខ្លឹមសារថា តើអត្ថបទដើមដែរជាភាសាខ្មែរនោះមានខ្លឹមសារដូចអ្វីដែលមាននៅក្នុងភាសាបរទេសនោះដែរឬទេ?

ចំណុចទីប្រាំ គឺទាក់ទងទៅនឹងការថែរក្សាឯកសារ។ ចំណុចនេះអង្គជំនុំជម្រះបានស្តាប់ឮការជជែកជាច្រើនហើយ ហើយយើងតែងតែបដិសេធថា ឯកសារទាំងអស់នោះពុំមានការរក្សាទុកត្រឹមត្រូវដែលយើងមិនអាចដឹងអំពីខ្សែចង្វាក់នៃការរក្សាទុកឯកសារនោះ ហើយដែលសរុបសេចក្តីមក គឺឃើញវាមានចំណុចខ្សោយ ឬក៏ឯកសារទាំងអស់នោះ មិនមានមូលដ្ឋានច្បាស់លាស់ដែលអាចឲ្យយើងជឿទុកចិត្តបានទៅលើកឯកសារទាំងនោះ។

[១១:៤៧:០៧]

តទៅនេះខ្ញុំបាទសូមបង្ហាញជូននូវឯកសារទីមួយ ដែលមាននៅក្នុងបញ្ជីរបស់អង្គជំនុំជម្រះ លេខ IS18.21។ ឯកសារនេះពុំមានការបញ្ជាក់ពីខ្សែចង្វាក់នៃការថែរក្សាឯកសារនេះច្បាស់លាស់ទេ។ អ្វីដែលយើងឃើញមាននោះគឺថា ត្រឹមតែចាប់ផ្តើមពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ណសារដ្ឋានជាតិតែប៉ុណ្ណោះ គឺមានត្រឹមតែពីរ ហើយការរក្សាទុកពីមុនមកគឺមិនមានការបង្ហាញច្បាស់លាស់ថា ឯកសារត្រូវបាននោះត្រូវបានទុកដាក់យ៉ាងណា? ហើយទទួលបានពីអ្នកណា? ដោយរបៀបណា? នៅពេលណា? នោះក៏គ្មានដែរ។

ទីពីរ ឯកសារ IS19.111 ឯកសារនេះយើងខ្ញុំសូមជំទាស់ដោយមូលហេតុថា ការទទួលបាននូវឯកសារនេះក្រៅប្រព័ន្ធតុលាការ មិនមែនជាកំណត់ហេតុដែលធ្វើឡើងនៅក្នុងប្រព័ន្ធ តុលាការទេ ហើយក៏គ្មានការធានាអំពីលក្ខខណ្ឌនៃការសម្ភាសទៅឯកសារនោះដែរ។ ទីបំផុត យើងក៏ មិនអាចធ្វើការផ្ទៀងផ្ទាត់បានទេ ចំពោះឯកសារនេះ។ អ៊ីចឹង ការផ្ទៀងផ្ទាត់បានគឺមានតែម្យ៉ាងគត់ គឺត្រូវឲ្យអ្នកដែលផ្តល់ការសម្ភាសចំពោះឯកសារនេះ មានវត្តមានចំពោះអង្គសវនាការដើម្បីឲ្យយើងអាចធ្វើការសួរដេញដោលទាក់ទងទៅនឹងខ្លឹមសារទាំងឡាយដែលមាននៅក្នុងឯកសារ 19.111 នេះ។

[១១:៤៩:៤៥]

ឯកសារ 19.210 វាមានទម្រង់ប្រហាក់ប្រហែលទៅនឹងឯកសារមុនដែរ ជាសេចក្តីប្រកាសឬក៏ជាកំណត់ហេតុរបស់បុគ្គលម្នាក់ដែលធ្វើឡើងនៅក្រៅប្រព័ន្ធតុលាការ។ ក្រៅពីនេះទៀតឯកសារនេះវាបង្ហាញនូវភាពលម្អៀង ដោយសារអី? ដោយសារឯកសារនេះត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងមើលទៅឃើញថា មជ្ឈមណ្ឌលឯកសារកម្ពុជានេះ ធ្វើការប្រមូលឯកសារគឺដើម្បីតែដាក់បន្ទុកតែប៉ុណ្ណោះ។ ហើយយើងក៏មិនអាចបញ្ជាក់ទៅលើខ្លឹមសារដែលមាននៅក្នុងឯកសារនេះដែរ។ យើងមិនអាចធ្វើការផ្ទៀតផ្ទាត់បានទេ។ ហើយម្យ៉ាងទៀត អង្គជំនុំជម្រះក៏មិនមានគម្រោងនឹងនាំបុគ្គលដែលបានធ្វើសេចក្តីថ្លែងនេះមកចំពោះមុខអង្គជំនុំជម្រះដែរ។ ដូច្នេះ វាធ្វើឲ្យលោក ខៀវ សំផន មិនធ្វើការដេញដោលទៅលបុគ្គលរូបនេះបាន ដើម្បីបញ្ជាក់អំពីខ្លឹមសារនៅក្នុងឯកសារនេះ។

[១១:៥១:៣៧]

ឯកសារ IS20.19 ឯកសារនេះត្រូវបានច្រានចោលនៅក្នុងសំណុំរឿង០០១ រួចហើយ។ ហើយលក្ខខណ្ឌដែលច្រានចោលនោះ គឺមានសុពលភាពនៅឡើយ ដូចមាននៅក្នុងកំណត់លេខកូដ លេខ

សម្គាល់ឯកសារលេខ E43/4 ដែលជាសេចក្តីសម្រេចស្តីពីភាពដែលអាចទទួលយកសម្ភារៈ ដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង។ អ៎! នៅក្នុងកថាខណ្ឌទី២០។

ដូច្នេះ បើសិនជា អង្គជំនុំជម្រះចង់ឲ្យទទួលយកឯកសារនេះ គឺលោក ខៀវ សំផន ស្នើសុំឲ្យបុគ្គលដែលបានផ្តល់នូវកំណត់ហេតុនេះ ចូលមកបង្ហាញខ្លួនចំពោះមុខអង្គសវនាការ ដើម្បីយើងអាចធ្វើការសួរដេញដោល។ ហើយបុគ្គលដែលមានឈ្មោះនៅក្នុងឯកសារនេះ តាមលេខកូដរបស់អង្គជំនុំ--របស់សាលាដំបូងនៃតុលាការវិសាមញ្ញនេះ គឺមានលេខ TCW-511។

[១១:៥៣:៣៥]

មានមូលហេតុផ្សេងទៀត ទាក់ទងទៅនឹងឯកសារនេះ គឺថាសហព្រះរាជអាជ្ញាក៏បានជំទាស់នឹងការបង្ហាញខ្លួនចំពោះមុខរបស់សាក្សីនេះដែរ។ ហើយឯកសារនេះ គឺធ្វើឡើងដោយ-- ហើយតុលាការក៏មិនមានគម្រោងកោះហៅសាក្សីរូបនេះ បុគ្គលនេះមកធ្វើជាសាក្សីដើម្បីបំភ្លឺដែរ។ ដូច្នេះ វាអាចជាបញ្ហាមួយ គឺយើងមិនអាចធ្វើការសួរដេញដោលទៅលើសាក្សីនោះបាន។

ឯកសារ 21.103 ឯកសារនេះស្ថិតនៅក្នុងក្រុមនៃឯកសារជាច្រើន ដែលបញ្ជាក់ថា ជាតេឡេក្រាម ឬក៏ទូរលេខ។ តែការពិតឯកសារនោះ មិនមែនជាតេឡេក្រាមទេ វាជាឯកសារគណនេយ្យ។ អ៊ីចឹងការកំណត់ពីធាតុដើមនៃឯកសារនេះគឺខុសរួចជាស្រេចទៅហើយ។ ទីពីរទៀត ខ្សែចង្វាក់នៃការថែរក្សាឯកសារនេះក៏មិនមានលក្ខណៈច្បាស់លាស់ គឺត្រូវបានទទួលតាមរយៈមជ្ឈមណ្ឌលឯកសារ ហើយនិងបណ្ណសារដ្ឋានជាតិ។

[១១:៥៥:៤០]

ដោយឡែកទៀត យើងឃើញថា នៅលើឯកសារនេះមានចំណារសរសេរដោយដៃ ដែលយើងមិនដឹងថាជាចំណាររបស់អ្នកណាទេ។ អ៊ីចឹង វាទាមទារឲ្យមានការសួរដេញដោលបញ្ជាក់ទៅលើការសរសេរបន្ថែមទៅលើឯកសារនេះ ដើម្បីស្វែងរកនូវភាពដែលគួរឲ្យជឿជាក់បាននៃឯកសារ។ ហើយឯកសារនេះអាចត្រូវបានផ្ទួរផ្គងជាមួយនឹងសាក្សីដែលមានលេខកូដ TCW-583 ដូចស្រដៀងគ្នានេះដែរ ចំពោះឯកសារបីខាងក្រោមទៀតមានលេខ 22.104 អ៎!សូមទោស 21.104, លេខ21.110, លេខ 21.114 គឺសុទ្ធតែជាឯកសារដែលបានកំណត់ថាជាទូរលេខ ប៉ុន្តែវាមិនមែនជាសារទូរលេខទេ គឺជាឯកសារគណនេយ្យ ហើយដែលខ្ញុំបាទសូមលើកមូលដ្ឋានដើម្បីជំទាស់ដូចមាននៅក្នុងឯកសារ 21.103 ដែរ។

[១១:៥៧:៤១]

ហើយមានឯកសារជាច្រើនទៀត ដែលប្រហាក់ប្រហែលគ្នានេះ ខ្ញុំសូមអានលេខឯកសារ។ ឯកសារនេះប្រហែលជាខ្ញុំអានបន្ថែមថា IS ក៏ប៉ុន្តែនៅក្នុងឯកសារជាក់ស្តែងដែលប្រគល់ជូនដោយខាងក្រុមប្រឹក្សាជំនុំជម្រះនោះគឺពុំមានដាក់ IS ទេ បាទ ខ្ញុំបាទសូមអានតែលេខសម្គាល់តែម្តងទៅ គឺលេខ 21.109, លេខ 21.120, លេខ 21.128, លេខ 21.129, លេខ 21.131, លេខ 21.132, លេខ 21.135, លេខ 21.136, លេខ 21.137, លេខ 21.139, លេខ 21.140, លេខ 21.143, លេខ 21.144, លេខ 21.145, លេខ 21.149, លេខ 21.25, លេខ 21.27, លេខ 21.30, លេខ 21.34, លេខ 21.49, លេខ 21.72, លេខ 21.75, លេខ21.82, លេខ 21.85, លេខ 21.88, លេខ 21.89, លេខ 21.90, លេខ 21.92, លេខ 21.93, លេខ 21.95, លេខ 21.97, លេខ 21.98, លេខ D161/1.30។

បាទនេះចំពោះៗឯកសារដែលពាក់ព័ន្ធទៅនឹងការកំណត់អំពីប្រភេទនៃឯកសារថាជាតេឡេក្រាម ជាសារទូរលេខ ប៉ុន្តែវាមិនមែនជាសារទូរលេខទេ។ ខ្ញុំបាទ-- លោកប្រធានឃើញថា ម៉ោងដល់ពេលសម្រាកហើយ ខ្ញុំបាទអាចសុំអនុញ្ញាតសម្រាក ឈប់ត្រឹមនេះ ឬមួយក៏យ៉ាងណាបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ដោយសារថាឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅ--

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តី នួន ជា!

[១២:០២:២៧]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណ គឺខ្ញុំសូមឲ្យកូនក្តីរបស់ខ្ញុំទៅបន្ទប់តាមដានពីខាងក្រោមនៅពេលរសៀល។ ដូច្នេះគឺសូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់នូវសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា សូមឲ្យកូនក្តី

របស់ខ្លួនទៅបន្តការតាមដានស្តាប់កិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោម តាមរយៈប្រព័ន្ធសោតទស្សន៍ ដោយលះបង់សិទ្ធិក្នុងការចូលរួមកិច្ចដំណើរការសវនាការផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំ។ ប៉ុន្តែ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់ មកឲ្យអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់ក្នុងបន្ទប់សវនាការដោយចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។ ហើយបង្គាប់ឲ្យ សោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សំឡេង និងរូបភាពសម្រាប់ជនជាប់ចោទ នួន ជា បន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលធ្វើសវនាការនៅរសៀលនេះ។

[១២:០៣:៣២]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោម ហើយដោយឡែកនៅរសៀលនេះ បង្គាប់ឲ្យនាំខ្លួនលោក ខៀវ សំផន មកកាន់សាលសវនាការវិញឲ្យបានមុនម៉ោងមួយសាមសិបនាទី។ ដោយឡែកលោក នួន ជា គឺទុកឲ្យគាត់បន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោម ដែលរៀបចំសម្រាប់គាត់ចុះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ហើយជាបន្តនេះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការបង្ហាញនូវការជំទាស់របស់ខ្លួន ចំពោះឯកសារចំនួន៩៥ ដែលយើងបានកំណត់ក្នុងការកិច្ចពិភាក្សាកាលពីព្រឹកមិញ។ សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ សូមគោរពសាជាថ្មីចំពោះក្រុមប្រឹក្សាជំនុំជម្រះ និងអង្គសវនាការទាំងមូល។ ខ្ញុំបាទសូមធ្វើការជំទាស់តទៀត ទាក់ទងនឹងឯកសារចំនួន៩៥។ មុនពេលសម្រាកពីព្រឹកមិញ ខ្ញុំបានលើកដល់ឯកសារសារទូរលេខមួយចំនួនដែលមូលដ្ឋាននៃការជំទាស់នោះ គឺថាវាមិន

មែនជាសារទូរលេខ តែជាឯកសារគណនេយ្យ និងខ្សែចង្វាក់នៃការទុកដាក់ឯកសារនេះ វាមិនមានលក្ខណៈសមស្របដែលអាចទទួលយកបាន ហើយនិងមានចំណារដោយដៃទៅលើឯកសារនោះទៀតផង ហើយដែលតម្រូវឲ្យមានការបញ្ជាក់របស់អ្នកដែលធ្វើចំណារនោះ។

[១៣:៣៣:២៣]

តទៅទៀត ខ្ញុំបាទសូមលើកជូនថា នៅក្នុងចំណងជើងអត្ថបទដែលដូចមាននលេខសម្គាល់ ដែលខ្ញុំបាទបានអានជូនក្រុមប្រក្សាជំនុំជម្រះនាពេលនេះ គឺមិនមានដាក់ថាជាទូរលេខ ឬក៏សារទូរលេខ ឬក៏តែឡេក្រាមទេ ក៏ប៉ុន្តែនៅក្នុងដីកាដំណោះស្រាយ នៅក្នុងហ្វូតណូត របស់ដីកាដំណោះស្រាយនោះ គឺមានសរសេរនៅក្នុងហ្នឹងអំពីសារទូរលេខនេះ។ ហេតុនេះហើយបានជាខ្ញុំលើកថា វាជាមូលដ្ឋាននៃការជំទាស់ទៅលើការកំណត់នៃឯកសារនេះមិនបានត្រឹមត្រូវ ពីព្រោះវាមិនមែនជាសារទូរលេខទេ វាជាឯកសារផ្សេង។

ជាបន្ត ខ្ញុំបាទសូមធ្វើការកត់សម្គាល់បន្ថែម ទៅលើឯកសារ IS19.111 បន្ថែមទៅលើអ្វីដែលខ្ញុំបាទបានលើកថា ការស្នើសុំឲ្យមានការដេញដោលចំពោះសាក្សី ដែលបានផ្តល់បទសម្ភាសន៍នោះ គឺសាក្សី ដែលមានលេខសម្គាល់ TCW-425 គឺជាការចាំបាច់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ទៅលើបទសម្ភាសន៍ដែលសាក្សីនោះបានធ្វើកន្លងមក។ ដូច្នេះ ការនាំខ្លួនសាក្សីដែលបានជម្រាបជូនអម្បាញ់មិញនេះ ដែលមានលេខសម្គាល់អម្បាញ់មិញនេះ គឺជាការចាំបាច់ដើម្បីធ្វើការដេញដោលចំពោះសាក្សីរូបនោះ ហើយក៏ដូចជាដើម្បីផ្ទៀងផ្ទាត់ទៅលើឯកសារនេះ។

[១៣:៣៥:៤២]

តទៅទៀត ខ្ញុំបាទសូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យឯកសារ ដែលមានលេខសម្គាល់ 21.115។ មូលដ្ឋាននៃការជំទាស់ចំពោះឯកសារនេះ ក៏ដូចគ្នាដែរគឺថា ខ្សែចង្វាក់នៃការរក្សាទុកឯកសារនោះពុំមានគ្រប់គ្រាន់។ ទីពីរ នៅលើឯកសារនោះ គឺមានចំណារសរសេរដោយដៃ ដែលជាចំណោទឲ្យយើងត្រូវស្វែងរកថា អ្នកណាអ្នកសរសេរ? សរសេរនៅពេលណា? ហើយហេតុអីបានសរសេរអ៊ីចឹង? វាមានចំណោទជាច្រើនទៀត សំណួរជាច្រើនទៀត ដែលយើងត្រូវការសួរបញ្ជាក់ទៅលើអ្នកដែលបានធ្វើចំណារនេះ ឬក៏អ្នកដែលអាចដឹងពីមូលហេតុ ឬក៏ព័ត៌មាននៃការធ្វើចំណារនេះ។

ដូច្នេះចាំបាច់ ត្រូវឲ្យអ្នកដែលដឹងព័ត៌មាននោះ ឬក៏ជាអ្នកដែលបានធ្វើកំណត់សម្គាល់ទៅលើឯកសារនោះបានមកបង្ហាញខ្លួនចំពោះមុខអង្គសវនាការ ដើម្បីឲ្យលោក ខៀវ សំផន ធ្វើការសួរដេញ

ដោល។ តទៀតសូមពិនិត្យឯកសារដែលមានលេខសម្គាល់ 21.123 គឺជាប្រភេទតេឡេក្រាម ជាសារទូរលេខ ដូចគ្នាដែរ ហើយមានសរសេរដោយដៃ កំណត់សម្គាល់បន្ថែមទៅលើឯកសារនោះ ហើយដែលយើងក៏ចង់ដឹងអំពីបញ្ហាផ្សេងៗ ដែលទាក់ទងទៅនឹងចំណារដែលមាននៅលើឯកសារនោះ ហើយមធ្យោបាយដែលអាចឱ្យយើងធ្វើបាន គឺមានតែយក នាំបុគ្គលនោះមកចំពោះមុខអង្គសវនាការ ដើម្បីធ្វើការសួរដេញដោលតទល់គ្នា។

[១៣:៣៨:២៥]

ទាក់ទងទៅនឹងឯកសារបន្ទាប់ទៀតគឺ ឯកសារលេខ 5.30។ ឯកសារនេះ ក្រុមមេធាវីការពាររបស់លោក អៀង សារី បានលើកបង្ហាញជូនអង្គជំនុំជម្រះកាលពីព្រឹកមិញរួចហើយ ហើយយើងខ្ញុំសូមធ្វើការគាំទ្រចំពោះមូលដ្ឋាននៃការជំទាស់នេះ ហើយខ្ញុំបាទសុំមិនធ្វើការពន្យល់បន្ថែមទេ។ ដូចគ្នានេះដែរចំពោះឯកសារដែលមានលេខ D108/28.168។ វាជាឯកសារបកប្រែ ដែលមានតែភាសាអង់គ្លេស ហើយឯកសារនេះគួរតែធ្វើមានឯកសារដើមជាភាសាខ្មែរ ក៏ប៉ុន្តែយើងពិនិត្យមើលទៅពុំមានភាសាខ្មែរ ពុំមានឯកសារជាភាសាខ្មែរ នៅក្នុងសំណុំរឿងនេះទេ។ ដូច្នេះ វាធ្វើឱ្យយើងមិនអាចធ្វើការផ្ទៀងផ្ទាត់ទៅលើខ្លឹមសារនៃឯកសារនោះបាន។

[១៣:៤០:០៦]

ឯកសារតទៀតមានលេខសម្គាល់ D108/43/7 ជាប្រភេទឯកសារ ហ្វេស.ប៊ី.អាយ.អេស (FBIS)។ ខ្ញុំសូមកត់សម្គាល់ថា ចំពោះឯកសារនេះ យើងខ្ញុំបានធ្វើការជំទាស់ដោយមានការពន្យល់យ៉ាងច្រើន ទាក់ទងទៅនឹងសវនាការកាលពីលើមុន ដែលមានធ្វើឡើងនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២។ ដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះអាចពិនិត្យទៅមើលប្រតិចារឹកដែលមានលេខសម្គាល់ E1/27.1។

ចំពោះឯកសារ D108/43/9 គឺជាប្រភេទឯកសារបកប្រែដែរ ហើយដែលសេចក្តីថ្លែងការណ៍នោះ គួរតែធ្វើជាភាសាខ្មែរ ហើយភាសាដើមគួរតែជាភាសាខ្មែរ ក៏ប៉ុន្តែនៅក្នុងសំណុំរឿងពុំមានឯកសារជាភាសាដើមដែលជាភាសាខ្មែរនោះទេ គឺមានតែឯកសារបកប្រែ។ ដូច្នេះ យើងមិនអាចធ្វើការផ្ទៀងផ្ទាត់ ថាតើការបកប្រែនោះវាត្រឹមត្រូវកម្រិតណាបាននៅក្នុងសវនាការនេះទេ។

ចំពោះឯកសារ D121/6.2 គឺជាបទអត្ថាធិប្បាយលាយលក្ខណ៍អក្សររបស់លោក ឌុច ហើយដែលចាំបាច់យើងត្រូវការគាត់មកបង្ហាញខ្លួនចំពោះមុខអង្គសវនាការនេះដើម្បីធ្វើការតទល់ដែរ។ ពីព្រោះថាស្ថានភាពនៃការផ្តល់បទអត្ថាធិប្បាយជាលាយលក្ខណ៍អក្សររបស់គាត់ កាលពីគាត់ធ្វើនោះ យើងមិន

ដឹងថា គាត់ធ្វើក្នុងលក្ខខណ្ឌបែបណា? ហើយអាចទទួលបានក្នុងកម្រិតណា? ហើយមានស្ថានភាពអ្វីជុំវិញ ពេលដែលធ្វើបទអត្ថាធិប្បាយជាលាយលក្ខណ៍អក្សរនោះ។ ដូច្នេះ យើងទាមទារឲ្យមានការតទល់ជាមួយនឹងបុគ្គលរូបនេះ ដើម្បីផ្ទៀងផ្ទាត់ទៅលើភាពត្រឹមត្រូវនៃការធ្វើការឯកសាររបស់គាត់នាពេលនោះ។

[១៣:៤៣:៥៧]

ចំពោះឯកសារ D177/3.1 យើងខ្ញុំសូមគាំទ្រចំពោះមូលដ្ឋានបដិសេធជំទាស់ដែលលើកឡើងដោយមេធាវីការពារលោក អៀង សារី។ ឯកសារដែលមានលេខសម្គាល់ D199/26.2.105 គឺជាប្រភេទឯកសារការទូត ហើយដែលយើងមិនអាចធ្វើការផ្ទៀងផ្ទាត់បានទេ។ ការដែលមិនអាចផ្ទៀងផ្ទាត់បាននេះ ដែលជាមូលដ្ឋាននៃការជំទាស់ទៅលើឯកសារនោះ។

ក៏ដូចគ្នានេះដែរ ឯកសារ D199/26.2.143 ជាប្រភេទឯកសារបកប្រែ មិនមានឯកសារដើមជាភាសាខ្មែរទេ យើងមិនអាចធ្វើការផ្ទៀងផ្ទាត់ដើម្បីពិនិត្យទៅលើខ្លឹមសារនៃឯកសារដើមនោះបាន។ ក្នុងនេះក៏មានមូលដ្ឋានជំទាស់ដូចគ្នាដែរចំពោះឯកសារ D199/26.2.147 ដែលយើងមិនអាចធ្វើការផ្ទៀងផ្ទាត់ចំពោះឯកសារនេះបាន។

ដោយឡែកចំពោះឯកសារ D199/26.2.153 វាជាប្រភេទឯកសារតេឡេក្រាម អ្វីដែលយើងកត់សម្គាល់នៅក្នុងនេះគឺថា វាជាទំនងជាពាក្យចចាមអារ៉ាម ដែលឯកសារនោះធ្វើឡើងតៗគ្នា ការកត់សម្គាល់តៗគ្នា វាមិនមែនជាឯកសារដែលទទួលយកពីបុគ្គលដែលបានផ្តល់នូវសក្ខីកម្ម ឬក៏កំណត់ហេតុអះអាងដោយមានការបញ្ជាក់នូវលក្ខខណ្ឌត្រឹមត្រូវ ដែលអាចឲ្យតុលាការនេះទទួលយកបាននោះទេ។

[១៣:៤៧:៤៦]

មូលដ្ឋាននៃពាក្យចចាមអារ៉ាមនេះ វាធ្វើឲ្យយើងមានការលំបាកក្នុងការផ្ទៀងផ្ទាត់ទៅលើខ្លឹមសារ ហើយដែលយើងឃើញថា ក្នុងការបង្ហាញខ្លួនចំពោះមុខសវនាការកន្លងមកនេះ លោក នួន ជាក៏គាត់បានលើកអំពីការសុំឲ្យកោះហៅសាក្សី TCW-447 នេះមកបង្ហាញខ្លួនចំពោះមុខតុលាការដែរ ក៏ប៉ុន្តែមានការជំទាស់ពីសហព្រះរាជអាជ្ញា ហើយអង្គជំនុំជម្រះក៏មិនមានគម្រោង ដើម្បីកោះហៅសាក្សីរូបនេះមកបង្ហាញខ្លួនដែរ។

ចំពោះឯកសារ D210/8 វាជាប្រភេទឯកសារសម្ភាសដែលធ្វើឡើងក្រៅក្របខ័ណ្ឌតុលាការ។ លើសពីនេះទៀត ឯកសារនេះមាននិយាយអំពីសកម្មភាព និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែល

តម្រូវឲ្យយើងត្រូវធ្វើការសួរដេញដោលចំពោះអ្នកដែលបានផ្តល់សក្ខីកម្មដូចដែលបានរៀបរាប់នេះ។

[១៣:៥០:០០]

ចំពោះឯកសារ 210/9 ក៏ដូចគ្នានេះដែរ គឺជាប្រភេទបទសម្ភាសន៍ដែលធ្វើឡើងក្រៅក្របខ័ណ្ឌតុលាការ ហើយបាននិយាយអំពីសកម្មភាព និងអាកប្បកិរិយារបស់ជនជាប់ចោទ។ ចំណែកឯតុលាការក៏គ្មានគម្រោងនឹងកោះហៅបុគ្គលនេះដែរ។ ដូច្នេះ ការជំទាស់ចំពោះការដាក់ឯកសារនេះ វាជាការចាំបាច់។

ឯកសារ D228.9 គឺប្រហាក់ប្រហែលគ្នាដែរ ជាប្រភេទបទសម្ភាសន៍ដែលទទួលបានក្រៅក្របខ័ណ្ឌតុលាការ ហើយយើងមិនអាចធ្វើការផ្ទៀងផ្ទាត់ចំពោះខ្លឹមសារបាន ពីព្រោះវាជារបាយការណ៍។ យើងក៏មិនដឹងពីលក្ខខណ្ឌនៃការសម្ភាសនោះដែរ។

ឯកសារ D224.121 វាជាឯកសារប្រភេទបទសម្ភាសន៍ដែលធ្វើឡើងក្រៅក្របខ័ណ្ឌតុលាការដូចគ្នា។ ហើយអ្វីដែលគួរឲ្យកត់សម្គាល់នោះគឺឯកសារនេះធ្វើឡើងដោយនិស្សិតម្នាក់។ ក្រុមប្រឹក្សាជំនុំជម្រះអាចពិនិត្យមើលឯកសារ D224 ដែលជាប់ពាក់ព័ន្ធទៅនឹងបញ្ហានេះ។

[១៣:៥២:៣០]

ម៉្យាងទៀត ការសម្ភាសធ្វើឡើងជាភាសាខ្មែរ ប៉ុន្តែឯកសារដែលយើងមាននៅក្នុងសំណុំរឿងជាប្រភេទឯកសារបកប្រែដែលជាភាសាអង់គ្លេស។ ដូច្នេះយើងក៏មិនអាចមានមូលដ្ឋាន ដើម្បីពិនិត្យទៅលើខ្លឹមសារថា តើវាត្រឹមត្រូវកម្រិតណានោះដែរ។ ចំពោះអ្នកដែលបានធ្វើឯកសារនេះ អង្គជំនុំជម្រះក៏មិនមានគម្រោងនឹងកោះហៅបុគ្គលនោះមកបង្ហាញមុខអង្គជំនុំជម្រះនេះដែរ។

មូលដ្ឋាននៃការធ្វើជំទាស់ក្នុងឯកសារ D224.37 គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងឯកសារ D224.121 ដែរ។ ខ្ញុំបាទសូមមិនធ្វើការលើកឡើងជាថ្មីទៀតទេ។

ចំពោះឯកសារ D243/2.1.19 យើងខ្ញុំសូមជំទាស់ទៅលើខ្សែចង្វាក់នៃការថែរក្សាឯកសារ ពីព្រោះវាមិនមានការបង្ហាញឲ្យឃើញពីភាពដែលអាចជឿជាក់បាន។ ឯកសារនេះជាប្រភេទទង់បដិវត្តដែលយើងបានស្តាប់ឮការជំទាស់ជាច្រើននៅក្នុងអង្គសវនាការកន្លងមក។

[១៣:៥៤:៥៥]

ការពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ សាក្សីឈ្មោះ ឆាំង យុ បានប្រកាសនៅក្នុងសវនាការនេះថា បើអំនួន ចង់បានឯកសារដើមនៃទង់បដិវត្តនោះ លោកនឹងអាចធ្វើជូនមកឲ្យបាន។ នេះយោងតាមប្រតិចារឹក

E1/38.1។ ដូច្នេះ វាចាំបាច់ដែលអង្គជំនុំជម្រះត្រូវយកឯកសារដើមនេះ យកមកធ្វើការដេញដោលនៅក្នុងពេលជំនុំជម្រះ។

ឯកសារ D248/2.2 យើងខ្ញុំសូមជំទាស់ទៅលើឯកសារនេះ ដោយហេតុថាវាជាសេចក្តីប្រកាស ឬជាបទសម្ភាសន៍ដោយធ្វើឡើងក្រៅក្របខ័ណ្ឌតុលាការ ដែលយើងមិនអាចធ្វើការផ្ទៀងផ្ទាត់ទៅលើឯកសារនេះបាន។ យើងខ្ញុំដឹងថាមានការស្នើសុំឲ្យអ្នកដែលបានធ្វើការសម្ភាសនេះមកបង្ហាញខ្លួន ប៉ុន្តែអង្គជំនុំជម្រះមិនមានគម្រោង និងកោះហៅទេ ដោយសារមានការជំទាស់ពីសហព្រះរាជអាជ្ញាផងដែរ។

[១៣:៥៧:០១]

ចំពោះឯកសារ D248/6.1.6 យើងខ្ញុំសូមគាំទ្រចំពោះការលើកឡើងរបស់មេធាវីការពារលោក អៀង សារី ហើយយើងខ្ញុំសូមបន្ថែមថា វាមានបញ្ហាបកប្រែភាសានេះមិនត្រូវគ្នាផងដែរ រវាងភាសាខ្មែរ ភាសាបារាំង និងភាសាអង់គ្លេស ដែលអត្ថបទមួយនេះមានខ្លឹមសារផ្ទុយគ្នាក្នុងបីភាសានេះ។

ចំពោះឯកសារ D262.2 ខ្ញុំបាទសុំគាំត្រចំពោះការលើកឡើងរបស់មេធាវីការពារលោក អៀង សារី ដែរ ដោយខ្ញុំបាទសុំមិនធ្វើការអត្ថាធិប្បាយបន្ថែម។

ចំពោះឯកសារ D269/9/1.15 យើងខ្ញុំសូមធ្វើការជំទាស់ដោយសារឯកសារនោះ វាជាបទសម្ភាសន៍ក្រៅក្របខ័ណ្ឌតុលាការ ហើយធ្វើឡើងដោយនិស្សិតម្នាក់ ដែលមានលេខសម្គាល់នៅក្នុង ជាសាក្សីរបស់អង្គជំនុំជម្រះលេខ TCE-38។ ម្យ៉ាងទៀត វាជាប្រភេទឯកសារបកប្រែ ជាភាសាអង់គ្លេស ដែលភាសាដើមធ្វើជាភាសាខ្មែរ ហើយពុំមានឯកសារជាភាសាខ្មែរនៅក្នុងសំណុំរឿងទេ។ ដូច្នេះ យើងមិនអាចធ្វើការផ្ទៀតផ្ទាត់ទៅលើខ្លឹមសារបាន។ ម្យ៉ាងទៀត នៅក្នុងឯកសារនោះ មានខ្លឹមសារនិយាយអំពីសកម្មភាព និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែលជនជាប់ចោទមានសិទ្ធិស្នើសុំឲ្យជននោះមកបង្ហាញខ្លួនដើម្បីធ្វើការសួរដេញដោលតទល់គ្នា។ ក៏ប៉ុន្តែ អង្គជំនុំជម្រះ ក៏មិនមានគម្រោងនឹងហៅបុគ្គលនោះមកបំភ្លឺនៅចំពោះមុខអង្គសវនាការនោះដែរ។

[១៤:០០:២៣]

ឯកសារ D269/9/1.15.1 គឺដូចគ្នានេះដែរ មានមូលដ្ឋាននៃការជំទាស់ ដូចគ្នានឹងឯកសារ D269/9/1.15។ ដូច្នេះ ខ្ញុំបាទសុំមិនធ្វើការអត្ថាធិប្បាយម្តងទៀតទេ។

ឯកសារ D288/5.463។ ឯកសារនេះចាំបាច់ត្រូវតែហៅអ្នកដែលបានផ្តល់សក្ខីកម្មនោះ មក

ចំពោះមុខអង្គជំនុំជម្រះដើម្បីសួរដេញដោលតទល់គ្នា។ ការធ្វើបែបនេះ គឺដើម្បីបញ្ជាក់ទៅលើភាពត្រឹមត្រូវនៃការធ្វើឯកសារនោះផងដែរ។ ដូចគ្នានេះដែរ មូលដ្ឋាននៃការជំទាស់ដែលតម្រូវជាចាំបាច់ឲ្យអ្នកដែលធ្វើបទសម្ភាសន៍ ឬក៏ធ្វើអត្ថាធិប្បាយត្រូវតែឡើងមកបំភ្លឺចំពោះមុខអង្គជំនុំជម្រះ ដើម្បីឲ្យភាគីអាចសួរដេញដោលចំពោះឯកសារ ដែលមានលេខសម្គាល់ដូចតទៅ៖ D288/6.159/10 ឯកសារដែលមានលេខសម្គាល់ D288/6.52/4.24 ឯកសារ D288/6.52/4.42 ឯកសារ D288/6.52/4.43។

ឯកសារ ដែលខ្ញុំអានអម្បាញ់មិញនេះ គឺទាមទារឲ្យមានការតទល់គ្នារវាងអ្នកដែលធ្វើឯកសារនោះ។ ហើយដែលយើងខ្ញុំសុំធ្វើការជំទាស់ទៅនឹងការដាក់ឯកសារនេះដើម្បីធ្វើការសួរដេញដោល។

[១៤:០៤:០៨]

ចំពោះឯកសារ D288/6.5/2.29។ យើងខ្ញុំសូមជំទាស់នឹងឯកសារនេះ ជំទាស់នឹងការដាក់ឯកសារនេះ ដោយសារអង្គជំនុំជម្រះមិនមានគម្រោងដើម្បីកោះហៅអ្នកដែលនិពន្ធឯកសារនេះមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ ដោយហេតុថា យើងមិនអាចធ្វើការផ្ទៀងផ្ទាត់ទៅលើភាពត្រឹមត្រូវនៃឯកសារនេះបាន។

ឯកសារ D29/E នៅក្នុងAttachment33 គឺជាប្រភេទឯកសារដែលធ្វើឡើងនៅក្រៅក្របខ័ណ្ឌតុលាការ ដែលយើងខ្ញុំសូមជំទាស់ចំពោះការទទួលយកឯកសារនេះ ដូចគ្នាទៅនឹងឯកសារដែលមានលេខសម្គាល់ D29 Attachment 01, D369/7.1.562។

ចំពោះឯកសារ D299.1.19R ជាប្រភេទឯកសារដែលមានកំណត់នៅក្នុងជើងទំព័រ៤១៨៨។ វាជាប្រភេទរូបថត ដែលមាននៅក្នុងខ្សែវីដេអូ ត្រង់នាទីប្រាំបីចុចសាមសិបប្រាំ។ ដូច្នេះ ការដាក់ឯកសារនេះ មិនមែនខ្សែវីដេអូទាំងមូលទេ គឺគ្រាន់តែជារូបភាពមួយនៅក្នុងខ្សែវីដេអូនេះតែប៉ុណ្ណោះ។

[១៤:០៧:២៨]

ចំពោះឯកសារ D29 Attachment 86 ជាប្រភេទឯកសារបកប្រែ ហើយមិនមានឯកសារដើមទេ គឺគ្មានភាសាខ្មែរ មានតែភាសាអង់គ្លេស ដូច្នេះ យើងក៏មិនមានមូលដ្ឋានដើម្បីផ្ទៀងផ្ទាត់បានដែរ។ អ៊ីចឹងហើយ យើងខ្ញុំសូមធ្វើការជំទាស់ការដាក់ឯកសារនេះ។

ឯកសារ D313/1.2.406 វាជាប្រភេទបទសម្ភាសន៍ដែលធ្វើឡើងនៅក្រៅក្របខ័ណ្ឌតុលាការដែរ ហើយជាឯកសារបកប្រែជាភាសាអង់គ្លេស។ យើងខ្ញុំដឹងថា មានការស្នើសុំឲ្យកោះហៅសាក្សីនេះដែលមានលេខសម្គាល់ TCW-92 និងTCW-223 ឲ្យមកបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះ។ ក៏ប៉ុន្តែ

អង្គជំនុំជម្រះមិនមានគម្រោងដើម្បីកោះហៅសាក្សីទាំងពីរនេះទេ។

លើសពីនេះទៀត ក្នុងបទសម្ភាសន៍នេះ ក្នុងឯកសារនេះ មាននិយាយអំពីសកម្មភាព និងអាកប្បកិរិយារបស់ជនជាប់ចោទ។ អ៊ីចឹង វាទាមទារឲ្យជនជាប់ចោទអាចមានសិទ្ធិសួរដេញដោលតទល់ជាមួយនឹងបុគ្គលទាំងពីរនេះ។

ដូច្នេះ យើងខ្ញុំសូមធ្វើការជំទាស់ចំពោះឯកសារនេះ ការដាក់ឯកសារនេះ។ ចំពោះឯកសារ D359/1/1.1.41 និងឯកសារ D359/1/1.1.44 វាជាប្រភេទឯកសារបកប្រែ ដែលមិនមានឯកសារដើម។ ឯកសារនេះជាប្រភេទការទូត ហើយដែលធ្វើការស្រង់ព័ត៌មាននានាជាភាសាខ្មែរ ក៏ប៉ុន្តែពុំមានអត្ថបទជាភាសាខ្មែរសម្រាប់ឲ្យយើងធ្វើការផ្ទៀងផ្ទាត់ចំពោះខ្លឹមសារនោះទេ។ យើងខ្ញុំសូមគាំទ្រនូវការលើកឡើងរបស់ក្រុមមេធាវីការពារលោក អៀង សារី ដែរ។ ឯកសារនេះមិនត្រូវបានទទួលយកសម្រាប់ការដេញដោលនេះទេ គឺយើងខ្ញុំសូមបដិសេធ។

[១៤:១១:០៩]

ចំពោះឯកសារ D56-Doc.066 វាជាប្រភេទកម្រងឯកសារប្រទេសស៊ុយអែត ឬក៏*ស្វីដឌីសខូឡិចសិន* ហើយដែលយើងបានធ្វើការជំទាស់យ៉ាងច្រើននៅពេលបង្ហាញពីយថាភាព នៃឯកសារកាលពីសវនាការលើកមុនរួចហើយដែរ។

ចំពោះឯកសារ D56-Doc.103 ជាប្រភេទឯកសារបកប្រែ មិនមានឯកសារដើមដូចគ្នា។ ដូច្នេះ យើងខ្ញុំមិនអាចធ្វើការផ្ទៀងផ្ទាត់ចំពោះឯកសារនេះបានទេ។ អ៊ីចឹងយើងខ្ញុំសូមធ្វើការជំទាស់ចំពោះការដាក់ឯកសារនេះ។

ឯកសារ D56-Doc.236 ដូចគ្នាដែរ គឺជាប្រភេទឯកសារបកប្រែ ដែលមិនមានឯកសារ ហើយយើងក៏មិនធ្វើការផ្ទៀតផ្ទាត់ចំពោះខ្លឹមសារនៃឯកសារនោះ។ អ៊ីចឹងយើងខ្ញុំសូមធ្វើការជំទាស់ចំពោះការដាក់ឯកសារនេះ។

[១៤:១៣:៣៦]

ចុងក្រោយឯកសារដែលមានលេខ D90/E។ គឺស្រដៀងគ្នានឹងការលើកឡើងមុនៗដែល ដែលជាប់ពាក់ព័ន្ធទៅនឹងសាក្សី TCW-281 គឺក្នុងសំណុំរឿង០០១ ដែលមាន គឺឈ្មោះលោក ឌុច ដែលយើងចាំបាច់ត្រូវធ្វើការតទល់ជាមួយនឹងសាក្សីនេះ។

ចំពោះឯកសារទាំងអស់ដែលយើងខ្ញុំបានលើកជូនអង្គសវនាការអម្បាញ់មិញនេះ រួមទាំងឯកសារ

ដែលមានលេខ D288/6/1 អ៎! សូមទោស .5/2.29 ផងនោះ យើងខ្ញុំសូមជំទាស់ចំពោះការដាក់ឯកសារនេះ រហូតមានសាក្សីដែលជាប់ពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មនេះមកបង្ហាញខ្លួនចំពោះមុខសវនាការ ដើម្បីឲ្យយើងអាចធ្វើការសួរដេញដោលតទល់ជាមួយនឹងសាក្សី ជាពិសេស សាក្សីដែលមានលេខ TCW-281 ទាក់ទងទៅនឹងឯកសារចុងក្រោយដែលមានលេខ D90/2។

សរុបសេចក្តីមក ខ្ញុំបាទសូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាបដិសេធចំពោះឯកសារដែលមានមូលដ្ឋានដូចដែលខ្ញុំបាទបានលើកជូនអម្បាញ់នេះ។ បាទ សូមអរគុណ។

[១៤:១៦:២៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានបង្ហាញជំហរយ៉ាងជាក់ច្បាស់នៅក្នុងការជំទាស់ទៅលើឯកសារចំនួន៩៥ ដែលអង្គជំនុំជម្រះបានដាក់ដើម្បីពិភាក្សា និងតវ៉ាជំទាស់នៅក្នុងអំឡុងពេលសវនាការនេះ។ ហើយជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ហើយនិងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ហើយអង្គជំនុំជម្រះក៏ចង់ដឹងដែរមុននឹងផ្តល់វេទិកា ថាតើការបែងចែកពេលវេលាយ៉ាងដូចម្តេចដែរចំពោះការពាក់ព័ន្ធនឹងបញ្ហាការជំទាស់តវ៉ាទៅនឹងឯកសារទាំងអស់ដែលបានបង្ហាញរួចហើយ ដោយភាគីក្រុមមេធាវីការពារក្តី ដោយអង្គជំនុំជម្រះបានជម្រាបជូនដំណឹងអំពីការបែងចែកពេលវេលាដែលបានបែងចែកឲ្យ។ ប៉ុន្តែដោយសារកិច្ចដំណើរការមានការរអាក់រអួលអ៊ីចឹងហើយធ្វើឲ្យពេលវេលាហ្នឹងគឺថាវាកិលទៅមុខយ៉ាងច្រើន វាអាចប៉ះពាល់នូវពេលវេលាដែលអង្គជំនុំជម្រះបានបែងចែកទៅឲ្យភាគីសហព្រះរាជអាជ្ញា និងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះចង់ដឹងពីបញ្ហានេះជាមុន ដើម្បីការគណនាពេលវេលាសម្រាប់ដំណើរការ សម្រាប់រសៀលនេះ ឬក៏នាពេលខាងមុខទៀត។

សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទសូមអរគុណលោកប្រធាន។ ខាងក្រុមការិយាល័យសហព្រះរាជអាជ្ញាត្រូវការពេលវេលាប្រហែលជាមួយម៉ោងដប់នាទីបាទ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន យើងត្រូវការរយៈពេលពី១៥ ទៅ២០នាទីតែប៉ុណ្ណោះ វាជាការគ្រប់គ្រាន់ហើយ

ចំពោះយើង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អ៊ីចឹងអង្គជំនុំជម្រះសូមផ្ដល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសនៅក្នុងការបង្ហាញពាក់ព័ន្ធនឹងឯកសារទាំង៩៥។

សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទសូមអរគុណលោកប្រធាន។

កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ នោះ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ឱកាសដល់ភាគីទាំងអស់ក្នុងការលើកឡើងអំពីការជំទាស់ទៅនឹងឯកសារដែលបានកំណត់ក្នុងជើងទំព័រនៃដីកាដំណោះស្រាយ ទាក់ទងទៅនឹងប្រវត្តិបក្សកុម្មុយនីស្ដកម្ពុជា។ ហើយនៅពេលនេះក៏ដូចជាលើកមុនអ៊ីចឹងដែរ គឺៗជាការបង្ហាញឯកសារដែលមាននៅក្នុងកំណត់ជើងទំព័រនៃដីកាដំណោះស្រាយ ទាក់ទងទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ។ ការបង្ហាញនេះគឺគោរពតាមអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ ពោលគឺឯកសារលេខ E170។ ហើយនៅក្នុងអនុស្សរណៈនេះគឺបានលើកឡើងថា ឯកសារដែលអង្គជំនុំជម្រះមិនពិចារណា--

**ប្រធានអង្គជំនុំ៖**

សូមតំណាងសហព្រះរាជអាជ្ញាជាតិ សូមផ្អាកបន្តិចសិន ដោយមានបញ្ហាខាងបច្ចេកទេសប្រតិចារឹក។

[១៤:២០:១៩]

*(មានបញ្ហាបច្ចេកទេស)*

[១៤:២១:៥៣]

បាទឥឡូវនេះដោយសារមានបញ្ហាបច្ចេកទេសប្រតិចារឹក ហើយពេលវេលាក៏សមល្មមនឹងសម្រាកផង ហេតុដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះដប់ប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ជាការសម្រួលទាំងការសម្រាកផងទាំងការរៀបចំស្ដារឡើងវិញនូវបច្ចេកទេសនៃប្រតិចារឹកផង។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២២ នាទី ដល់ម៉ោង ១៤:៤៦ នាទី)*

[១៤:៤៥:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អម្បាញ់មិញនេះ អង្គជំនុំជម្រះបានផ្តល់វេទិកាទៅដល់តំណាងសហព្រះរាជអាជ្ញា ក្នុងការមានឱកាសក្នុងការធ្វើអត្ថាធិប្បាយទៅលើឯកសារទាំង៩៥ ប៉ុន្តែដោយសារមានបញ្ហាបច្ចេកទេសខាងប្រតិចារឹក ដែលនាំឲ្យរាំងស្ទះមិនអាចដំណើរបាន ហើយតាមទទួលព័ត៌មានប្រតិចារឹកមកគឺ បញ្ហានោះគឺមានការរអាក់រអួលរយៈពេលយូរហើយ ដូច្នេះអង្គជំនុំជម្រះប្រគល់វេទិកាទៅឲ្យតំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើកិច្ចការនេះរបស់ខ្លួនបន្ត ដោយចាប់ផ្តើមពីដំបូង ពីព្រោះបញ្ហាដែលបានធ្វើរួចហើយនោះ មិនបានកត់ត្រាត្រឹមត្រូវទេ។

សូមអញ្ជើញ!

[១៤:៤៦:៣៦]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំនឹងចាប់ផ្តើមពីដំបូងឡើងវិញ។ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះបានផ្តល់ឱកាសដល់គ្រប់ភាគីទាំងអស់ក្នុងការលើកឡើងអំពីការជំទាស់ទៅនឹងឯកសារដែលមានជើងទំព័រនៃដីកាដំណោះស្រាយ ដែលទាក់ទងទៅនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។ ហើយនៅពេលនេះក៏ដូចជាមុនៗដែរ គឺមានការបង្ហាញឯកសារដែលមាននៅក្នុងកំណត់ជើងទំព័រនៃដីកាដំណោះស្រាយដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ។ ហើយការបង្ហាញនេះ គឺគោរពទៅតាមអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ ដែលមានលេខឯកសារគឺ E170។ នៅក្នុងអនុស្សរណៈនេះ គឺបានលើកឡើងថា ឯកសារដែលអង្គជំនុំជម្រះមិនពិចារណាគឺឯកសារ ដែលបានស្នើសុំដាក់នៅចំពោះអង្គជំនុំជម្រះសាលាដំបូងរួចហើយ។ ឯកសារទាំងនេះគឺជាឯកសារដែលស្ថិតនៅក្នុងឧបសម្ព័ន្ធ១ ដល់ឧបសម្ព័ន្ធ៥ នៃបញ្ជីឯកសាររបស់សហ

ព្រះរាជអាជ្ញាសម្រាប់ដំណាក់កាលទីមួយនៃសវនាការនេះ។

[១៤:៤៨:០៨]

ឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ១ ដល់ឧបសម្ព័ន្ធ៥ ហ្នឹង មានដូចជា មួយគឺចម្លើយរបស់ជនជាប់ចោទ ពីរឯកសារបោះពុម្ពផ្សាយ និងសេចក្ដីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា បីកំណត់ហេតុប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា បួនការប្រាស្រ័យទាក់ទងរបស់កម្ពុជាប្រជាធិបតេយ្យ និងប្រាំរបាយការណ៍សារព័ត៌មាន និងសេចក្ដីថ្លែងការណ៍សាធារណៈរបស់កម្ពុជាប្រជាធិបតេយ្យ។

ហើយអង្គជំនុំជម្រះក៏នឹងមិនពិចារណាផងដែរ នូវឯកសារស្ដីពីសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ដែលនឹងបង្កើតជាកម្មវត្ថុនៃសេចក្ដីសម្រេច ដែលនឹងស្ថិតនៅក្រោមការពិចារណារបស់អង្គជំនុំជម្រះ។ បន្ថែមពីលើអនុស្សរណៈនេះដែរ គឺយើងបានទទួលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ ដែលបានផ្ញើតារាងចំនួនពីរទាក់ទងទៅនឹងឯកសារដែលត្រូវធ្វើសវនាការនៅពេលនេះ។

តារាងទីមួយគឺជាឯកសារ ដែលរៀបចំដោយការិយាល័យសហព្រះរាជអាជ្ញាមានចំនួន ១៥ ឯកសារដើម្បីដាក់មកពិភាក្សា។ ហើយតារាងទីពីរគឺជាឯកសារដែលរៀបចំដោយអង្គជំនុំជម្រះសាលាដំបូង និងបញ្ជីឯកសារសរុបចំនួន ១២០ឯកសារ ដែលមានយោងនៅក្នុងកំណត់ជើងទំព័រក្នុងកថាខណ្ឌបន្ថែមរបស់អង្គជំនុំជម្រះសាលាដំបូង។

[១៤:៤៩:៤៥]

ហើយក្នុងចំណោមឯកសារទាំងអស់នេះ គឺមានឯកសារមួយចំនួនដែលជាឯកសារទាក់ទងទៅនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ដែលបានលើកយោងក្នុងកំណត់ជើងទំព័រនៃដីកាដំណោះស្រាយ។ ឯកសារទាំងនេះមិនមែនជាកម្មវត្ថុដែលត្រូវយកមកបង្ហាញនៅពេលនេះទេ ហើយឯកសារទាំងនេះមានប្រហែលជា១៣ឯកសារ ហើយត្រូវបានចាត់ថ្នាក់ជាឯកសារ E3 ផងដែរ។ ឯកសារទាំងនេះក៏មានជាសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ហើយបើយោងទៅតាមអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារប្រភេទនេះក៏មិនមែនជាកម្មវត្ថុដែលត្រូវលើកយកមកពិភាក្សានៅពេលនេះដែរ។ ហើយឯកសារទាំងនេះមានប្រហែលជា២០ឯកសារ។ ជាមួយគ្នានេះដែរ ឯកសារទាំងអស់នេះក៏មានឯកសារដែលជាឧបសម្ព័ន្ធ១ ដល់ ឧបសម្ព័ន្ធ៥ ផងដែរ។ ហើយឯកសារទាំងហ្នឹងមានប្រហែលជា ១២ឯកសារ។

[១៤:៥០:៥២]

ដូច្នេះសហការីខ្ញុំ ហើយនិងខ្ញុំនឹងមិនលើកឡើងឯកសារដែលមិនមែនជាប្រធានបទសម្រាប់ពេលនេះទេ។ ហើយជាបន្តខ្ញុំសូមលើកឡើងអំពីរបាយការណ៍ចំនួនបីដែលមានចំណងជើងថា "របាយការណ៍វិភាគ"។ របាយការណ៍វិភាគទីមួយ គឺធ្វើឡើងដោយលោក ក្រេក អេតធេសាន់ ដែលមានចំណងជើងថា "ទស្សនាទានអំពីឋានានុក្រមនៃរបបកម្ពុជាប្រជាធិបតេយ្យ" ដែលមានលេខឯកសារ D2-15។ របាយការណ៍នេះ ត្រូវបានទទួលមកធ្វើជាភស្តុតាងរួចមកហើយនៅក្នុងសំណុំរឿងលេខ០០១ លោក ក្រេក អេតធេសាន់ គាត់ធ្លាប់បានផ្តល់សក្ខីកម្មនៅក្នុងអង្គសវនាការនៃសំណុំរឿង ០០១ ដែលគាត់បានលើកឡើងអំពីរបាយការណ៍នេះ រួមទាំងប្រភពសំខាន់ដែលគាត់បានលើកឡើង--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី!

[១៤:៥២:១៤]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សាធារណជនទាំងអស់ ទាំងក្នុង និងក្រៅបន្ទប់សវនាការ។ គឺថាសហព្រះរាជអាជ្ញាមិនបានលើកឡើងនូវឯកសារណាជាក់លាក់នោះទេ មិនមែនជាឯកសារពាក់ព័ន្ធទៅនឹងឆ្នាំ៧៥ទេ (សូមទោស) មិនមែនជាឯកសារចំនួន ៩៥នេះទេ។ គឺអ្វីដែលលើកឡើងមិនមាននៅក្នុងបញ្ជីឯកសារនោះទេ។ ខ្ញុំគិតថាការលើកឡើងនេះមិនមែនសម្រាប់គោលបំណងសវនាការនៅថ្ងៃនេះទេ។ ហើយយើងនៅសល់តែឈប់សម្រាកហ្នឹងនៅសល់តែមួយម៉ោងម្ភៃនាទីទៀត។

ដូច្នេះខ្ញុំសូមស្នើថាសហព្រះរាជអាជ្ញាត្រូវតែលើកនូវឯកសារតែកៅ-- វង្វង់ឯកសារតែ៩៥នេះបានហើយ ទើបយើងអាចបញ្ចប់នៅថ្ងៃនេះបាន។ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី កាណាវាស ដែលបានធ្វើការជំទាស់។ ដូច្នេះការជំទាស់ហ្នឹងជាការត្រឹមត្រូវ។ សូមតំណាងសហព្រះរាជអាជ្ញាតម្រង់ទិស ដើម្បីលើកទឡ្ហីករណ៍តទល់ពាក់ព័ន្ធនឹងតែឯកសារចំនួន ៩៥។

អង្គជំនុំជម្រះបានជម្រាបជូនរួចហើយ តាំងពីមុនពេលដែលផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញានោះ។ ហើយភាគីដទៃទៀតដែលគេបានធ្វើកន្លងមក គឺមិនប្រាសចាកនឹងអ្វីដែលអង្គជំនុំ

ជម្រះបានកំណត់នោះឡើយ។

[១៤:៥៣:៤១]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តទៀត-- លោកប្រធានខ្ញុំសូមអនុញ្ញាតសម្រាកដើម្បីពិភាក្សាជាមួយសហការីខ្ញុំមួយភ្លែតបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដោយពេលវេលាតិច អង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ថាតើខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអាចប្រើប្រាស់ពេលវេលានេះមុនពេល-- មុនខាងធ្វើអត្ថាធិប្បាយដោយក្រុមសហព្រះរាជអាជ្ញាដែរឬទេ?

បាទ? សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

លោកប្រធាន ខ្ញុំសូមចាប់ផ្ដើម លោកប្រធានអនុញ្ញាតចាប់ផ្ដើមឡើងវិញ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយ ដោយសារតំណាងសហព្រះរាជអាជ្ញាអាចបន្តការងាររបស់ខ្លួនបានហើយ ដូច្នេះខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនបាច់ឆ្លើយតបនឹងអ្វីដែលយើងបានសួរអម្បាញ់មិញនេះទេ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អំតំណាងសហព្រះរាជអាជ្ញាជាតិ!

[១៤:៥៥:៤៩]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ជាបន្តខ្ញុំសូមដាក់ឯកសារដែលជាខ្សែវីដេអូ។ យើងឃើញថាក្នុងកំណត់ត្រាជើងទំព័រនៃដីកាដំណោះស្រាយក៏បានលើកឡើងអំពីខ្សែវីដេអូមួយចំនួនផងដែរ ហើយខ្សែវីដេអូដែលនឹងលើកយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះមានដូចជា ឯកសារលេខ D299.1.19R។ ខ្សែវីដេអូនេះមានចំណងជើងថា "កម្ពុជាស្លាប់ និងកើតឡើងវិញ"។ ខ្សែវីដេអូនេះគឺជាគឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលមកពីប្រទេសអាល្លឺម៉ង់។

ហើយខ្សែវីដេអូមួយទៀត គឺឯកសារលេខ D295/2/2.52R។ ខ្សែវីដេអូនេះមានចំណងជើងថា "ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូចិន និងម៉ាឡេស៊ីមកកាន់កម្ពុជាប្រជាធិបតេយ្យ"។ ខ្សែវីដេអូនេះ

គឺជាខ្សែភាពយន្តឯកសារ ដែលបានផលិតឡើងដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៦។ ហើយខ្សែវីដេអូនេះបង្ហាញអំពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូចិន ដែលមានលោក ខៀវ សំផន, លោក នួន ជា, និងលោក អៀង សារី ជាអ្នកទទួលដំណើររបស់គណៈប្រតិភូផងដែរ។

[១៤:៥៧:២៦]

នៅក្នុងខ្សែវីដេអូនេះផងដែរក៏បានបង្ហាញអំពីគណៈប្រតិភូប្រទេសម៉ាឡេស៊ី ដែលមានលោក ខៀវ សំផន, នួន ជា, អៀង សារី, និង អៀង ធីរិទ្ធ ជាអ្នកទទួលដំណើររបស់គណៈប្រតិភូផងដែរ។ ហើយខ្សែវីដេអូនេះ គឺទទួលបានមកពីមជ្ឈមណ្ឌលសោតទស្សន៍បុប្ផាណា។

ហើយខ្សែវីដេអូមួយទៀត គឺមានឯកសារលេខ 295/2/2.65R។ ខ្សែវីដេអូនេះមានចំណងជើងថា "ដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីប្រទេសឡាវ ឈ្មោះ សុផានុវង្ស មកកាន់កម្ពុជាប្រជាធិបតេយ្យ"។ ខ្សែវីដេអូនេះ គឺជាភាពយន្តឯកសារដែលផលិតឡើងដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ហើយខ្សែវីដេអូនេះបង្ហាញអំពីដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីឡាវ មកកាន់កម្ពុជាប្រជាធិបតេយ្យ និងបង្ហាញអំពីអ្នកដែលទទួលដំណើររបស់គណៈប្រតិភូ ដែលក្នុងនោះមានលោក ខៀវ សំផន, លោក នួន ជា, លោក អៀង សារី, និង អៀង ធីរិទ្ធ បានហែហមដំណើរគណៈប្រតិភូផងដែរ។

[១៤:៥៨:៥៣]

ហើយខ្សែវីដេអូនេះក៏បានទទួលមកពីមជ្ឈមណ្ឌលសោតទស្សន៍បុប្ផាណា ហើយឯកសារទាំងនេះប្រមូលបាន ដោយយោងទៅតាមដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងអំឡុងថ្ងៃ៧ ខែសីហា ឆ្នាំ២០០៩ ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩។

ខ្សែវីដេអូមួយទៀត មានឯកសារលេខ D232/110.1.1.1R។ ខ្សែវីដេអូនេះមានចំណងជើងថា "ប៉ុល ពត នៅប៉េកាំង"។ ខ្សែវីដេអូនេះ គឺជារបាយការណ៍ឯកសារស្ដីអំពីដំណើរទស្សនកិច្ចរបស់ ប៉ុល ពត ទៅកាន់ប្រទេសចិននៅខែកញ្ញា ឆ្នាំ១៩៧៧ គឺជាពេលវេលាដែលគាត់បានប្រកាសអំពីអត្ថិភាពរបស់បក្សកុម្មុយនីស្តកម្ពុជា។ ហើយឯកសារនេះក៏ប្រមូលបានមកពី ដោយយោងទៅតាមដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេតផងដែរ គឺទទួលបានមកពីមជ្ឈមណ្ឌលសោតទស្សន៍បុប្ផាណា។

[១៥:០០:១៣]

លើសពីនេះទៀត នៅក្នុងអង្គហេតុ នៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូទាំងនេះ គឺត្រូវបានរាយការណ៍ដោយឯកសារផ្សេងៗជាច្រើនទៀតផងដែរ។ ឧទាហរណ៍ បើយើងមើលអំពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ ដែលជាប្រធានាធិបតីឡាវមកកាន់កម្ពុជាប្រជាធិបតេយ្យ គឺត្រូវបានគេរាយការណ៍ នៅក្នុងសេចក្តីសង្ខេបព័ត៌មានពិភពលោកផងដែរ។ បើទោះជាការថាប់យករូបភាពនៅក្នុងខ្សែវីដេអូនេះ មានរយៈពេលខ្លីដ៏ដោយ ក៏បង្ហាញអំពីគណៈប្រតិភូ និងបង្ហាញអំពីថា តើអ្នកណាខ្លះដែលបានចូលរួមក្នុងការទទួលគណៈប្រតិភូនៅពេលនោះ? នេះគឺជាគោលបំណងនៃការប្រើប្រាស់ខ្សែវីដេអូនេះ។ ហើយខ្សែវីដេអូដែលមាននៅក្នុងឯកសារលេខ D295/2/2.52R គឺត្រូវបានប្រើប្រាស់ដើម្បីបង្ហាញថា លោក អៀង សារី ក៏បានទទួលគណៈប្រតិភូ ដែលបានមកទស្សនកិច្ចនៅកម្ពុជាផងដែរ។ បរិបទផ្សេងទៀត មិនអាចជួយធ្វើឱ្យនត្ថិភាព ឬក៏ជួយឱ្យផ្លាស់ប្តូរបរិបទដើម្បីបង្ហាញថា លោក អៀង សារី មិនបានទទួលគណៈប្រតិភូនោះទេ។

[១៥:០១:៤០]

ហើយលើសពីនេះទៀត គឺអង្គជំនុំជម្រះបានប្រកាសនូវសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួនរួចហើយកាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ នេះ ទាក់ទងទៅនឹងបញ្ហាឯកសារដោយបានសម្រេចថា សម្ភារៈមួយចំនួន ដូចជា រាយការណ៍ដែលមានកាលវិភាគ សៀវភៅ ភាពយន្តឯកសារ និងអត្ថបទដែលដកស្រង់ចេញពីប្រព័ន្ធផ្សព្វផ្សាយ អាចមានការពាក់ព័ន្ធ ហើយនិងត្រូវរាប់ចូលជាប្រភេទនៃឯកសារមួយផងដែរ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះនឹងពិចារណាសម្រេច អំពីតម្លៃជាភស្តុតាង នៃឯកសារទាំងនេះនាពេលខាងមុខសមស្រប។

បាទ ហើយនៅពេលនេះ ខ្ញុំចប់ការដាក់ឯកសាររបស់ខ្ញុំហើយ ហើយសហការីរបស់ខ្ញុំនឹងបន្តតទៅទៀតបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៥:០២:៤៥]

**លោកស្រី ហ្វាល់ហ្គុនី ដេបណាត៖**

សូមអរគុណលោកប្រធាន។ លោក លោកស្រីចៅក្រមជាទីគោរព គោលបំណងនៃការធ្វើសវនាការទៅលើឯកសារនេះច្បាស់លាស់ហើយ គោលបំណងនៃសវនាការនេះ គឺដើម្បីឱ្យភាគីលើក

ឡើងបញ្ជាឯកសារ ដែលបានដកស្រង់នៅក្នុងកំណត់ជើងទំព័រក្នុងកថាខណ្ឌមួយចំនួន នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលវាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទាក់ទង។ ឯកសារទាំងអស់នោះ គឺបានដាក់ជាប់ថាវាមានភាពពាក់ព័ន្ធ និងភាពទុកចិត្តបាន រួមទាំងបញ្ហាយថាភាពផងដែរ។

គោលបំណងនៃសវនាការនេះ គឺដើម្បីផ្តល់ដល់ភាគីនូវឱកាសបង្ហាញនូវការសន្មតមួយចំនួនថាតើគួរតែយើងអនុវត្តតាម ឬក៏អត់? ការជំទាស់ដែលបានស្តាប់នៅថ្ងៃនេះ បែងចែកចេញជាពីរ។ ទីមួយប្រភេទទីមួយ គឺព្យាយាមពង្រីកការជំទាស់ ដែលមិនអាចធ្វើទៅបាន។ ខាងភាគីផ្សេង គឺគាត់ព្យាយាមសុំបញ្ចូលឯកសារផ្សេង ហើយព្យាយាមសុំកោះហៅបុគ្គលដែលជាអ្នកធ្វើសម្ភាស ហើយពួកគាត់ស្នើសុំកោះហៅបុគ្គលទាំងអស់នោះ មុនពេលដែលយើងសម្រេចទៅលើឯកសារ។ ការស្នើសុំទាំងអស់នេះមិនមានការគាំទ្រពីយុត្តិសាស្ត្រណាមួយ ឬក៏មិនមានការគាំទ្រពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះថ្ងៃទី៣១ ខែមករា នោះទេ ដែលសម្រេចថា ឯកសារនេះពិនិត្យមើលទៅតើវាពាក់ព័ន្ធទុកចិត្តបានដែរឬទេ? សូមឲ្យភាគីពន្យល់ ឬក៏ឯកសារទាំងអស់នោះវាក្លែងក្លាយ? តាមលក្ខណៈឯកសារតើវាអាចឲ្យយើងឃើញថា តើវាមិនទុកចិត្តបានដែរឬទេ?

[១៥:០៤:៤៨]

ប្រភេទការជំទាស់ទីពីរនៅក្នុងថ្ងៃនេះគឺ ពាក់ព័ន្ធទៅនឹងទម្ងន់ដែលគួរតែផ្តល់ជូនទៅដល់អង្គជំនុំជម្រះនោះ-- ផ្តល់ជូនទៅលើឯកសារដោយអង្គជំនុំជម្រះ។ លក្ខណៈចំពោះទម្ងន់ គឺយើងមិនគួរលើកឡើងយកមក-- លើកជំទាស់ក្នុងនេះទេ។ បញ្ហាពាក់ព័ន្ធទៅនឹងទម្ងន់ គឺគួរតែពិចារណានៅក្នុងពេលមួយសមស្របនាពេលក្រោយតែប៉ុណ្ណោះ។ នៅពេលនេះ ខ្ញុំសូមអនុញ្ញាតទៅដល់កំណត់ហេតុរបស់ពាណិជ្ជកម្ម។ ឯកសារប្រហែល៣៨ ដែលសរសេរបញ្ចូលនៅក្នុងកំណត់សម្គាល់ជើងទំព័រ នៅក្នុងបញ្ជីនេះផងដែរ គឺកំណត់ហេតុក្រសួងពាណិជ្ជកម្ម។ កំណត់ជើងទំព័រ គឺប្រើដើម្បីគាំទ្រទៅលើកថាខណ្ឌនៅក្នុងដីកាដោះស្រាយ 1144 ដែលថា ខៀវ សំផន បានទទួលទូរលេខពីខាងក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្មដែលក្នុងនិយាយអំពីបញ្ហាដឹកជញ្ជូនចេញ និងនាំចូលស្បៀង ទំនាក់ទំនងជាមួយនឹងបរទេស ហើយនិងគណៈកម្មាធិការនៅក្នុងគណៈកម្មាធិការពាណិជ្ជកម្មធ្វើដំណើរទៅយកស្រូវ។ ចំពោះសាក្សី 583 ដែលគាត់ធ្វើការងារនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្មបានកំណត់ និងលើកឡើងកំណត់ហេតុពាណិជ្ជកម្មចំនួន១៤ ក្នុងពេលដែលសម្ភាសដោយ អ្វ.ស៊ី.អាយ.ជេ។ ចំណុចដែលសំខាន់នៅពេលនោះក៏មានការកំណត់សម្គាល់អំពីហត្ថលេខារបស់លោក វ៉ាន់ រិត ដែលជាលេខាខាងពាណិជ្ជកម្មផងដែរ។

[១៥:០៦:៥៥]

ហត្ថលេខានោះ គឺឃើញមានចុះនៅឯកសារជាច្រើន ដែលមានដាក់ស្គាល់ថាជាឯកសារពាណិជ្ជកម្ម។ ឧទាហរណ៍មានឯកសារ IS21.145។ ឯកសារនេះគឺមានហត្ថលេខា វ៉ាន់ រិត ដែលបានកំណត់ដោយ TC-- សាក្សី TCW-583។ ឯកសារនោះ ក៏មានកំណត់ត្រាចំណារដែលបញ្ជូនទៅបង ហែម ដែលជាឈ្មោះហៅក្រៅរបស់ ខៀវ សំផន។ សំណុំឯកសារមួយទៀត ដែលចេញមកកំណត់ហេតុក្រសួងពាណិជ្ជកម្ម គឺមានបទបាឋកថា ដែលក្នុងនោះនិយាយអំពីការប្រើប្រាស់១៤០លានយ័ន។ ដូច្នេះ នៅក្នុងនេះ គឺវាមានបង្ហាញអំពីតួលេខនៃការបញ្ជូនទំនិញជាមួយនឹងចិន ហើយនៅក្នុងនោះ ក៏និយាយអំពីបញ្ហាទំនិញ ដែលចំណាយដោយកម្ពុជាប្រជាធិបតេយ្យ ដោយប្រើប្រាស់លុយយ័ននោះឯង។ ឯកសារនោះ មានហត្ថលេខា វ៉ាន់ រិត ហើយនិងចំណារដែលបានលើកឡើងថា បានបញ្ជូនទៅបង ហែម និង បងវន រួចហើយ។

សាក្សី TCW-583 ក៏បានបញ្ជាក់ថា ចិនបានផ្តល់ឥណទានទៅដល់កម្មាភិបាលប្រជាធិបតេយ្យ ដើម្បីត្រួតពិនិត្យនៅធនាគារនៅបរទេស ហើយដើម្បីឲ្យធនាគារនោះ អាចរៀបចំរបាយការណ៍ទៀងទាត់ពាក់ព័ន្ធទៅនឹងទំនិញ ដែលបាននាំចេញ និងនាំចេញរួមទាំងឥណទានដែលបានផ្តល់ជូនផងដែរ។ តួលេខដែលបានបញ្ចូលនោះ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តី ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមធ្វើការជំទាស់ចំពោះការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា អំពីខ្លឹមសារនៃឯកសារ។ តាមការណែនាំរបស់លោកចៅក្រម ឡាវ៉ែន៍ កាលពីព្រឹកមិញគឺថា យើងពិនិត្យទៅលើថាតើឯកសារទាំងអស់នេះ អាចទទួលយកមកពិនិត្យបានដែរឬទេ? គឺមិនមែនពិនិត្យទៅលើខ្លឹមសារនៃឯកសារនីមួយៗនេះទេ ក៏ប៉ុន្តែខ្ញុំបានស្តាប់កន្លងមកនេះ តំណាងសហព្រះរាជអាជ្ញាបានលើកនូវចំណុចជាច្រើន អំពីខ្លឹមសារនៅក្នុងឯកសារនេះ។ បាទ សូមអរគុណ។

[១៥:០៩:៥២]

**ប្រធានអង្គជំនុំ៖**

មាន ចង់មានមតិយោបល់អ្វីលើការជំទាស់របស់មេធាវីការពារក្តីលោក ខៀវ សំផន ទេ តំណាង

សហព្រះរាជអាជ្ញាអន្តរជាតិ?

បើមានសូមអញ្ជើញ!

**លោកស្រី ហ្វាល់ហ្គុនី ដេបណាត៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំកំពុងតែមើលទៅក្នុងឯកសារ ដើម្បីបង្ហាញថាហេតុអ្វីបានឯកសារនោះអាចទុកចិត្តបាន។ ចំណុចនេះហើយ គឺត្រូវឲ្យបង្ហាញរចនាសម្ព័ន្ធនៅក្នុងឯកសារនោះ ថាតើមានអ្វីខ្លះ? ប្រសិនបើមិនចូលទៅដល់រចនាសម្ព័ន្ធខ្លឹមសារនោះទេ គឺយើងខ្ញុំមិនអាចបង្ហាញថា ឯកសារនេះយើងជឿជាក់ទុកចិត្តដោយរបៀបណានោះឡើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១០:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធនូវការជំទាស់របស់មេធាវីការពារក្ដីលោក ខៀវ សំផន ហើយសូមតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបន្តធ្វើការអត្ថាធិប្បាយរបស់ខ្លួនបន្ត។

សូមអញ្ជើញ!

**លោកស្រី ហ្វាល់ហ្គុនី ដេបណាត៖**

ការបញ្ចូលតួលេខនោះ គឺមានបញ្ជីលម្អិតទំនិញ និងការដឹកទំនិញដឹកជញ្ជូន។ ឧទាហរណ៍ឃើញមាននៅក្នុង IS21.114 និង IS21.104។ ឯកសារពាណិជ្ជកម្មនេះ គឺបង្ហាញអំពីទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសដទៃទៀត។ ឯកសារ IS18.21 ជាឧទាហរណ៍ គឺជាកិច្ចប្រជុំជាមួយនឹងកម្មាភិបាលកូរ៉េ នៅក្រសួង-- ទីស្ដីការក្រសួងពាណិជ្ជកម្ម។ របាយការណ៍នេះ ក៏បានបញ្ជូនទៅដល់បងហែម ជាទីគោរព និងជាទីស្រឡាញ់ផងដែរ។

[១៥:១២:០៧]

ឯកសារ IS21.19 ដែលក្នុងនោះនិយាយអំពីឥណទាន ១៤០ *មីលលាន*យ៉ន ដែលក្នុងនោះមានតុល្យការ និយាយអំពីប្រតិបត្តិការរបស់ប្រទេសកម្ពុជាជាមួយនឹងប្រទេសចិន និងកូរ៉េ។ ក្នុងនោះបានបង្ហាញអំពីទិន្នន័យស្រូវបញ្ជូនទៅម៉ាដាហ្គាស្កា ហើយនិងការបញ្ជូនទៅយូហ្គោស្លាវីផងដែរ នូវស្រូវទាំងអស់នោះ។

ឯកសារ D166/1.30 គឺនិយាយអំពីបញ្ហានៃស្រូវនេះផងដែរ។ ឯកសារនេះ គឺមានចំណាររបស់

វ៉ាន់ រិត ដែលបាននិយាយអំពី យ៉ន បញ្ជូនទៅរកបង ហែម និង បងវន ហើយ វន គាត់បដិសេធមិនទទួលយក ហើយក៏មិនឆ្លើយតបទៅកាន់យូហ្គោស្លាវី។

[១៥:១៣:១៥]

សូម ខ្ញុំសូមបង្ហាញអំពីប្រភពដើមនៃឯកសារនេះ។ យើងឃើញមានឯកសារប្រមូលដោយ ឌី.ស៊ី.ខេម ដែលចេញមកពីបណ្ណសារដ្ឋានជាតិ។ ឯកសារនេះជាច្រើន គឺមានលេខកាតាឡុកចេញពីឯកសារទាំងអស់នោះ។ យុ ឆាំង គាត់មកផ្តល់សក្ខីកម្មនៅទីនេះ ក្នុងពេលផ្តល់ជូនសវនាការ ដែលថាឯកសារទាំងអស់នេះអាចទៅមើលនៅបណ្ណសារដ្ឋានជាតិបាន។

ខ្ញុំសូមអនុញ្ញាតចូលប្រភេទឯកសារមួយប្រភេទទៀត ឯកសារទាំងអស់នេះយើងហៅថាឯកសារបារាំង។ ឯកសារនេះផ្តល់ជូនដោយខាងក្រសួងការបរទេសបារាំងឆ្លើយទៅតាមលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី--

[១៥:១៤:១០]

**អ្នកបកប្រែ៖**

បាទ លោកប្រធាន សូមឲ្យគាត់ជួយបញ្ជាក់នូវថ្ងៃខែ និងលេខឯកសារសាជាថ្មីវិញ។

**ប្រធានអង្គជំនុំ៖**

សូមឲ្យយឺតជាងនេះបន្តិច ហើយនិងឲ្យបញ្ជាក់នូវលេខឯកសារ និងថ្ងៃខែឆ្នាំឲ្យបានជាក់ច្បាស់។ ហើយអម្បាញ់មិញនេះ គឺមានបញ្ហាដោយសារបកប្រែមិនទាន់ ហើយសូមបញ្ជាក់សាឡើងវិញនូវឯកសារដែលបង្ហាញចុងក្រោយអម្បាញ់មិញនេះ។

[១៥:១៤:៣៨]

**លោកស្រី ហ្សាល់ហ្គុនី ដេបណាត៖**

សូមអរគុណ ខ្ញុំនឹងគោរពតាម។ ឯកសារនេះមួយចំនួន គឺមានការពិនិត្យមើលឡើងវិញទៅលើហេតុការណ៍សំខាន់ៗ ដែលកើតឡើងក្នុងប្រទេសកម្ពុជា។ គោលបំណង ហេតុអ្វីបានជាឯកសារនេះបានបង្កើតឡើងនេះ គឺយើងអាចឃើញមាននៅក្នុងកំណត់សម្គាល់ដែលដាក់អមក្នុងឯកសារ D199/26.2.105 កំណត់សម្គាល់នោះបានបញ្ជាក់លើកឡើងថា ដោយពិចារណាលើការមិនមានទំនាក់ទំនងរវាងបារាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងអវត្តមាននូវព័ត៌មានទាំងឡាយស្តីអំពីប្រធានបទពាក់ព័ន្ធទៅនឹងកម្ពុជាប្រជាធិបតេយ្យផ្នែកអាស៊ី នៃក្រសួងការបរទេសបារាំង គិតថាវាចាំបាច់ក្នុងការផ្តល់ការពិនិត្យមើលឡើងវិញ ទៅលើទំនាក់ទំនងទាំងក្នុងស្រុក និងក្រៅស្រុកនៃប្រទេសកម្ពុជាថ្មីនេះ។

របាយការណ៍ទាំងអស់នេះ វារួមមានព័ត៌មានពាក់ព័ន្ធទៅនឹងទស្សនកិច្ចរបស់អ្នកការទូតបរទេស ដែលមេដឹកនាំទទួលស្គាល់ថា ជាអ្នកការទូត ហើយមានហេតុការណ៍មួយចំនួនដែលបានកើតឡើងនៅពេលនោះ។ ហេតុការណ៍ជាច្រើនមានភាពស៊ីសង្វាក់ទៅនឹងការរៀបរាប់ក្នុងទស្សនកិច្ចមួយចំនួន ជាពិសេសនៅក្នុងការបង្ហាញ និងផ្សព្វផ្សាយដោយ ហ្វីប៊ីស។

[១៥:១៦:៥០]

ឯកសារទាំងអស់នេះមានទម្រង់បែបបទដូចគ្នា ខាងឆ្វេងខាងលើ ខាងឆ្វេងខាងលើនៃទំព័រទី១ គឺមានត្រារបស់ក្រសួងពាណិជ្ជកម្ម-- របស់ក្រសួង ខាងក្រោមគឺជាលេខដែល-- លេខឯកសារដែលពិនិត្យមើលឡើងវិញ។ នៅខាងលើខាងស្តាំនៃទំព័រទី១ យើងឃើញមានត្រានៃសាធារណរដ្ឋប្រទេសបារាំងនិងកាលបរិច្ឆេទ។

ប្រភេទឯកសារមួយទៀត ក៏បានបង្កើតផលិតដោយរដ្ឋាភិបាលបារាំងផងដែរ ហើយបានបញ្ជូនទៅតាមសំណើរបស់ ស.ច.ស.ច ដោយក្នុងនោះមានទូរលេខពីក្រសួងការបរទេសរបស់បារាំង។ ទម្រង់នៃទូរលេខនេះគឺវាមានលក្ខណៈដូច ស៊ីសង្វាក់ដូចមុនដែរ។ ក្រសួងការបរទេសតែងតែគេដាក់ស្លាកនៅខាងស្តាំខាងលើ *"ឌីស៊ីហ្វកម៉ង់"* គឺគេសរសេរនៅខាងស្តាំ ខាងលើ។ ឧទាហរណ៍យើងអាចមើលឃើញឯកសារ D199/26.2.29 នេះគឺទូរលេខចេញមកពីអាណូដ៍ (Arnaud) កម្មវត្ថុទៅនៅប្រទេសចិន ពីខាងកម្ពុជា។ អាណូដ៍ គឺជាអ្នកសរសេរទូរលេខនេះ។ ហើយគេក៏បានបញ្ជូនទូរលេខនេះពាក់ព័ន្ធទៅនឹងទស្សនកិច្ចនានាផងដែរ។ ឯកសារនេះឃើញនៅក្នុងឯកសារ D199/26.2.3 ទស្សនកិច្ចរបស់ប៉ុល ពត ទៅប្រទេសចិន គឺយើងឃើញមានផ្សព្វផ្សាយតាមសារព័ត៌មានរួមទាំងកាសែតញូវយ៉កថែមស៍ផងដែរ។

[១៥:១៩:១៣]

នៅពេលនេះ យើងមើលឯកសារ IS5.30 ឯកសារនេះគឺជាចម្លើយសារភាពរបស់ ស-២១ របស់ហ៊ូ នឹម ដែលជារដ្ឋមន្ត្រីឃោសនាការ។ ឯកសារនេះ គឺមានកំណត់ជើងទំព័រជួរទី១ នៃកថាខណ្ឌ ៨៨៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ជួរនោះលើកឡើងថា "រដ្ឋមន្ត្រីក្រសួងឃោសនាការនិងព័ត៌មាននៅក្នុងកម្ពុជាប្រជាធិបតេយ្យ គឺ ហ៊ូ នឹម ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅ ស-២១ នៅខែមេសា ឆ្នាំ៧៧"។ នៅក្នុងសេចក្តីសម្រេចរបស់សាលាដំបូងនៅថ្ងៃទី៣១ ខែមករា ២០១២ កថាខណ្ឌ៩ អង្គជំនុំជម្រះបានបញ្ជាក់ថាព័ត៌មានទាំងឡាយទទួលបានពីការធ្វើទារុណកម្មមិនមានប្រយោជន៍ឡើយ។ ការប្រើ

ឯកសារនេះគឺបានដាក់ជូនដែលវាបញ្ជាក់ថា ហ៊ូ នឹម បានបញ្ជូនទៅ ស-២១ នៅក្នុងថ្ងៃដែលគេចាប់ខ្លួនគាត់។ ឯកសារនេះមានចំណារដែលបង្ហាញថា ឌុច បញ្ជាក់ថាគាត់ជាអ្នកចំណារទៅលើលិខិត ហើយលិខិតនោះសរសេរដោយ ហ៊ូ នឹម ដាក់អមជាមួយនឹងចម្លើយសារភាពនោះ។ លិខិតនោះផ្ញើជូនទៅ ប៉ុល ពត, នួន ជា, អៀង សារី, វន វ៉េត, សុន សេន, និង ខៀវ សំផន។

[១៥:២១:00]

មេធាវីខាង អៀង សារី ជំទាស់ទៅលើឯកសារពីរ។ ទីមួយ គឺឯកសារផែនការរួមចុងក្រោយ។ ឯកសារនេះគឺបានដកស្រង់នៅក្នុងកំណត់ជើងទំព័រ៣៧៨២ និង ៣៧៨៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ឯកសារលេខ D288/6.5/2.29 ឯកសារនេះត្រង់ផ្នែកដែលពាក់ព័ន្ធលើកឡើងថា "បន្ថែមទៅលើចំណុចខាងលើ នួន ជា បានក្លាយទៅជាអនុលេខានៅភូមិភាគចំនួនពីរក្រោយពីការចាប់ខ្លួនលេខា"។ ក្រោយពីការចាប់ខ្លួននៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦ នៃលេខា ម៉ែន សាន នៃភូមិភាគពៀសាន ហៅ សៀ តួនាទីនេះគឺត្រូវបាន អ៉ំណោង ហៅ វ៉ាយ រហូតមកដល់ពាក់កណ្តាលឆ្នាំ១៩៧៨ ហើយបន្ទាប់មក នួន ជា ជំនួសសម្រាប់មួយរយៈពេលខ្លី។ ឯកសារនេះគឺការវិភាគទៅលើចម្លើយសារភាពនៅស-២១។

[១៥:២២:២២]

ការវិភាគនេះធ្វើឡើងដោយ ថន ដែលជា ប៉ុន ដែលធ្វើឡើង ប៉ុន ដែលជាប្រធានអ្នកសួរចម្លើយរបស់ ឌុច ដែលក្នុងនោះបានធ្វើវិភាគហើយបានឃើញផែនការរួបរួមគ្នាកើតឡើង។ ឯកសារនេះបានពិភាក្សានៅក្នុងការជំនុំជម្រះសំណុំរឿង០០១ ដែលក្នុងពេលសវនាការនោះ ឌុច បានបញ្ជាក់ថា ឯកសារនេះបានផលិត និងបង្កើតឡើងនៅ ស-២១ ហើយធ្វើឡើងដោយ ប៉ង់។

នៅពេលនេះខ្ញុំសូមលើកឡើងការជំទាស់ ដែលលើកឡើងដោយមេធាវីការពារក្តី។ ខ្ញុំសូមមើលឯកសារ D177/3.1 ឯកសារនេះហៅថា "រយៈពេល តារាងពេលវេលា ដែលបញ្ជាក់អំពីការធ្វើដំណើររបស់ អៀង សារី ក្នុងពេលកម្ពុជាប្រជាធិបតេយ្យ ដោយមានកំណត់ហេតុការចាប់ខ្លួន និងការសម្លាប់បុគ្គលិក អ៊ឹម.អេស.ហ្វេ។ ឯកសារនេះបានដាក់រួមបញ្ចូលគ្នានូវទម្រង់ស៊ីសង្វាក់ព័ត៌មានដែលឃើញមាននៅក្នុងឯកសារនានា ដែលឯកសារទាំងអស់នោះមាននៅក្នុងសំណុំរឿងរួចហើយ។ វិធីនៃការជំទាស់ឯកសារនេះ គឺដើម្បីបង្ហាញថា ហេតុអ្វីរយៈពេលនោះវាមិនត្រឹមត្រូវ? តែពេលនេះដែលថា ពេលនោះ អៀង សារី គាត់មិននៅទីនោះទេ នៅក្នុងហ្នឹងទេ។

[១៥:២៤:២៧]

ការជំទាស់ក៏បានលើកឡើងផងដែរ ដែលយើងថា គេជំទាស់នោះទៅលើឯកសាររបស់លោក ស្ទីវិន ហេដឌ័រ។ មេធាវីបានលើកឡើងថា ស្ទីវិន ហេដឌ័រ មិនបាន-- មិនត្រឹមតែរៀបចំដីកាបញ្ជូនរឿងទៅស៊ើបសួរទេ គាត់បានធ្វើការស៊ើបអង្កេតទៀត។ ស្ទីវិន បានចេញពីការិយាល័យ អូ.ស៊ី.ភី នៅថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០០៦ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងឆ្នាំ២០០៦ ហើយដាក់ជូនទៅដល់អង្គជំនុំជម្រះនៅឆ្នាំ២០០៧។ ស្ទីវិន ហេដឌ័រ អត់បានសរសេរដីកានេះទេ។

ឯកសារពីរពាក់ព័ន្ធទៅនឹងលោក ស្ទីវិន ហេដឌ័រ ត្រូវបានលើកឡើងមួយ គឺ D29/I Attachment 32 ហើយនិង D366/7.1.562។ ឯកសារទាំងពីរនេះ គឺជាផ្នែកមួយនៃឧបសម្ព័ន្ធ១។ ឧបសម្ព័ន្ធ១ យើងបានលើកឡើងអះអាងនៅក្នុងឯកសារបញ្ជីឯកសារ សវនាការដំណាក់កាលលើកទីមួយ។ យើងឃើញមានការជំទាស់ដែលថា ការស្តាប់ចម្លើយសាក្សីមិនបានធ្វើឡើងដោយ អូ.ស៊ី.អាយ.ជេ ដូច្នេះមិនអាចទទួលយកបាននោះទេ។ ជាថ្មីម្តងទៀត ស្របតាមឯកសារ D107 ឯកសារនេះគឺគួរតែដកចេញនូវឯកសារចម្លើយសាក្សី។

[១៥:២៦:២៨]

ដូច្នេះខ្ញុំកត់សម្គាល់ឃើញថា មេធាវី នួន ជា បានជំទាស់ទៅលើចម្លើយសាក្សីរបស់លោក អ៊ុក ប៊ុនឈឿន, ស៊ុម កា, ជា ស៊ីម, ហេង សំរិន ចម្លើយសាក្សីរបស់បុគ្គលទាំងអស់នេះគឺត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីរបស់មេធាវីនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ ដែលគាត់លើកឡើង-- ដែលមេធាវីលើក-- ការពារក្តី នួន ជា លើកឡើងអំពីចម្លើយសាក្សីរបស់បុគ្គលទាំងអស់នេះនៅចំពោះមុខអង្គជំនុំជម្រះ។

ការជំទាស់ផ្សេងទៀតពាក់ព័ន្ធទៅនឹងរបាយការណ៍ ហ្វីប៊ីស ដែលវាពាក់ព័ន្ធទៅនឹងទង់បដិវត្តកំណត់ហេតុគណៈអចិន្ត្រៃយ៍។ ការជំទាស់ទាំងអស់នោះ គឺមាននៅក្នុងឯកសារឧបសម្ព័ន្ធ១ ទៅដល់៥ នៅក្នុងបញ្ជីឯកសារ ក្នុងឯកសារសម្រាប់សវនាការដំណាក់កាលដំបូង ដែលឯកសារមួយវាស៊ីសង្វាក់ទៅនឹងឯកសារផ្សេងទៀត។ ដែលក្នុងនោះគេលើកឡើងអំពីទម្រង់បែបបទ ហើយការពិភាក្សាលក្ខណៈស៊ីសង្វាក់នោះ វាឃើញថា មានការលើកឡើងយ៉ាងលម្អិត។

ឃើញមានការជំទាស់ផងដែរទៅលើឯកសារ D56/Doc/103 ជាចម្លើយរបស់ជនជាប់ចោទ។ មេធាវីចង់ឱ្យលោក ប៉េនស្ទីង មកផ្តល់សក្ខីកម្មមុនពេលដែលយើងទទួលយកឯកសារនេះ។ ចម្លើយ

របស់ជនជាប់ចោទនៅក្នុងឧបសម្ព័ន្ធ១ ហើយក៏បានយកមកពិភាក្សានៅក្នុងបញ្ជីឯកសារសវនាការដំណាក់កាលលើកទីមួយផងដែរ។ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា នៅពេលដែល យើងមើលអានទៅលើចម្លើយរបស់ជនជាប់ចោទ យើងឃើញថាជនជាប់ចោទលើកឡើងម្តងហើយម្តងទៀតដូចតែគ្នា។ ចម្លើយរបស់ជនជាប់ចោទ គឺមានភាពស៊ីសង្វាក់គ្នា។ យើងឃើញមានការជំទាស់ទៅដល់-- ទៅលើឯកសារផ្សព្វផ្សាយរបស់សារព័ត៌មានបរទេសផងដែរ។ ការជំទាស់នោះ គឺលើកឡើងចំពោះឯកសារ D108/43/7 ជារបាយការណ៍របស់ប៊ីប៊ីស។ ខ្ញុំបានលើកឡើងបញ្ហាឯកសារ ប៊ីប៊ីស នេះនៅសវនាការមុនរួចហើយ។

[១៥:២៩:២២]

ឯការជំទាស់មួយទៀត ទៅលើឯកសារ D108/43/9 ឯកសារនេះ គឺជាការសង្ខេបនៃការផ្សព្វផ្សាយរបស់ពិភពលោកធ្វើឡើងដោយ ប៊ី.ប៊ី.ស៊ី។ ខ្ញុំក៏បានយកមកពិភាក្សានៅក្នុងការលើកឡើងបញ្ជីឯកសារសវនាការលើកដំបូងផងដែរ។ ការជំទាស់បានធ្វើឡើងផងដែរៗទៅលើឯកសារ D56/Doc.066 គឺជារបាយការណ៍សារព័ត៌មានដែលនិយាយអំពីខួបទីប្រាំមួយនៃការកងទ័ពបដិវត្តន៍កម្ពុជាចេញពីកាសែតទស្សនាវដ្តីប៉េកាំងថ្ងៃទី២៨ ខែប្រាំបួន ឆ្នាំ៧៦។ ឯកសារនេះវាស៊ីសង្វាក់ទៅនឹងឯកសារពីរផ្សេងទៀត។ ទីមួយ គឺឯកសារ D313/1.2.317 ឯកសារនេះគឺជាសេចក្តីសង្ខេបការផ្សព្វផ្សាយសារព័ត៌មានពិភពលោកដែលរាយការណ៍អំពីការប្រារព្ធខួបអនុស្សាវរីយ៍ដែល នួន ជា និង ខៀវ សំផន បានចូលរួមក្នុងពេលនោះ។

ឯកសារក៏មានការស៊ីសង្វាក់ជាមួយនឹងឯកសារមួយទៀត គឺ D248/6.1.14 ឯកសារនេះ គឺជាការសង្ខេបនៃការផ្សព្វផ្សាយសារព័ត៌មានពិភពលោកផងដែរ ដែលក្នុងឯកសារនេះគឺជាការដកស្រង់ចេញពីសុន្ទរកថាថ្លែងដោយ នួន ជា ជានាយករដ្ឋមន្ត្រីស្តីទី។ តែឯកសារនេះចុះនៅថ្ងៃទី២០ មករា ឆ្នាំ៧៧។ លោក លោកស្រីចៅក្រម នេះគឺជាការដាក់ឯកសាររបស់យើងខ្ញុំ។ សូមអរគុណ។

[១៥:៣១:៣៣]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តី នួន ជា!

**លោក អេនគ្រូ អ៊ីន្ទូស៊ី៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមរយៈពេលមួយនាទីបានទេ ដើម្បីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងឯកសារ ពីបញ្ជីឯកសាររបស់ក្រុម នួន ជា។

**ប្រធានអង្គជំនុំ៖**

ពេលវេលាបែងចែកសម្រាប់ក្រុមមេធាវីរបស់លោកបានផុតហើយ អង្គជំនុំជម្រះមិនអនុញ្ញាតទេ ពេលវេលាចុងក្រោយនេះ ត្រូវបានទៅក្រុមសហព្រះរាជអាជ្ញា និងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក អេនគ្រូ អ៊ីនូស៊ី៖**

លោកប្រធាន ខ្ញុំនេះគ្រាន់តែជាសំណើមួយដើម្បីធ្វើការឆ្លើយតបខ្លីទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាង អ៎!ខាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូន។ សូមអញ្ជើញ!

[១៥:៣៣:១០]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

បាទ លោកប្រធាន ជម្រាបសួរអស់លោកចៅក្រមជាទីគោរព។ ខ្ញុំមានការកត់សម្គាល់ខ្លីៗបន្ទាប់ពីបានស្ដាប់ការជំទាស់ជាលក្ខណៈទូទៅ។ ថ្ងៃនេះការកត់សម្គាល់ទីមួយរបស់ខ្ញុំមានដូចតទៅនេះ ហើយខ្ញុំគិតថាពុំមានអ្នកណាភ្ញាក់ផ្អើលនោះទេ ព្រោះថានេះយើងពិនិត្យលើឯកសារចំនួន៩៥ ដែលជាកំណត់សម្គាល់ជើងទំព័រនៃដីកាដំណោះស្រាយ ហើយខ្ញុំសូមលើកឡើងម្ដងទៀតថា ឯកសារទាំងអស់នេះហាក់ដូចជាត្រូវបានពិនិត្យពិច័យដ៏លម្អិតហើយ ដោយអ្នកមានជំនាញទាក់ទងនឹងគួរ ភាពគួរឲ្យទុកចិត្តបាន ហើយនិងយថាភាព ហើយឃើញ មានការវាយតម្លៃថាមានលក្ខណៈច្បាស់លាស់ពីព្រោះថាសហចៅក្រមស៊ើបអង្កេតបានប្រើឯកសារទាំងអស់នេះ ហើយបញ្ចូលនៅក្នុងដីកាដំណោះស្រាយហើយៗបន្ទាប់មកទៀតមានសេចក្ដីសម្រេចអំពីសំណាក់អង្គបុរេជំនុំជម្រះផងដែរ ហើយនេះជាទស្សនទានទូទៅដែលយើងត្រូវតែពិនិត្យ ដើម្បីឈរជាមូលដ្ឋានដើម្បីពិនិត្យមើលការជំទាស់។

[១៥:៣៤:២៤]

ការកត់សម្គាល់ទីមួយរបស់ខ្ញុំ គឺថាការជំទាស់ដែលបានលើកឡើងថ្ងៃនេះ គឺភាគច្រើននោះគឺជាការជំទាស់ដែលយើងបានពិភាក្សារួចមកហើយនៅក្នុងសវនាការមុននោះ លើការពិភាក្សាលើឯកសារ។ ឧទាហរណ៍ដូចជាការជំទាស់លើការ ថាយើងចង់បង្ហាញ ឲ្យបង្ហាញឯកសារដើម ឬក៏ការជំទាស់លើការដែលថាឯកសារទាំងឡាយដែលមកពីមជ្ឈមណ្ឌលកម្ពុជាមិនគួរឲ្យទុកចិត្តបាន ឬក៏ថាការជំទាស់ថា

ត្រូវតែស្តាប់អ្នកនិពន្ធនៃឯកសារជាដាច់ខាត ឬក៏ថាអ្នកនិពន្ធសៀវភៅ ឬក៏ថា អ្នកផ្តល់បទសម្ភាសន៍ ឬក៏ជាអត្ថបទកាសែតជាដើមនោះ។ នេះគឺជាការជំទាស់ដែលយើងបានស្តាប់ហើយៗកាលពីការពិភាក្សាគ្នាដំបូងលើឯកសារនោះ ឧទាហរណ៍ ទាក់ទងនឹងការថែរក្សាឯកសារជាដើម ដែលចេញពីមជ្ឈមណ្ឌលកម្ពុជា ឬក៏ចេញពីបណ្ណសារជាតិទាំងអស់នេះ។ អ៊ីចឹងយើងឃើញថា ការជំទាស់នោះដដែលជាដដែល។ អ៊ីចឹង ខ្ញុំគិតថា គួរតែយោងទៅលើអ្វីដែលយើងបានលើកឡើងពាក់ព័ន្ធនឹងប្រធានបទនេះទៅ។

ការកត់សម្គាល់របស់ខ្ញុំមួយទៀតគឺថា ខ្ញុំគិតថា មិនជាការគ្រប់គ្រាន់ទេ ដែលក្នុងការនិយាយថា សេចក្តីថ្លែងការណ៍ក្រៅក្របខ័ណ្ឌតុលាការមិនអាចយកទុកចិត្តបាននោះ។ បើសិនជាយើងចង់ពិភាក្សាអំពីសេចក្តីប្រកាសដែលថា នៅក្រៅក្របខ័ណ្ឌតុលាការនោះ យើងគួរតែយ៉ាងហោចណាស់ គួរតែបង្ហាញឲ្យឃើញថាតើភាពគួរឲ្យទុកចិត្តបាន ឬការសន្មតថា ការអាចទុកចិត្តបាន ដែលថាចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ហើយនោះ ដែលអាចយកមកចោទជាបញ្ហាបាននោះ វានៅត្រង់ណា? ខ្ញុំឃើញថា ខាងភាគីការពារក្តីមិនបានធ្វើការបង្ហាញនោះទេ។

[១៥:៣៦:១៩]

ខ្ញុំមានការកត់សម្គាល់មួយទៀត ដែលមិនមែនជាការឆ្លើយតប ធ្វើការជំទាស់ទេ គ្រាន់តែជាការកត់សម្គាល់ពិសេសមួយ ទៅលើសំណុំឯកសារមួយ ដែលនៅក្នុងចំណោមឯកសារទាំង៩៥ នោះគឺថា មានឯកសារចំនួន៣៧ ដែលនៅក្នុងឧបសម្ព័ន្ធទី៧ ដែលទាក់ទងទៅនឹងឯកសារដែលចេញមក ពីក្រសួងពាណិជ្ជកម្ម។ ចំពោះយើង យើងយល់ឃើញថា ដើម្បីជាប្រយោជន៍ដល់យុត្តិធម៌ យើងគួរតែពិភាក្សាអំពីឯកសារទាំង៣៧នេះ នៅក្នុងក្របខ័ណ្ឌ នៃឧបសម្ព័ន្ធទី៧ ពីព្រោះខ្ញុំគិតថា ឧបសម្ព័ន្ធនេះ យើងនឹងយកមកពិភាក្សានៅថ្ងៃក្រោយ។

ហើយខ្ញុំចង់ធ្វើការកត់សម្គាល់មួយទៀត ទាក់ទងទៅនឹងចម្លើយសារភាព ព្រោះថាមានចម្លើយសារភាពមួយដែលបានលើកឡើងមកពិភាក្សា។ ខ្ញុំយល់ឃើញថា យើងជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាដំបូងគឺថា យើង-- ជាមេធាវីតែម្តង គឺយើងទាមទារឲ្យមានការអនុវត្តមាត្រាទី១៥ នៃអនុសញ្ញាលើការធ្វើទារុណកម្ម។ នៅក្នុងអនុស្សរណៈចុះថ្ងៃទី៣០ មករា មានការថែងថា យើងអាចប្រើឯកសារនេះដើម្បីបង្ហាញថា មានការធ្វើទារុណកម្ម មិនមែនបង្ហាញថា-- និយាយអំពីខ្លឹមសារនៅក្នុងឯកសារនេះទេ។ អ៊ីចឹងសហព្រះរាជអាជ្ញា អំមិញគាត់បានលើកឡើងហើយ។ នេះគឺជាការកត់សម្គាល់របស់ខ្ញុំ។

[១៥:៣៨:០៩]

ខ្ញុំមិនដឹងថា សហភាតារបស់ខ្ញុំចង់បន្តទៀត ឬក៏យ៉ាងណានោះទេ។ សូមអរគុណ។ ខ្ញុំគិតថា ខាងមេធាវីនាំមុខនេះ មិនមានការអធិប្បាយអីទៀតទេ ទាក់ទងនឹងឯកសារនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៩:៣១]

បាទ ឥឡូវនេះដោយសារ នៅមានពេលខ្លះ ហើយអំមិញហ្នឹងឃើញថា មេធាវីការពារក្តីលោក នួន ជា មានបំណងចង់ធ្វើសេចក្តីតប ចំពោះការអត្ថាធិប្បាយរបស់ក្រុមសហព្រះរាជអាជ្ញា ហើយនិង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយអង្គជំនុំជម្រះមិនដឹងថាតើលោកត្រូវការចំណាយ ពេលវេលាប៉ុន្មានទេ។ លោកត្រូវការពេលវេលាប៉ុន្មានបង្ហាញឲ្យច្បាស់លាស់ ដើម្បីឲ្យអង្គជំនុំជម្រះ ពិចារណា អំពីបញ្ហានេះ។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន តែមួយនាទីទេ គ្រប់គ្រាន់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែសូមរំឭកថា ភាគីទាំងអស់ដែលពាក់ព័ន្ធគឺកន្លងទៅ គឺអង្គជំនុំ ជម្រះបានជម្រាបជូនរួចហើយ ថាបណ្តាសាក្សីទាំងឡាយ ទាំងសាក្សី ទាំងដើមបណ្តឹងរដ្ឋប្បវេណី អង្គ ជំនុំជម្រះបានកំណត់នូវរហស្សនាមរួចហើយ ប្រសិនបើមានការពាក់ព័ន្ធនឹងបុគ្គលដែលបានកំណត់ រហស្សនាមរួចហើយ គឺសូមប្រើប្រាស់រហស្សនាម មិនអនុញ្ញាតនូវការបង្ហាញនូវនាម គោត្តនាមរបស់ គេនៅដំណាក់កាលនេះទេ។ ហើយនេះ ជាការអនុវត្តនូវអនុសញ្ញាអន្តរជាតិ ស្តីពីកិច្ចការពារដល់សាក្សី នៅក្នុងរឿងព្រហ្មទណ្ឌ។

សូមអញ្ជើញ!

[១៥:៤១:១២]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែសុំបញ្ជាក់ គឺការជំទាស់របស់យើងខ្ញុំ គឺទៅនឹងឯកសារបី ដែលសហព្រះរាជអាជ្ញាបានលើកឡើង គឺសេចក្តីថ្លែងការណ៍របស់ អ៊ុក ប៊ុនឈឿន ដែលជាព្រឹទ្ធសភា

នៃគណបក្សប្រជាជន និងជា ស៊ីម ដែលជាប្រធានព្រឹទ្ធសភា និងហេង សំរិន ដែលជាប្រធានរដ្ឋសភា។ នេះគឺមាននៅក្នុងបញ្ជី។ ការជំទាស់គឺដើម្បីបញ្ជាក់អំពីសកម្មភាពរបស់ជនជាប់ចោទ គឺថាយើងខ្ញុំសូមបញ្ជាក់ថា មិនអាចចោទប្រកាន់ទៅលើសកម្មភាព ដោយមិនមានការសាកសួរដេញដោលទៅលើសាក្សីទាំងនេះ បានទេ។

យើងខ្ញុំបានដាក់ឯកសារនេះ ដោយមានហេតុផលមួយផ្សេង ប៉ុន្តែការជំទាស់ពីព្រឹកមិញនេះ គឺដើម្បីនិយាយបញ្ជាក់អះអាង អំពីសកម្មភាពរបស់ជនជាប់ចោទ។ បើមិនអាចធ្វើដូច្នេះបានទេ បើមិនមានវត្តមានរបស់សាក្សីនៅតុលាការ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ហើយឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ សម្រាប់កិច្ចដំណើរការសវនាការថ្ងៃនេះ។

ដូច្នេះ អង្គជំនុំជម្រះសម្រេចថា ដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺផ្អាកត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១២ ខែមីនា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក អាស្រ័យហេតុនេះ សូមភាគី និងសាធារណជនជ្រាប។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងបីរូប មកកាន់សាលសវនាការនេះ នៅព្រឹកថ្ងៃចន្ទ ទី១២ ខែមីនា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៤៣នាទី)*